មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

Cambodian Center for Human Rights

ខែកញ្ញា ឆ្នាំ ២០១៦

# ការរើសអើងលើអ្នកប្តូរភេទជាស្ត្រីនៅតាមទីប្រជុំជនក្នុង ព្រះរាជាណាចក្រកម្ពុជា



ឧបត្ថម្ភដោយ

rfsu

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") គឺជាអង្គការមិនមែនរដ្ឋាភិបាល ("អង្គការ") មិនចូលបក្សសម្ពន្ធ ឯករាជ្យ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឱ្យកម្ពុជាក្លាយជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលក្នុងនោះប្រជាពលរដ្ឋទទួលបានសិទ្ធិមនុស្សជាមូលដ្ឋាន មានសមភាព ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ ម.ស.ម.ក ចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព ស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុនិយមដោយក្នុងនោះភាពចម្រុះបែបនៃសង្គមត្រូវបានទទួលយកនិងសាទរ ជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់ ម.ស.ម.ក រំលេចអោយឃើញរូបសត្វព្រាបស ហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវដែលនេះជានិមិត្តរូបនៃការទាមទារសេរីភាពរបស់កម្ពុជា។

## អំពីរបាយការណ៍

របាយការណ៍ស្រាវជ្រាវនេះ ("របាយការណ៍") ចងក្រងពីបញ្ហាសិទ្ធិមនុស្សដែលអ្នកប្តូរភេទជាស្ត្រីបានជួបប្រទះនៅតាមទីប្រជុំជនក្នុងប្រទេសកម្ពុជា និងផ្តល់អនុសាសន៍ជាសកម្មភាពក្នុងការធានាថាពួកគាត់ទទួលបានសិទ្ធិស្មើគ្នា សេចក្តីថ្លៃថ្នូរ សុខភាព និងសន្តិសុខ។ របាយការណ៍នេះផលិតដោយគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ របស់ ម.ស.ម.ក ដែលចាប់ផ្តើមដំណើរការតាំងពីឆ្នាំ ២០១០ ក្នុងគោលបំណងផ្តល់អំណាចដល់សហគមន៍ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ("អ្នកស្រឡាញ់ភេទដូចគ្នា") និងតស៊ូមតិចំពោះសិទ្ធិរបស់ពួកគាត់នៅកម្ពុជា។

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ អាចរៀបចំទៅបានដោយមានការគាំទ្រពីសមាគមអប់រំអំពីផ្លូវភេទរបស់ប្រទេសស៊ុយអែត។ ម.ស.ម.ក សូមថ្លែងអំណរគុណដល់សហគមន៍ឥន្ទធនូកម្ពុជា អនាគតយុវជនកម្ពុជាអាស៊ាន សុខភាពបុរសកម្ពុជា ខេមរា បណ្តាញចតុមុខ សេវាសង្គមសុខភាពបុរស អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (រ៉ាក់) និង ចារ៉ែត ដេវីស ចំពោះជំនួយនៅក្នុងការតាក់តែងរបាយការណ៍នេះ។ ខ្លឹមសារនៅក្នុងរបាយការណ៍នេះ គឺជាការទទួលខុសត្រូវរបស់ ម.ស.ម.កនិងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សមាគមអប់រំអំពីផ្លូវភេទរបស់ប្រទេសស៊ុយអែត ឬដៃគូផ្សេងទៀតនោះទេ។ ម.ស.ម.ក ក៏សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះអ្នកប្តូរភេទជាស្ត្រីទាំងអស់ដែលបានចូលរួមក្នុងការស្រាវជ្រាវដើម្បីចងក្រងជារបាយការណ៍នេះឡើង ។

## សំណួរ និងមតិឆ្លើយតប

ប្រសិនបើលោកអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ ឬប្រសិនបើអ្នកមានបំណងចង់ផ្ដល់មតិឆ្លើយតប សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈ info@cchrcambodia.org ។

របាយការណ៍នេះ និងឯកសារបោះពុម្ពផ្សេងទៀតទាំងអស់របស់ ម.ស.ម.ក អាចរកមើលបាននៅលើគេហទំព័រដែលទទួលបានពានរង្វាន់ខាងផ្នែកសិទ្ធិមនុស្សតាមរយៈគេហទំព័រ www.sithi.org ដែលគ្រប់គ្រងដោយ ម.ស.ម.ក។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១៦
ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# មាតិកា

ពាក្យកាត់ ........ v
និយមន័យ ........ vi
មូលន័យសង្ខេប ........ viii
១. សេចក្តីផ្តើម ........ 1
១. ១ តើពាក្យថា "អ្នកប្តូរភេទ" មានន័យដូចម្តេច? ........ 1
១.២ បរិបទកម្ពុជា - ប្រវត្តិសាស្ត្រ វប្បធម៌ និងសង្គម ........ 2
១.២.១ ទស្សនៈបែបវប្បធម៌ និងប្រវត្តិសាស្ត្រនៃអត្តសញ្ញាណយេនឌ័រនៅកម្ពុជា ........ 3
២. គោលបំណង វិសាលភាព និងវិធីសាស្ត្រ ........ 5
២.១ វិធីសាស្ត្រ ........ 6
២.២ ដែនកំណត់ ........ 7
៣. សិទ្ធិ និងច្បាប់ស្តីពីអ្នកប្តូរភេទ ........ 8
៣.១ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ........ 8
៣.២ ច្បាប់ជាតិ ........ 11
៤. របកគំហើញពីការស្រាវជ្រាវ និងការពិភាក្សា ........ 13
៤.១ ការកំណត់អត្តសញ្ញាណផ្ទាល់ខ្លួន ........ 13
៤.២ ការបំពាននៅទីសាធារណៈ ........ 14
៤.៣ លក្ខខណ្ឌរស់នៅ គ្រួសារ និងទំនាក់ទំនង ........ 19
៤.៤ ការងារ ........ 22
៤.៥ នគរបាល និងអាជ្ញាធរ ........ 25
៤.៦ ការងាររកស៊ីផ្លូវភេទ និងការរើសអើងពីសង្គម ........ 28
៤.៦.១ ការរើសអើងរបស់នគរបាលលើអ្នករកស៊ីផ្លូវភេទដែលជាមនុស្សប្តូរភេទ ........ 31
៤នគរបាលរបស់បន្ថោកបន្ទាបធម៌ និងអមនុស្ស ដ៏ឃោរឃៅប្រព្រឹត្តិការ ៧. ........ 32

៤.៧.១ ការបង្ខំឱ្យចុះងូតទឹកនៅក្រុងសៀមរាប ........................................................ 32
៤.៨ ការរាយការណ៍ពីការបំពាននានា ........................................................ 35
៤.៩ សុខភាពផ្លូវចិត្ត និងផលប៉ះពាល់ចិត្តសាស្ត្រពីការរើសអើង ........................................................ 35
៤.១០ ការស្វែងរកជំនួយ និងក្រុមគាំទ្រ ........................................................ 37
៥. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍ ........................................................ 39

# ពាក្យកាត់

| | |
|---|---|
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| អ.ស.ប | អ្នកប្តូរភេទពីស្ត្រីទៅជាបុរស |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ក.អ.ស.ស.វ | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ |
| អ្នកស្រឡាញ់ភេទដូចគ្នា | ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ |
| អឹម អេច្ឆ ស៊ី | អង្គការសុខភាពបុរសកម្ពុជា |
| ប.ស.ប | បុរសស្រឡាញ់បុរស |
| អ.ប.ស | អ្នកប្តូរភេទពីបុរសទៅជាស្ត្រី |
| សង្គមស៊ីវិល | អង្គការមិនមែនរដ្ឋាភិបាល |
| អូ អេច្ឆ ស៊ី អេច្ឆ អ | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |
| រ៉ក់ | សហគមន៍ឥន្ទធនូកម្ពុជា |
| សូជី | និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ |
| សូជីអី | និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវទំនោរយេនឌ័រ |
| អ.ប.ជ.ប | អ្នកប្តូរភេទជាបុរស |
| អ.ប.ជ.ស | អ្នកប្តូរភេទស្ត្រី |
| ស.ប.ស.ស | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| អ.ស.ប | អង្គការសហប្រជាជាតិ |

# និយមន័យ

| | |
|---|---|
| **យេនឌ័រពីកំណើត** ( Cis-gender) | បុគ្គលដែលមានការនិយមផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រស្របទៅតាមភេទ ដែលគាត់មានពីកំណើត មិនមែនជាអ្នកប្តូរភេទនោះទេ។ |
| **យេនឌ័រ** | សំដៅលើតួនាទី អាកប្បកិរិយា សកម្មភាព និងលក្ខណៈសម្បត្តិនានា ដែលសង្គមមួយចាត់ទុកសមស្របសម្រាប់បុរស និងស្ត្រី។ |
| **ការបង្ហាញលក្ខណៈយេនឌ័រ** | សំដៅលើការបង្ហាញឡើងនូវអាកប្បកិរិយារបស់បុគ្គលតាមទំនោរផ្នែកយេនឌ័ររបស់ខ្លួន។ ក្នុងន័យនេះអាចរាប់បញ្ចូលទាំងការបញ្ចេញឥរិយាបថ និងឬកពាខាងក្រៅ ដូចជាតាមរយៈសំលៀកបំពាក់ ការតុបតែងខ្លួន ការសម្តែងកាយវិការ ការនិយាយ ការដាក់ឈ្មោះ និងការបញ្ចេញសំឡេង។ |
| **អត្តសញ្ញាណយេនឌ័រ** | សំដៅទៅលើអារម្មណ៍ខាងក្នុងផ្ទាល់ខ្លួន និងបទពិសោធន៍របស់បុគ្គលម្នាក់ទៅលើយេនឌ័ររបស់ខ្លួន ដែលអាច ឬមិនអាចស៊ីសង្វាក់ទៅនឹងភេទពីកំណើតរបស់បុគ្គលនោះទេ។ |
| **ភេទ** | សំដៅទៅលើលក្ខណៈក្រូម៉ូសូមអ័រម៉ូន(ជីវសាស្ត្រ) និងលក្ខណៈសរីរាងបន្តពូជ និងភេទរបស់បុគ្គលម្នាក់ដែលបានកំណត់ថាជាភេទប្រុស និងភេទស្រី។ |
| **និន្នាការភេទ** | សំដៅលើអារម្មណ៍ស្រឡាញ់ មនោសញ្ចេតនា ឬចំណង់ផ្លូវភេទ ទំនាក់ទំនងផ្លូវភេទរបស់បុគ្គលម្នាក់ទៅលើបុគ្គលផ្សេងទៀតដែលមានភេទជាក់លាក់ណាមួយអាចជាបុគ្គលភេទដូចគ្នា ឬទៅលើបុគ្គលទាំងពីរភេទ។ |
| **មនុស្សភេទទី ៣** | ជាពាក្យស័ព្ទមួយដែលប្រើនៅពេលវប្បធម៌ទទួលស្គាល់ថាយេនឌ័រទី៣ ឬច្រើន ដើម្បីពិពណ៌នាពីបុគ្គលណាម្នាក់ដែលមិនមានអត្តសញ្ញាណថាជាបុរស ឬស្ត្រី។ |
| **អ្នកប្តូរភេទ** | ជាពាក្យសម្គាល់ទៅលើបុគ្គលដែលមានអត្តសញ្ញាណយេនឌ័រ និងការសំដែងចេញនូវយេនឌ័រខុសពីភេទពីកំណើតរបស់បុគ្គលនោះ។ |
| **អ្នកប្តូរភេទជាបុរស** | សំដៅទៅលើបុគ្គលម្នាក់ដែលមានភេទពីកំណើតជាស្រី ប៉ុន្តែអត្តសញ្ញាណយេនឌ័ររបស់គាត់ជាបុរសទៅវិញ ។ |

**អ្នកប្តូរភេទជាស្ត្រី** សំដៅទៅលើបុគ្គលម្នាក់ដែលមានភេទពីកំណើតជាប្រុស ប៉ុន្តែអត្តសញ្ញាណយេនឌ័ររបស់គាត់ជាស្ត្រីទៅវិញ ។

# មូលន័យសង្ខេប

ការស្រាវជ្រាវរបស់ ម.ស.ម.ក ដែលប្រមូលបាន ១៣៥នាក់ តាមរយៈការស្ទង់មតិធ្វើឡើងនៅខែមេសា ឆ្នាំ ២០១៦ ក្នុងរាជធានីភ្នំពេញ ក្រុងសៀមរាប ក្រុងព្រះសីហនុ និងក្រុងបាត់ដំបង បានរកឃើញថាអ្នកប្តូរភេទជាស្ត្រីជួបប្រទះការរើសអើងក្នុងកម្រិតខ្ពស់នៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") រួមទាំងការប្រមាថដោយពាក្យសម្តី ការបំពានលើរាងកាយ និងការបៀតបៀនកេរ្តិ៍ខ្មាស់តាមទីសាធារណៈ ការមិនផ្តល់ឱកាសការងារ និងការឃាត់ខ្លួន ការឃុំខ្លួន និងការបំពានដោយរើសអើងពីសំណាក់នគរបាល។ ទន្ទឹមនឹងមន្ត្រីជាន់ខ្ពស់នៅក្នុងរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") បង្ហាញថាកម្ពុជាជាប្រទេសគាំទ្រក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅប៉ុន្មានឆ្នាំចុងក្រោយនេះក្តី ក៏ការស្រាវជ្រាវនេះបង្ហាញថាភាពពិតជាក់ស្តែងមានស្ថានភាពអាក្រក់នៅតាមមូលដ្ឋាន។ លទ្ធផលនៃការស្រាវជ្រាវនេះចង្អុលបង្ហាញថាការប្រព្រឹត្តលើអ្នកប្តូរភេទជាស្ត្រីទាមទារឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់ ប្រសិនបើកម្ពុជាមានបំណងបំពេញតាមកាតព្វកិច្ចអន្តរជាតិស្តីពីសិទ្ធិមនុស្ស។

អ្នកប្តូរភេទជាស្ត្រីស្ទើរតែទាំងអស់ដែលបានចូលរួមការស្ទង់មតិជាមួយ ម.ស.ម.ក ធ្លាប់ត្រូវបានគេប្រមាថនៅតាមទីសាធារណៈ[1] ដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគាត់ ហើយភាគច្រើនបានជួបបញ្ហានេះជាច្រើនដងនៅក្នុងរយៈពេល ១២ ខែចុងក្រោយនេះ។ ចំនួនអ្នកផ្តល់សម្ភាសន៍ដែលធ្លាប់ត្រូវបានគេបំពានដោយពាក្យសម្តីមានចំនួន ៩២% អំពើហិង្សាលើរាងកាយមានចំនួន ៤៣% ការបំពានខាងផ្លូវភេទ មានចំនួន ៣១% និងការរំលោភសេពសន្ថវៈមានចំនួន ២៥% នៅតាមទីសាធារណៈ ដែលនេះបង្ហាញថាតាមដងផ្លូវនៅកម្ពុជាជាកន្លែងមិនមានសុវត្ថិភាព និងគួរឱ្យព្រួយបារម្ភសម្រាប់អ្នកប្តូរភេទជាស្ត្រី។ ជនរងគ្រោះពីការបំពានទាំងនេះ មានអារម្មណ៍ថាពួកគាត់មិនអាចរកជំនួយបានទេ ហើយជឿជាក់ថាគ្មានផ្លូវដែលអាជ្ញាធរនឹងរកយុត្តិធម៌ឱ្យពួកគាត់នោះដែរ។ កង្វះជំនឿពីការអនុវត្តច្បាប់ប្រហែលជាមានឫសគល់មកពីកម្រិតការបំពានខ្ពស់ខ្លាំងពីសំណាក់នគរបាលផ្ទាល់។ កម្រិតនៃការប្រមាថ និងការបំពានលើអ្នកប្តូរភេទជាស្ត្រីពីសំណាក់នគរបាល មានកម្រិតខ្ពស់គួរឱ្យព្រួយបារម្ភខ្លាំង ដោយមានចំនួនអ្នកផ្តល់សម្ភាសន៍យ៉ាងច្រើនត្រូវបានឃាត់ខ្លួន និងឃុំខ្លួន និងជារឿយៗត្រូវបានបំពានដោយនគរបាល ដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគាត់។ ចំនួនច្រើនជាងមួយភាគបីនៃអ្នកផ្តល់សម្ភាសន៍(ស្មើនឹង ៣៨,៧%) ត្រូវបានឃាត់ខ្លួន ហើយក្នុងចំណោមនោះមាន ៩១,៦៧% ជឿថានគរបាលឃាត់ខ្លួនពួកគាត់ដោយសារតែអត្តសញ្ញាណជាអ្នកប្តូរភេទរបស់ពួកគាត់។ អ្នកផ្តល់សម្ភាសន៍ប្រហែលចំនួនមួយភាគបី(ស្មើនឹង ៣៣,៥៨%) ត្រូវបានចោទប្រកាន់ដោយទម្លាក់កំហុសថាបានប្រព្រឹត្តបទល្មើស។ ព័ត៌មានពិស្តារគួរឱ្យបារម្ភមួយបង្ហាញតាមរយៈការស្រាវជ្រាវនេះគឺការប្រព្រឹត្តដែលមិនធ្លាប់

[1] ការយោងទៅលើវាក្យស័ព្ទ "ទីសាធារណៈ" នៅក្នុងរបាយការណ៍នេះឆ្លើយតបទៅនឹងសំណួរស្ទង់មតិដែលសាកសួរអំពីបទពិសោធន៍របស់អ្នកផ្តល់សម្ភាសន៍នៅពេល "ដើរហើរនៅខាងក្រៅ"។ នៅខណៈដែលពាក្យនេះបង្កប់ពីធាតុផ្សំតាមបែបការបញ្ចេញពីអារម្មណ៍ និងគំនិត និយមន័យនេះមានគោលបំណងឆ្លើយតបទៅនឹងអារម្មណ៍ផ្ទាល់របស់អ្នកផ្តល់សម្ភាសន៍ពេលនៅតាម "ទីសាធារណៈ"។

ត្រូវបានរាយការណ៍នាពេលកន្លងមកទៅលើអ្នកប្តូរភេទជាស្ត្រី ដែលត្រូវបាននគរបាលប្រមាថនៅតាមទីសាធារណៈ និងបង្ខំឱ្យចុះងូតទឹកនៅក្នុងស្ទឹងនៅក្រុងសៀមរាប។ អំពើនេះអាចចាត់ទុកថាជាការប្រព្រឹត្តដ៏ឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោក ព្រមទាំងអាចជាការធ្វើទារុណកម្ម ស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

ការស្រាវជ្រាវនេះបង្ហាញថាការរើសអើងកើតឡើងដោយមិនគិតពីមុខរបររបស់អ្នកប្តូរភេទជាស្ត្រីឡើយ ទោះបីជាអ្នកប្តូរភេទជាស្ត្រីខ្មែរភាគច្រើនធ្វើការនៅក្នុងមុខរបរតាមបែបស្ត្រី ដូចជានៅតាមហាងកាត់សក់ និងកែសម្ផស្ស និង/ឬការងាររកស៊ីផ្លូវភេទ។ ប្រការនេះប្រហែលជាផ្នែកមួយបណ្តាលមកពីការរើសអើងរបស់និយោជកដោយអ្នកផ្តល់សម្ភាសន៍ចំនួន ៣៤% រាយការណ៍ថាខ្លួនត្រូវបានបដិសេធទទួលឱ្យធ្វើការនិង ២៥% រាយការណ៍ថាខ្លួនត្រូវបានបណ្តេញចេញពីការងារដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគាត់។ ការដាក់កំហិតចំពោះខ្លួនឯងដែលធ្វើឱ្យអ្នកប្តូរភេទជាស្ត្រីមានអារម្មណ៍ថាខ្លួនមិនអាចមានការងារប្រាកដប្រជា ក៏ជាកត្តាចម្បងមួយក្នុងការរឹតត្បិតដល់អ្នកប្តូរភេទជាស្ត្រីជាច្រើនឱ្យធ្វើការងារបែបស្ត្រីនិងការងាររកស៊ីផ្លូវភេទ។ ប្រហែលជាគ្មានអ្វីត្រូវភ្ញាក់ផ្អើលទេដែលអ្នករកស៊ីផ្លូវភេទមានអត្រារើសអើងខ្ពស់ជាងអ្នកមិនរកស៊ីផ្លូវភេទបានជួបប្រទះបញ្ហាជាច្រើនក្នុងជីវិត។ ការស្រាវជ្រាវនេះក៏បង្ហាញថាអ្នកប្តូរភេទជាស្ត្រីទំនងជាក្លាយជាអ្នករកស៊ីផ្លូវភេទប្រសិនបើពួកគាត់ត្រូវបានបដិសេធទទួលឱ្យធ្វើការឬ ត្រូវបណ្តេញចេញពីការងារដោយផ្អែកលើមូលដ្ឋាននៃការរើសអើង។

ការស្រាវជ្រាវក៏រកឃើញដែរថា គ្រួសារជាច្រើនមិនយល់និងមិនទទួលស្គាល់សមាជិកគ្រួសារដែលជាអ្នកប្តូរភេទបន្ទាប់ពីពួកគាត់បង្ហាញអត្តសញ្ញាណយេនឌ័រពិតរបស់ពួកគាត់ដោយអ្នកផ្តល់សម្ភាសន៍ចំនួន ៤៨,៨៥% រាយការណ៍ថាពួកគាត់ធ្លាប់មានអារម្មណ៍ថាពួកគាត់ត្រូវចាកចេញពីផ្ទះដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគាត់។ អារម្មណ៍រើសអើងដែលជិតដាមចំពោះអត្តសញ្ញាណអ្នកប្តូរភេទនៅតែកើតមាន ហើយអ្នកផ្តល់សម្ភាសន៍ជាច្រើនបានរាយការណ៍មកថា មូលហេតុនៃការខ្វះការគាំទ្រពីគ្រួសាររបស់ពួកគាត់គឺមកពីការបារម្ភពីកេរ្តិ៍ឈ្មោះគ្រួសារ និងកង្វះការយល់ដឹងពីអ្នកប្តូរភេទ និងបញ្ហាអត្តសញ្ញាណយេនឌ័រ។ គួរឱ្យកត់សម្គាល់ គ្រួសាររបស់អ្នកផ្តល់សម្ភាសន៍ច្រើនជាងពាក់កណ្តាល (ស្មើនឹង ៥៣,៤៩%) ព្យាយាមបង្ខំអ្នកផ្តល់សម្ភាសន៍ឱ្យរៀបការជាមួយមនុស្សដែលមានភេទផ្ទុយគ្នា។

ថ្វីបើរបាយការណ៍បានបង្ហាញពីកម្រិតខ្ពស់នៃការរើសអើងក៏ដោយ ក៏អ្នកប្តូរភេទជាស្ត្រីភាគច្រើនបាននិយាយថាជីវិតរបស់ពួកគាត់ប្រសើរជាងមុនចាប់តាំងពីបង្ហាញអត្តសញ្ញាណយេនឌ័រពិតមក និងអាចនិយាយបានថាពួកគាត់សប្បាយចិត្ត។ ទោះជាយ៉ាងណាក្តី អ្នកប្តូរភេទជាស្ត្រីមានចំនួនច្រើនជាងមួយភាគបីមានអារម្មណ៍ថាសោកស្តាយដែលបានបង្ហាញអត្តសញ្ញាណពិត ហើយចំនួន ៤១% មានគំនិតថាចង់ធ្វើអត្តឃាតដោយសារតែមូលហេតុរើសអើង និងការប្រមាថដែលពួកគាត់បានជួបប្រទះ។ ក៏ប៉ុន្តែ កំណើនអង្គការ និងបណ្តាញគាំទ្រថ្មីៗជាច្រើននៅទូទាំងប្រទេសដែលធ្វើការជាមួយ និងអង្គការមូលដ្ឋាន និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ជាការជំរុញទឹកចិត្តបន្ថែមដល់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។ ខ្លឹមសារសង្ខេបនៃគោលបំណងចម្បងៗនៃផ្នែកនីមួយៗនៅក្នុងរបាយការណ៍នេះមានដូចខាងក្រោម ៖

**ជំពូកទី ១ (សេចក្តីផ្តើម)** បរិយាយសង្ខេបស្តីពីប្រវត្តិ និងកម្មវត្ថុនៃការសិក្សានេះ ដោយមានការឱ្យនិយមន័យពាក្យសំខាន់ៗ និងបង្ហាញពីភាពងាយរងគ្រោះរបស់អ្នកប្តូរភេទជាស្ត្រី ថាជាក្រុមមួយនៅទូទាំងពិភពលោក ក៏ដូចជានៅប្រទេសកម្ពុជា។

**ជំពូកទី ២ (គោលបំណង វិសាលភាព និងវិធីសាស្ត្រ)** បង្ហាញពីគោលបំណង កម្មវត្ថុ និងមូលហេតុដែលជំរុញឱ្យមានការសិក្សាស្រាវជ្រាវ និងគូសបញ្ជាក់ពីវិធីសាស្ត្រដែលយកមកប្រើក្នុងការសិក្សាស្រាវជ្រាវ។

**ជំពូកទី ៣ (សិទ្ធិ និងច្បាប់ស្តីពីអ្នកប្តូរភេទ)** បង្ហាញពីការការពារដែលផ្តល់ដោយច្បាប់ជាតិ និងអន្តរជាតិដល់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ដោយផ្តោតលើក្រុមអ្នកប្តូរភេទ។

**ជំពូកទី ៤ (របកគំហើញពីការសិក្សាស្រាវជ្រាវ និងការពិភាក្សា)** បង្ហាញពីរបកគំហើញពីការសិក្សាស្រាវជ្រាវ និងវិភាគពីលទ្ធផលស្រាវជ្រាវនេះផងដែរ។

**ជំពូកទី ៥ (សេចក្តីសន្និដ្ឋាន និងអនុសាសន៍)** សង្ខេបពីរបកគំហើញសំខាន់ៗមួយចំនួនដែលទទួលបានពីការស្រាវជ្រាវនេះ និងប្រើប្រាស់របកគំហើញទាំងនេះដើម្បីផ្តល់អនុសាសន៍សមស្របដល់អ្នកពាក់ព័ន្ធផ្សេងៗក្នុងគោលបំណងលើកកម្ពស់ស្ថានភាពសិទ្ធិមនុស្សរបស់អ្នកប្តូរភេទជាស្ត្រី។

# ១. សេចក្តីផ្តើម

នៅក្នុងសកលលោក អ្នកប្តូរភេទជាស្ត្រីទទួលរងការបំពានសិទ្ធិមនុស្សជាច្រើនប្រភេទនៅក្នុងវិស័យសាធារណៈ និងឯកជន ទាំងផ្នែកផ្លូវចិត្ត និងរាងកាយ។ អ្នកប្តូរភេទជាទូទៅគឺជាជនងាយរងគ្រោះពីការរើសអើងដោយសារតែនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងទំនោរយេនឌ័ររបស់ពួកគាត់ជារឿយៗងាយនឹងឱ្យអ្នកដទៃមើលឃើញ ហើយជាពិសេស អ្នកប្តូរភេទជាស្ត្រីស្ថិតក្នុងក្រុមអ្នកស្រឡាញ់ភេទដូចគ្នាដែលងាយរងគ្រោះបំផុតពីការរើសអើង អំពើហិង្សា និងការប្រមាថ។ គម្រោងឃ្លាំមើលឃាតកម្មទៅលើអ្នកប្តូរភេទបានរាយការណ៍ថាអ្នកប្តូរភេទ និងជនមានភេទចម្រុះចំនួន ១.៧៣១ នាក់ ត្រូវបានធ្វើឃាតនៅក្នុងប្រទេសចំនួន ៦០ ដោយសារតែមូលហេតុនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវទំនោរយេនឌ័រ ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ ២០១៤។[2]

ទោះបីជាអត្តសញ្ញាណ និងការបង្ហាញលក្ខណៈយេនឌ័រត្រូវបានដាក់បញ្ចូលកាន់តែច្រើនឡើង និងនិយាយដោយប្រយោលនៅក្នុងពាក្យគន្លឹះក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ព្រមទាំងច្បាប់ជាតិជុំវិញពិភពលោកក្តី ក៏ការមិនដាក់បញ្ចូលនៅក្នុងទិដ្ឋភាពច្បាប់ សង្គម និងសេដ្ឋកិច្ច និងការមិនយកចិត្តទុកដាក់ដល់ក្រុមអ្នកប្តូរភេទនៅតែប៉ះពាល់ដល់គ្រប់បញ្ហាក្នុងជីវិតរបស់ពួកគាត់ទាំងអស់។ ដោយគ្មានកិច្ចគាំពារពីច្បាប់ អ្នកប្តូរភេទជាជនងាយរងគ្រោះយ៉ាងខ្លាំង ហើយតែងតែប្រឈមនឹងអំពើហិង្សា និងការរើសអើងដែលកើតចេញពីបុរេនិច្ឆ័យប្រពៃណី និងកង្វះការទទួលយក ឬការយល់ដឹងនៅក្នុងសង្គមជុំវិញអត្តសញ្ញាណយេនឌ័រខុសៗគ្នា។ ផលប៉ះពាល់ទាំងនេះមានការកើនឡើងជាលំដាប់ ហើយផលប៉ះពាល់ខ្លះត្រូវបានមើលឃើញដោយបើកចំហ ដូចជាការឆ្លងមេរោគអេដស៍ក្នុងចំណោមអ្នកប្តូរភេទជាស្ត្រីនៅក្នុងតំបន់ជាច្រើននៅលើពិភពលោក។[3] ផលប៉ះពាល់ខ្លះទៀតដូចជាជំងឺថប់អារម្មណ៍ ការបាក់ទឹកចិត្ត និងការឱ្យតម្លៃខ្លួនទាបមិនសូវត្រូវបានមើលឃើញនោះទេ។

## ១. ១ តើពាក្យថា "អ្នកប្តូរភេទ" មានន័យដូចម្តេច?

វាក្យស័ព្ទ "អ្នកប្តូរភេទ" ត្រូវបានប្រើប្រាស់ជាប្រចាំបំផុតដើម្បីពិពណ៌នាចំពោះបុគ្គលទាំងឡាយណាដែលធ្លាប់មានអារម្មណ៍មិនស្របទៅនឹងភេទដែលគាត់មានមកពីកំណើត និងអត្តសញ្ញាណយេនឌ័ររបស់ពួកគាត់ ហើយអារម្មណ៍ដែលដក់ជាប់យ៉ាងជ្រៅអំពីយេនឌ័ររបស់ពួកគាត់។ "អ្នកប្តូរភេទជាស្ត្រី" គឺជាបុគ្គលដែលមានភេទជាបុរសពីកំណើត ប៉ុន្តែកំណត់សញ្ញាណ និងតែងតែរស់នៅក្នុងសភាពជាស្ត្រី។ ជាធម្មតាក្រុមអ្នកប្តូរភេទបង្ហាញខ្លួនឯងក្នុងរូបភាពខាងក្រៅទៅតាមអត្តសញ្ញាណយេនឌ័ររបស់ពួកគាត់ជាជាងបង្ហាញខ្លួនតាមភេទ

[2] "គម្រោងឃ្លាំមើលឃាតកម្មទៅលើអ្នកប្តូរភេទ - "ការធ្វើបច្ចុប្បន្នភាពលើ IDAHOT ឆ្នាំ២០១៥)"ថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៥ របស់អង្គការ Trans Respect Versus Transphobia Worldwide

[3] កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ "សុខភាព និងសិទ្ធិមនុស្សរបស់អ្នកប្តូរភេទ" នៃឯកសារពិភាក្សា) ឆ្នាំ ២០១៣ (ទំព័រទី ២ )

ដែលពួកគាត់មានពីកំណើត ហើយភាគច្រើនក៏សម្រេចផ្លាស់ប្តូរភេទជាអចិន្ត្រៃយ៍ដោយរើសយកការវះតាមបែបវេជ្ជសាស្ត្រកាត់ ដែលស្គាល់ថាជាការកំណត់យេនឌ័រម្តងទៀត។ នៅក្នុងប្រទេសណាដែលអាចធ្វើទៅបាន ក្រុមអ្នកប្តូរភេទក៏អាចស្វែងរកការផ្លាស់ប្តូរភេទដោយស្របច្បាប់នៅលើឯកសារផ្លូវការផងដែរ។ ដោយមនុស្សជាច្រើនយល់ឃើញថាមាន "ក្រុមប្រភេទទី៣" ដែលទស្សនៈយេនឌ័រដែលមានតែពីរភេទគឺបុរសនិងស្ត្រីនោះលែងសំខាន់ទៀតហើយ ដោយសារតែទស្សនៈយេនឌ័រនេះអាចនឹងត្រូវបត់បែន និងបកស្រាយជាភេទផ្សេងៗទៀត។ ពាក្យថា "អ្នកប្តូរភេទ" អាចត្រូវបានបកស្រាយថាជាអត្តសញ្ញាណភេទក្នុងន័យទូលាយ និងការបង្ហាញផ្ទាល់ខ្លួនដែលសង្គមបកស្រាយថាមានលក្ខណៈជាបុរស ឬស្ត្រីច្រើនជាង។ជាច្រើនទសវត្សរ៍ចុងក្រោយនេះ ការវិវឌ្ឍន៍ជាច្រើននៃទស្សនៈវិស័យជុំវិញបញ្ហាសិទ្ធិមនុស្សដែលបានជំរុញឱ្យសន្ទុះចលនាសង្គមដឹកនាំដោយក្រុមអ្នកស្រឡាញ់ភេទដូចគ្នានាំឱ្យមានទំនោរកើនឡើងនៃសកម្មភាពតាមផ្លូវច្បាប់ និងលិខិតគតិយុត្តជាច្រើនដែលទទួលស្គាល់អត្តសញ្ញាណយេនឌ័រជាច្រើនប្រភេទ។ ការទទួលស្គាល់ភាពខុសគ្នារវាងភេទ និងយេនឌ័រ គឺជាកត្តាសំខាន់នៅក្នុងការដោះស្រាយកង្វល់ និងការញែកឱ្យដាច់ពីគ្នា ដែលអាចកើតចេញពីអត្តសញ្ញាណយេនឌ័ររបស់នរណាម្នាក់ ដែលមិនស្របជាមួយអត្តសញ្ញាណយេនឌ័ររបស់បុគ្គលនោះដែលមានមកពីកំណើត។

## ១.២ បរិបទកម្ពុជា - ប្រវត្តិសាស្ត្រ វប្បធម៌ និងសង្គម

ទោះបីជាមិនមានស្ថិតិច្បាស់លាស់អំពីចំនួនអ្នកប្តូរភេទជាស្ត្រីនៅក្នុងប្រទេសកម្ពុជា ក្រុមអ្នកស្រាវជ្រាវស្តីពីមេរោគហ៊ីវ/ជម្ងឺអេដស៍ បានប៉ាន់ប្រមាណថាអ្នកប្តូរភេទជាស្ត្រីមានចំនួន ៣០៣០ នាក់ ដោយផ្អែកលើការស្រាវជ្រាវដែលបានធ្វើឡើងនៅក្នុងបណ្តាខេត្តចំនួនប្រាំពីរ។[4] តួលេខទាំងនេះទាក់ទងទៅនឹងបុគ្គលដែលបានកំណត់អត្តសញ្ញាណថាជាអ្នកប្តូរភេទ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាស្ទើរតែមួយភាគបី (ស្មើនឹង២៩%) នៃអ្នកស្រឡាញ់ភេទដូចគ្នា មិនដែលបង្ហាញពីស្ថានភាពអ្នកស្រឡាញ់ភេទដូចគ្នារបស់ពួកគេទៅនរណាម្នាក់ ដែលធ្វើឱ្យកាន់តែលំបាកក្នុងការប៉ាន់ប្រមាណចំនួនអ្នកប្តូរភេទជាស្ត្រី នៅក្នុងប្រទេសកម្ពុជា។[5]

តាមប្រពៃណី ជំនឿពុទ្ធសាសនាដែលប្រទេសកម្ពុជាប្រតិបត្តិតាម បានអះអាងថាសាសនានេះជាទូទៅផ្តល់ការអធ្យាស្រ័យដល់អត្តសញ្ញាណយេនឌ័រចម្រុះបែបនៅកម្ពុជាបើធៀបជាមួយសាសនាដទៃទៀតក្នុងពិភពលោក។ ផ្នែកនេះនឹងពិនិត្យទៅលើការយល់ឃើញកន្លងមកចំពោះក្រុមអ្នកប្តូរភេទនៅក្នុងសង្គមខ្មែរ និងផលប៉ះពាល់ដែលអ្នកប្តូរភេទជាស្ត្រីជួបប្រទះនាបច្ចុប្បន្ននេះ ។

---

[4] មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ជម្ងឺសើស្បែក និងកាមរោគ និង គំរូនៃការរីករាលដាលជំងឺអេដស៍ នៅប្រទេសកម្ពុជាឆ្នាំ ២០១៤

[5] សហគមន៍ឥន្ទធនូ(រ៉ក)របាយការណ៍ស្រាវជ្រាវស្តីពីមតិយោបល់ ឥរិយាបថ និងអត្តចរិកចំពោះក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា" ឆ្នាំ២០១៥

## ១.២.១ ទស្សនៈបែបវប្បធម៌ និងប្រវត្តិសាស្ត្រនៃអត្តសញ្ញាណយេនឌ័រនៅកម្ពុជា

ការស្រាវជ្រាវនៅអាស៊ីអាគ្នេយ៍ និងជាពិសេសនៅក្នុងប្រទេសកម្ពុជា បានបង្ហាញថាមានអត្តសញ្ញាណយេនឌ័រជាច្រើនប្រភេទនៅទូទាំងប្រទេស និងអះអាងថាការយល់ដឹងពីយេនឌ័រនៅកម្ពុជាមានលក្ខណៈរលូនជាងតំបន់ជាច្រើនទៀតនៅក្នុងពិភពលោក។

ការស្រាវជ្រាវអះអាងថាប្រជាជននៅតំបន់អាស៊ីអាគ្នេយ៍ក៏ទំនងជាមានការយល់ដឹងតិចតួចពីបញ្ហាយេនឌ័រក្នុងលក្ខខណ្ឌតែពីររវាងបុរស/ស្ត្រី និងទំនងជាទទួលយកសកម្មភាពភេទដូចគ្នា (ជាពិសេស ក្នុងចំណោមបុរស) ថាជារឿងធម្មតា។[6] សហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) ដែលជាអង្គការគាំទ្រក្រុមអ្នកស្រឡាញ់ភេទដូចគ្នាក្នុងស្រុករាយការណ៍ថា ថ្វីបើគ្មានពាក្យក្នុងភាសាខ្មែរសម្រាប់ពន្យល់ពីឥរិយាបថអ្នកស្រឡាញ់ភេទដូចគ្នា ស្រឡាញ់ភេទផ្ទុយគ្នា ស្រឡាញ់ភេទទាំងពីរ ប្រុសស្រឡាញ់ប្រុស ឬស្រីស្រឡាញ់ស្រីដោយផ្ទាល់ មានការប្រើវាក្យស័ព្ទជាង ២០០ បែបសម្រាប់សម្គាល់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅតាមខេត្តទូទាំងប្រទេស។[7] ជារឿយៗ វាក្យស័ព្ទ "សក់ខ្លី" ក៏ត្រូវបានប្រើសំដៅលើមនុស្សប្រុសស្រឡាញ់ប្រុស និងវាក្យស័ព្ទ "សក់វែង" (ឬ *ស្រីស្រស់*) ត្រូវបានប្រើសំដៅលើអ្នកប្តូរភេទជាស្ត្រី។[8] ពាក្យថា "ខ្ទើយ" ដែលជាទម្លាប់សំដៅលើមនុស្សភេទទី៣ ឬយេនឌ័រទី៣ បច្ចុប្បន្នត្រូវបានយល់ជាទូទៅថាជាពាក្យប្រមាថដល់អ្នកប្តូរភេទជាស្ត្រី។[9]

ទោះជាយ៉ាងណាក្តី ផលប៉ះពាល់បច្ចុប្បន្នពីភាពចម្រុះនៃយេនឌ័រដែលកើតមាននៅកម្ពុជា និងអាស៊ីអាគ្នេយ៍មិនគួរត្រូវនិយាយពន្លើសនោះទេ។ តម្លៃគ្រួសារតាមបែបប្រពៃណីដែលលើកទឹកចិត្តឱ្យមានការរៀបការ និងមានកូន បានដក់ជាប់ក្នុងអារម្មណ៍យ៉ាងជ្រៅ ហើយជារឿយៗមិនស៊ីសង្វាក់គ្នាជាមួយនឹងអត្តសញ្ញាណអ្នកប្តូរភេទ។ ខណៈដែលសង្គមខ្មែរអាចមានភាពអត់ឱនចំពោះឥរិយាបថអ្នកស្រឡាញ់ប្រុសដូចគ្នា ជាពិសេសនៅពេលបែងចែកឱ្យដាច់ពីគ្នា និងមិនប៉ះពាល់ដល់រចនាសម្ព័ន្ធគ្រួសារ បទពិសោធន៍របស់អ្នកស្រឡាញ់ស្រីដូចគ្នា និងអ្នកប្តូរភេទជាស្ត្រី និងបុរសប្តូរភេទជារឿយៗជួបនូវការរារាំងជាច្រើន។

នៅក្នុងការស្ទង់មតិទ្រង់ទ្រាយធំអំពីក្រុមអ្នកស្រឡាញ់ភេទដូចគ្នា និងស្រឡាញ់ភេទផ្ទុយគ្នានៅកម្ពុជានៅក្នុងឆ្នាំ២០១៥ រកឃើញថាអ្នកផ្តល់សម្ភាសន៍ជាមនុស្សប្តូរភេទជាស្ត្រីស្ទើរតែទាំងអស់ស្មើនឹង (៩៧%) កាន់សាសនាព្រះពុទ្ធ។ នៅក្នុងការស្ទង់មតិដដែលនេះ អ្នកគាំទ្រក្រុមអ្នកស្រឡាញ់ភេទដូចគ្នាចំនួនមួយភាគបី និងអ្នកផ្តល់សម្ភាសន៍ជាក្រុមអ្នកស្រឡាញ់ភេទដូចគ្នាចំនួន ៤០% ដែលកាន់សាសនាព្រះពុទ្ធបានឆ្លើយថា

---

[6] អ៊ឺស ប៉ាបារ៉ា (Earth, Barbara) "ការធ្វើពិពិធកម្មយេនឌ័រ៖ អត្តសញ្ញាណអ្នកប្តូរភេទពីបុរសមកជាស្រី និងកម្មវិធីជម្ងឺអេដស៍នៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា"។ យេនឌ័រ និងការអភិវឌ្ឍ ១៤:២ ទំព័រពី ២៥៩ ដល់ ២៧១ ) ឆ្នាំ ២០០៦ (ទំព័រ២៦០ ) ។

[7] សហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) "របាយការណ៍ស្រាវជ្រាវស្តីពីមតិយោបល់ ឥរិយាបថ និងអត្តចរិកចំពោះក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា" ឆ្នាំ ២០១៥ ។

[8] អ៊ឺស ប៉ាបារ៉ា (Earth, Barbara) "ការធ្វើពិពិធកម្មយេនឌ័រ៖ អត្តសញ្ញាណអ្នកប្តូរភេទពីបុរសមកជាស្រី និងកម្មវិធីជម្ងឺអេដស៍នៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា" យេនឌ័រ និងការអភិវឌ្ឍ ១៤:២ ទំព័រពី ២៥៩ ដល់ ២៧១ ឆ្នាំ ២០០៦ ( ទំព័រ២៦១ ) ។

[9] ដូចលេខយោងខាងលើ ទំព័រ២៦០ ។

ប្រសិនបើព្រះពុទ្ធនៅមានព្រះជន្មដល់សព្វថ្ងៃ ពួកគាត់គិតថាទ្រង់នឹងមានពុទ្ធដិកា *"ឱ្យក្រុមអ្នកស្រឡាញ់ភេទដូចគ្នាធ្វើអ្វីតាមដែលពួកគេចង់ធ្វើទៅ"*។[10] តាមពិត ពុទ្ធសាសនាឱ្យតម្លៃការរៀបការនិងការបង្កកំណើតទាបជាងសាសនាដទៃនៅលើពិភពលោកយើងនេះ ដោយចាត់ទុកថាការរៀបការ និងការបង្កកំណើតជារឿងល្អប្រសិនបើវាផ្តល់នូវក្តីស្រឡាញ់ និងការគោរព ប៉ុន្តែវាជារឿងអាក្រក់ ប្រសិនបើវាបង្កឱ្យមានការឈឺចាប់និងជម្លោះ។ ភាពនៅលីវត្រូវបានគោរពយ៉ាងជ្រាលជ្រៅពីសំណាក់អ្នកដែលស្វែងរកការត្រាស់ដឹង ។ ដូច្នេះគេឃើញថាជំទាស់ចំពោះអ្នកប្តូរភេទ ដោយសារមូលហេតុទស្សនៈសាសនាឬស្ថាប័នសាសនានៅកម្ពុជាមានតិចតួចជាងទស្សនៈជំទាស់ដែលកើតចេញពីទំនៀមទំលាប់ប្រពៃណីនៅក្នុងសង្គម។ ដែលខុសពីការប្រៀនប្រដៅរបស់ព្រះពុទ្ធដោយបានឱ្យតម្លៃខ្ពស់ទៅលើការរៀបការនិងកូនចៅ។

ប្រហែលជាមួយផ្នែកមួយដោយសារតែមិនមានការជំទាស់ពីសាសនា និងពីស្ថាប័នសាសនាបើមានបញ្ហាជាច្រើនដែលក្រុមអ្នកស្រឡាញ់ភេទដូចគ្នាបានជួបប្រទះនៅកម្ពុជាក៏នៅតែមានសេចក្តីថ្លែងការណ៍គាំទ្រជាច្រើនពីសំណាក់បុគ្គលសាធារណៈដែលមានឥទ្ធិពលនៅកម្ពុជា រួមទាំងព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងនាយករដ្ឋមន្ត្រី ហ៊ុន សែន អំពីបញ្ហាក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាកំពុងលេចចេញកាន់តែច្បាស់នៅកម្ពុជា ដោយសារតែចលនាសិទ្ធិរបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នាដែលទើបតែចាប់កំណើតមែន ប៉ុន្តែមានសន្ទុះស្វាហាប់និងមានការប្តេជ្ញាចិត្តខ្ពស់។ ការប្រារព្ធសប្តាហ៍មោទនភាពអ្នកស្រឡាញ់ភេទដូចគ្នាដំបូងនៅក្នុងប្រទេសប្រព្រឹត្តទៅនៅឆ្នាំ២០០៣ ហើយចាប់តាំងពីឆ្នាំ២០០៩ មកសកម្មភាពពេញមួយសប្តាហ៍បានពង្រីកវិសាលភាពក្រៅពីរាជធានីភ្នំពេញចេញទៅតាមខេត្តបាត់ដំបង និងសៀមរាប។ អាជ្ញាធរមូលដ្ឋាន និងមេឃុំ/ចៅសង្កាត់ជាច្រើនក៏បានគាំទ្រសកម្មភាពមោទនភាពនេះខ្លះដែរ។

---

[10] សហគមន៍ឥន្ទធនូ(រ៉ក) "របាយការណ៍ស្រាវជ្រាវស្តីពីមតិយោបល់ ឥរិយាបថ និងអត្តចរិកចំពោះក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា" ឆ្នាំ ២០១៥ ។

## ២. គោលបំណង វិសាលភាព និងវិធីសាស្ត្រ

គោលបំណងនៃរបាយការណ៍នេះ គឺចង់បង្ហាញពីភស្តុតាងអំពីការរីកសាយភាយនៃការរើសអើងលើអ្នកប្តូរភេទជាស្ត្រីនៅតាមទីប្រជុំជននៅក្នុងព្រះរាជាណាចក្រកម្ពុជាពីសំណាក់ស្ថាប័នឯកជន (ដូចជា គ្រួសារ មិត្តភក្តិ មនុស្សមិនស្គាល់គ្នា និយោជក) និងស្ថាប័នរដ្ឋ (ដូចជា នគរបាល សាលារៀន មណ្ឌលថែទាំសុខភាព) និង ផ្តល់ជាអនុសាសន៍សំខាន់ៗទាក់ទិននឹងសកម្មភាពដែលត្រូវធ្វើ ដើម្បីដោះស្រាយបញ្ហាដែលបានកត់សម្គាល់រួច។ ខណៈដែលការស្រាវជ្រាវពីមុននៅកម្ពុជាបានផ្តោតលើសហគមន៍ក្រុមអ្នកស្រឡាញ់ភេទដូចគ្នាជារួម ឬ ផ្តោតតែទៅលើសហគមន៍អ្នកប្តូរភេទដោយឈរលើទស្សនៈចង្អៀតជាងនេះជុំវិញអ្នករកស៊ីផ្លូវភេទ ឬមេរោគហ៊ីវ/អេដស៍ របាយការណ៍នេះនឹងផ្តោតលើអ្នកប្តូរភេទជាស្ត្រីដោយផ្អែកលើទស្សនៈទូលាយផ្អែកសិទ្ធិមនុស្ស។ ដោយផ្អែកលើទំនាក់ទំនងរបស់គម្រោងសូជីរបស់ ម.ស.ម.ក ជាមួយនឹងសហគមន៍អ្នកប្តូរភេទនៅកម្ពុជា រួមជាមួយនឹងការសិក្សាស្រាវជ្រាវលើការស្រាវជ្រាវមុនៗ ម.ស.ម.ក ចាត់ទុកការប្រមាថលើអ្នកប្តូរភេទជាស្ត្រីពីសំណាក់ស្ថាប័នរដ្ឋថាជាបញ្ហាដោយឡែកនៅកម្ពុជា ហើយដូច្នេះរបាយការណ៍នេះផ្តោតយ៉ាងស៊ីជម្រៅទៅលើការរើសអើងលើអ្នកប្តូរភេទជាស្ត្រីពីសំណាក់នគរបាលនិងអាជ្ញាធរ។ បន្ថែមលើនេះទៀត វិធីសាស្ត្រនេះធ្វើទៅដោយឈរលើគោលការណ៍ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលទទួលស្គាល់រដ្ឋថាជាអ្នកដែលមានភារកិច្ចចម្បងក្នុងការធានាការការពារសិទ្ធិមនុស្ស។ មុនពេលធ្វើការស្រាវជ្រាវដើម្បីសរសេររបាយការណ៍នេះ ម.ស.ម.ក បានទទួលរបាយការណ៍ជាច្រើនលើកឡើងថាមន្ត្រីនគរបាលនិងអាជ្ញាធរផ្សេងទៀត គឺជាអ្នកប្រព្រឹត្តអំពើរើសអើង និងការប្រមាថលើក្រុមអ្នកស្រឡាញ់ភេទដូចគ្នាជាញឹកញាប់ ជាឧទាហរណ៍ របាយការណ៍ឆ្នាំ២០១៥ របស់ ម.ស.ម.ក ស្តីពីការសម្លុតក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀន បានរកឃើញថាអ្នកផ្តល់សម្ភាសន៍ចំនួន ២០,៥១% ធ្លាប់ត្រូវបាននគរបាលមាក់ងាយដោយសារតែនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័ររបស់ពួកគាត់។[11] របាយការណ៍ផ្សេងទៀតស្តីពីអ្នកប្តូរភេទជាស្ត្រីនៅក្នុងការងាររកស៊ីផ្លូវភេទក៏បានរកឃើញស្រដៀងគ្នាអំពីអត្រារើសអើង ការបំពាន និងអំពើហិង្សាលើផ្លូវភេទខ្ពស់ទៅលើអ្នកប្តូរភេទជាស្ត្រីពីសំណាក់អាជ្ញាធរ។[12] កាលពីខែសីហា ឆ្នាំ២០១៥ មន្ត្រីខណ្ឌដូនពេញម្នាក់នៅក្នុងរាជធានីភ្នំពេញបានលើកឡើងនៅក្នុងសារព័ត៌មានថា"*មន្ត្រីសង្កាត់បាន រួមគ្នាព័ទ្ធចាប់មនុស្សចំនួន ៥១ នាក់ រួមទាំងអ្នករកស៊ីផ្លូវភេទ ខ្ទើយ និងជន*

---

[11] ម.ស.ម.ក "របាយការណ៍ស្តីពីការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀនក្នុងកម្ពុជា" ឆ្នាំ២០១៥ ។

[12] ឧទាហរណ៍ អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ការមើលលម្អិតបន្ថែមពី៖ ការឃុំខ្លួនតាមអំពើចិត្ត និងការបំពានផ្សេងទៀតលើអ្នករកស៊ីផ្លូវភេទនៅកម្ពុជា" ឆ្នាំ ២០១០ និង ដេវីឌ ចារ៉េត (Davis, Jarrett) និងឯកសារ "លើសពីយេនឌ័រ ៖ ការសិក្សាមូលដ្ឋានពីអ្នកប្តូរភេទនៅក្នុងឧស្សាហកម្មរកស៊ីផ្លូវភេទនៅរាជធានីភ្នំពេញ" និងអ្នកដទៃច្រើនទៀត ឆ្នាំ២០១៤ ។

*អានាថា* ដោយហៅពួកគាត់ថាជា *"ការអាម៉ាសដល់សង្គមជាតិ"* និងបានពោលបញ្ជិតបញ្ចៀងខ្លាំងៗថាអ្នកប្តូរភេទជាស្ត្រីជាគោលដៅសំខាន់របស់នគរបាល។[13]

## ២.១ វិធីសាស្ត្រ

ដើម្បីទទួលបានការយល់ដឹងពីស្ថានភាពបច្ចុប្បន្នរបស់អ្នកប្តូរភេទជាស្ត្រីនៅកម្ពុជា ការសិក្សាស្រាវជ្រាវទៅលើឯកសារពាក់ព័ន្ធនិងសារតារសង្គម ប្រវត្តិសាស្ត្រ និងវប្បធម៌របស់អ្នកប្តូរភេទស្ត្រី និងទស្សនៈជុំវិញបញ្ហារបស់អ្នកប្តូរភេទនៅកម្ពុជា អាស៊ីអាគ្នេយ៍ និងលើពិភពលោកត្រូវបានលើកយកមកសិក្សា។ ការសិក្សាស្រាវជ្រាវនេះក៏ផ្តោតលើការយល់ដឹងជាសកលអំពីអត្តសញ្ញាណយេនឌ័រដែលបានចែងនៅក្នុងច្បាប់ជាតិ និងអន្តរជាតិ។

ការស្រាវជ្រាវបែបគុណវិស័យត្រូវបានធ្វើឡើងក្នុងទម្រង់ជាការស្ទង់មតិដែលមាន ១៥២ សំណួរ និងត្រូវបានព្រាងឡើងដោយផ្អែកលើមូលដ្ឋានការស្រាវជ្រាវលើឯកសារមុន និងបទពិសោធន៍របស់ ម.ស.ម.ក ធ្វើការទៅលើដែលជាបញ្ហារបស់អ្នកប្តូរភេទ ។ ការស្ទង់មតិត្រូវបានរៀបចំឡើងដើម្បីប្រមូលទិន្នន័យជាបរិមាណអំពីការប្រមាថនិងការរើសអើង និងរួមបញ្ចូលសំណួរសំយោគ និងបែបប្រជាសាស្ត្រ ព្រមទាំងសំណួរសួរអំពីទស្សនៈ និងអត្តសញ្ញាណផ្ទាល់ខ្លួន លក្ខខណ្ឌរស់នៅ ការអប់រំ ការងារ ការថែទាំសុខភាព ការទទួលបានការគាំទ្រ និង ការរើសអើងក៏ដូចជាការបំពាននៅក្នុងស្ថានភាពផ្សេងៗគ្នារួមទាំងនៅតាមផ្ទះ តាមដងផ្លូវ ពីសំណាក់អ្នកផ្តល់សេវា អាជ្ញាធរ និងនគរបាល។ ជាសរុបមានអ្នកផ្តល់សម្ភាសន៍ចំនួន ១៣៥ នាក់ (៦៨ នាក់នៅរាជធានីភ្នំពេញ ២៥ នាក់នៅក្នុងក្រុងបាត់ដំបង ២៣ នាក់នៅក្នុងក្រុងសៀមរាប និង ១៩ នាក់នៅក្នុងក្រុងព្រះសីហនុ) បានឆ្លើយសំណួរតាមរយៈការស្ទង់មតិ។ អ្នកស្រាវជ្រាវរបស់ ម.ស.ម.ក បានបំពេញបេសកកម្ម នៅតាមតំបន់គោលដៅ៣ខេត្តជាច់ដោយឡែកកាលពីខែមេសា ឆ្នាំ២០១៦ ក្នុងការប្រមូលបានទិន្នន័យនៅរាជធានីភ្នំពេញ ក្រុងសៀមរាប ក្រុងបាត់ដំបង និងក្រុងព្រះសីហនុ។ ទីក្រុងទាំងនេះត្រូវបានជ្រើសមកធ្វើជាតំបន់គោលដៅគឺដោយសារតែជាទីក្រុងធំៗនៅកម្ពុជាដែលមានបណ្តាញក្រុមអ្នកស្រឡាញ់ភេទដូចគ្នាបង្កើតបានល្អបំផុត។ ការស្ទង់មតិធ្វើឡើងដោយមានការលាយគ្នារវាងទីតាំងឯកជននិងសាធារណៈ ដរាបណាអ្នកផ្តល់សម្ភាសន៍មានអារម្មណ៍កក់ក្តៅនឹងបរិស្ថានជុំវិញ។ នៅតាមតំបន់គោលដៅនីមួយៗ គម្រោងបានប្រើទំនាក់ទំនងនៅក្នុងបណ្តាញអង្គការអ្នកស្រឡាញ់ភេទដូចគ្នាដើម្បីស្វែងរកសមាជិកសហគមន៍គោលដៅ និងសម្របសម្រួលការស្ទង់មតិជាមួយនឹងបុគ្គលដែលស្គាល់ថាជាអ្នកប្តូរភេទជាស្ត្រី ប៉ុន្តែគ្មានលក្ខណៈវិនិច្ឆ័យអ្វីផ្សេងពីនេះទេ។ ការស្ទង់មតិដែលមានទាំងទម្រង់សំណួរពហុជ្រើសរើសនិងសំណួរបើទនេះធ្វើឡើងក្នុងលក្ខណៈជាកិច្ចសម្ភាសន៍ដែលជាការធ្វើឡើងក្នុងរូបភាពជាការសន្ទនាគ្នាទៅវិញទៅមក។ ក្នុងហេតុផលក្រមសីលធម៌ អ្នកស្រាវជ្រាវរបស់ ម.ស.ម.ក មិនបានធ្វើការស្ទង់មតិជាមួយនឹងអ្នកផ្តល់សម្ភាសន៍ដែលសង្ស័យថាមិនអាចផ្តល់ការយល់ព្រម

---

[13] ប៊ិន សុឃៀន "សាលាក្រុងមានផែនការបង្កើតមជ្ឈមណ្ឌលវិជ្ជាជីវៈថ្មីមួយចំពេលប្រតិបត្តិការបោសសម្អាតអ្នកសុំទានតាមផ្លូវថ្នល់" សារព័ត៌មានខេមបូឌាដេលី នៅលើប្រព័ន្ធអ៊ិនធើណែត ថ្ងៃទី៩ ខែសីហា ឆ្នាំ ២០១៥ ។

ដែលបណ្តាលមកពីឥទ្ធិពលប្រើប្រាស់គ្រឿងញៀន ឬជាតិស្រវឹង។ ទាំងវិធីសាស្ត្រជ្រើសរើសសំណាកតាមគោលដៅ និងសំណាកតាមបណ្តាញត្រូវបានយកមកប្រើប្រាស់ ដូចមានរៀបរាប់ខាងក្រោម។ នៅក្នុងពេលគ្រប់គ្រង់លើការស្ទង់មតិ ព័ត៌មានបន្ថែមដែលអ្នកផ្តល់សម្ភាសន៍បានផ្តល់ឱ្យ តែមិនឆ្លើយតបដោយផ្ទាល់នឹងសំណួរស្ទង់មតិត្រូវបានពន្យល់នៅលើការស្ទង់មតិដោយអ្នកស្រាវជ្រាវរបស់ ម.ស.ម.ក។

## ២.២ ដែនកំណត់

ម.ស.ម.ក បានជួបប្រទះនូវឧបសគ្គជាក់លាក់មួយចំនួននៅពេលធ្វើការស្រាវជ្រាវនេះ តែបញ្ហាទាំងអស់នេះមិនប៉ះពាល់ដល់គុណភាពនៃការប្រមូលទិន្នន័យទេ។ ដំបូងឡើយ ការស្រាវជ្រាវនេះមានគោលបំណងរួមបញ្ចូល អ្នកប្តូរភេទជាបុរស នៅក្នុងការស្រាវជ្រាវដែរ ក៏ប៉ុន្តែតាមរយៈការស្រាវជ្រាវទៅលើឯកសារមុន និងការពិភាក្សាជាមួយដៃគូសង្គមស៊ីវិលយើងបានសម្រេចថាបញ្ហាដែលអ្នកប្តូរភេទជាបុរសបានជួបប្រទះ គឺមានលក្ខណៈខុសគ្នាដាច់ពីបញ្ហាដែលអ្នកប្តូរភេទជាស្ត្រីបានជួបប្រទះ ហើយដូច្នេះគួរតែធ្វើការស្រាវជ្រាវផ្សេងដាច់ដោយឡែកតែទៅលើអ្នកប្តូរភេទជាបុរស។ មានកង្វះខាតការស្រាវជ្រាវអំពីស្ថានភាពរបស់អ្នកប្តូរភេទជាបុរសនៅកម្ពុជា ហើយ ម.ស.ម.ក សង្ឃឹមថានាពេលអនាគតនឹងមានការស្រាវជ្រាវទៅលើបញ្ហាអ្នកប្តូរភេទជាបុរសនេះ។

ដែនកំណត់មួយលើការស្រាវជ្រាវនេះគឺពេលវេលាបំពេញបេសកកម្មនៅតាមតំបន់គោលដៅ ដោយសារតែកង្វះធនធាន។ ការចុះទៅតាមខេត្តនីមួយៗប្រើពេលពី ២ ទៅ ៣ ថ្ងៃប៉ុណ្ណោះ ដែលប្រការនេះធ្វើឱ្យចំនួនអ្នកផ្តល់សម្ភាសន៍សរុបក៏មានកម្រិតដែរ។ កត្តានេះក៏បណ្តាលឱ្យមានការពឹងផ្អែកទៅលើបណ្តាញក្រុមអ្នកស្រឡាញ់ភេទដូចគ្នា (រួមទាំងបណ្តាញដែលធ្វើការលើការបង្ការការឆ្លងមេរោគហ៊ីវ/អេដស៍) ដើម្បីស្វែងរកអ្នកចូលរួមក្នុងការស្ទង់មតិនៅតាមតំបន់នីមួយៗ ជាហេតុធ្វើឱ្យក្រុមការងារមិនអាចទាក់ទងអ្នកប្តូរភេទជាស្ត្រីខ្លះ (និងអ្នកខ្លះអាចជាជនរងគ្រោះបំផុត) ដែលមិនបានទទួលការគាំទ្រពីបណ្តាញ។ ដែនកំណត់នេះអាចធ្វើឱ្យចំនួនអ្នករកស៊ីផ្លូវភេទកើនខ្ពស់ជាងចំនួនមធ្យមភាគ ដែលចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវនេះ ដោយហេតុថាអ្នករកស៊ីផ្លូវភេទទំនងជាផ្នែកមួយនៃបណ្តាញទាំងនោះ។ ក៏ប៉ុន្តែ ដែនកំណត់នេះត្រូវបានសម្រាលដោយការប្រើវិធីសាស្ត្រ "ការជ្រើសសំណាកតាមបណ្តាញ" ដែលអ្នកប្តូរភេទជាស្ត្រីដែលជាសមាជិកបណ្តាញគាំទ្រ ក៏ត្រូវជ្រើសរើសអ្នកដែលខ្លួនស្គាល់ផ្សេងទៀតឱ្យចូលរួមក្នុងការស្ទង់មតិផងដែរ។ នៅរាជធានីភ្នំពេញដែលជាទីតាំងទីស្នាក់ការរបស់ម.ស.ម.ក ដូច្នេះក្រុមស្រាវជ្រាវបានចំណាយពេលច្រើនក្នុងការបំពេញបេសកកម្មនៅតាមតំបន់គោលដៅក្នុងរាជធានីភ្នំពេញនិងសំដៅជួបបុគ្គលដែលពិបាកនឹងជួប។

ដែនកំណត់ចុងក្រោយពាក់ព័ន្ធនឹងវិសាលភាពនៃការស្រាវជ្រាវ។ ការផ្តោតរបស់ការស្រាវជ្រាវនេះ ធ្វើឡើងនៅតាមទីក្រុង និងរាជធានី ដោយសារតែមានចំនួនអ្នកប្តូរភេទជាស្ត្រីច្រើននៅតាមទីប្រជុំជន ដែលអាចឱ្យអ្នកស្រាវជ្រាវរបស់ ម.ស.ម.ក អាចធ្វើការស្ទង់មតិ បានចំនួនច្រើននៅក្នុងរយៈពេលខ្លីនិងធនធានមានកម្រិត។ ទោះជាយ៉ាងណាក្តី ម.ស.ម.ក សង្ឃឹមថាការស្រាវជ្រាវនេះអាចជាការជំរុញឱ្យមានការស៊ើបអង្កេតបន្ថែមអំពីការរើសអើង និងការយាយីលើអ្នកប្តូរភេទជាស្ត្រីនៅទូទាំងប្រទេសកម្ពុជា ។

# ៣. សិទ្ធិ និងច្បាប់ស្តីពីអ្នកប្តូរភេទ

ផ្នែកនេះនឹងបកស្រាយយ៉ាងពិស្តារអំពីក្របខណ្ឌគតិយុត្តិ ដែលមានជាធរមានក្នុងការការពារសិទ្ធិរបស់ក្រុមអ្នកប្តូរភេទក្នុងប្រទេសកម្ពុជា និងជាលក្ខណៈអន្តរជាតិ។ ផ្នែកនេះនឹងពិភាក្សាដោយសង្ខេបអំពីការអនុវត្តច្បាប់ទាំងនោះក្នុងស្ថានភាពជាក់ស្តែងផងដែរ។

## ៣.១ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ

សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស («ស.ម.ស.ស») កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ («ក.អ.ស.ព.ន») និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ («ក.អ.ស.ស.វ») ធានាសិទ្ធិស្មើគ្នាដល់ជនគ្រប់រូបទាំងអស់ដោយមិនគិតពីឋានៈ ឬបុគ្គលិកលក្ខណៈ។ មាត្រា ១ នៃ ស.ប.ស.ស.ស.ម ចែងថា "*មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ*" និងមិនអនុញ្ញាតឱ្យមាន "*ការបែងចែកបែបណាមួយ*" មានជាអាទិ៍ "*ពូជសាសន៍ ពណ៌សម្បុរ ភេទ... ឬស្ថានភាពដទៃទៀតឡើយ*"។

ការមិនរើសអើងត្រូវបានកំណត់ថា ជាគោលការណ៍មូលដ្ឋានគ្រឹះនៃលិខិតុបករណ៍នីមួយៗស្តីពីសិទ្ធិមនុស្សទាំងអស់នេះ ដោយមាត្រា ២ នៃ ក.អ.ស.ព.ន ចែងថា រដ្ឋត្រូវធានា "*បុគ្គលគ្រប់រូបដែលរស់នៅលើទឹកដី និងស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួននូវសិទ្ធិ...ដោយគ្មានការបែងចែកណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម កំណើត ឬស្ថានភាពដទៃៗទៀតឡើយ*"។ ការរៀបរាប់នេះមិនមែនមានតែប៉ុន្មឹងទេ ហើយមូលដ្ឋាននៃការរើសអើងមានលក្ខណៈបើកទូលាយយ៉ាងជាក់លាក់ពីសំណាក់អ្នកធ្វើសេចក្តីព្រាងសន្ធិសញ្ញា ដើម្បីអាចបញ្ចូលប្រភេទផ្សេងៗទៀតបាន ដូចជានិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។[14] គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់អង្គការសហប្រជាជាតិ បានធ្វើការកត់សម្គាល់ថា "*ស្ថានភាពដទៃៗទៀត*" ដែលយោងតាមមាត្រា ២ នៃ ក.អ.ស.ស.វ រួមបញ្ចូលទាំងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រផងដែរ។[15]

ដូចនេះ តាមទ្រឹស្តី កាតព្វកិច្ចផ្លូវច្បាប់របស់រដ្ឋក្នុងការគោរព និងការពារសិទ្ធិមនុស្សរបស់ក្រុមអ្នកប្តូរភេទ ត្រូវបានបង្កើតយ៉ាងត្រឹមត្រូវនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ស្របជាមួយនឹងការយល់ដឹងកើនឡើងពីបញ្ហាក្រុមអ្នកស្រឡាញ់ភេទដូចគ្នាជាសាកល និងចលនាតស៊ូមតិកើនឡើងកាន់តែសកម្ម ស្ថាប័នគ្រប់គ្រងសន្ធិ

---

[14] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) "ច្បាប់ និងការអនុវត្តរើសអើង និងអំពើហិង្សាលើបុគ្គលដោយមូលហេតុនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ" (A/HRC/19/41) (ឆ្នាំ២០១១ ទំព័រទី ១៤)

[15] ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ លេខ ២០ ស្តីពី "ការមិនរើសអើងនៅក្នុងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌" កថាខណ្ឌ ២ មាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (E/C.12/GC/20) (ឆ្នាំ ២០០៩)

សញ្ញាសិទ្ធិមនុស្សបានព្យាយាមឱ្យមានការរួមបញ្ចូលការការពារច្បាស់លាស់ជាងនេះសម្រាប់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងច្បាប់អន្តរជាតិ ដើម្បីធានាថារដ្ឋមានកាតព្វកិច្ចការពារបុគ្គលគ្រប់រូបពីការរើសអើងដោយមូលហេតុអត្តសញ្ញាណយេនឌ័រ។ ចំណុចដែលជាប់ពាក់ព័ន្ធជាពិសេសទៅនឹងរបាយការណ៍នេះ គឺថានៅឆ្នាំ២០១១ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានកត់សម្គាល់ថា ហេតុដែលមនុស្សម្នាក់ជាអ្នកប្តូរភេទមិនមែនជាការដាក់កម្រិតដល់ការទទួលបានសិទ្ធិមនុស្សជាមូលដ្ឋានពេញលេញដែលបាន ផ្តល់ឱ្យពួកគាត់នោះទេ។[16]

ប៉ុន្តែ ថ្វីបើការមិនរើសអើងដែលជាគោលការណ៍គ្រឹះនៃច្បាប់សិទ្ធិមនុស្សមានចែងនៅក្នុង ស.ប.ស.ស, ក.អ.ស.ព.ន និង ក.អ.ស.ស.វ ក៏ស្ថាប័នគ្រប់គ្រងសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ និងអង្គការផ្សេងៗទៀតកំពុងចងក្រងឯកសារពីការកើនឡើងនៃការរំលោភបំពានសិទ្ធិមនុស្សរបស់ក្រុមអ្នកប្តូរភេទ ប្រព្រឹត្តដោយរដ្ឋ និងបង្ហាញពីការខកខានរបស់រដ្ឋក្នុងការការពារសិទ្ធិមនុស្សពីការបំពានដោយភាគីទី៣ ព្រមទាំងរឹតត្បិតពីសំណាក់រដ្ឋក្នុងការធានាយ៉ាងសកម្មអំពីការទទួលបានសិទ្ធិមនុស្សជាមូលដ្ឋានរបស់ក្រុមអ្នកប្តូរភេទ។[17] កាលពីខែមិថុនា ឆ្នាំ២០១១ ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (ក្រុមប្រឹក្សាសិទ្ធិមនុស្ស) បានសម្តែង "*ក្តីបារម្ភយ៉ាងខ្លាំងអំពីអំពើហិង្សា និងការរើសអើងនៅគ្រប់តំបន់លើពិភពលោក ដែលប្រព្រឹត្តទៅលើបុគ្គលដោយសារមូលហេតុនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ*"។[18] ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក៏បានអំពាវនាវឱ្យមានការអនុវត្តច្បាប់ប្រឆាំងនឹងការរើសអើងដ៏ទូលំទូលាយដែលហាមឃាត់ការរើសអើងដោយផ្អែកលើអត្តសញ្ញាណយេនឌ័រពិត ឬតាមការយល់ឃើញជាក់ស្តែង ព្រមទាំងនិន្នាការភេទនិងភេទ។[19] ថ្មីៗនេះ ការវិវត្តជាច្រើនបានបង្ហាញពីការទទួលស្គាល់ស្តីពីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ សេចក្តីសម្រេចជាបន្តបន្ទាប់មួយទៀតត្រូវបានអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ២០១៤ ដែលបានអំពាវនាវដល់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សដើម្បីបង្ហាញរបាយការណ៍ស្តីពីការអនុវត្តដ៏ល្អបំផុតប្រឆាំងការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នា។[20] កាលពីខែកញ្ញា ឆ្នាំ២០១៥ ការចូលរួមជាសម្ព័ន្ធដែលមិនធ្លាប់មានពីមុនមកនៃអង្គភាពចម្រុះចំនួន១២ របស់អង្គការសហប្រជាជាតិក្នុងនោះរួមមាន មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ អង្គការសុខភាពពិភពលោក អង្គការ

---

[16] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) "ច្បាប់ និងការអនុវត្តរើសអើង និងអំពើហិង្សាលើបុគ្គលដោយមូលហេតុនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ " (A/HRC/19/41)ឆ្នាំ២០១១ (ទំព័រទី ១៤)

[17] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "ការកើតមកមានសេរីភាព និងសមភាព ៖ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនៅក្នុងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស" (HR/PUB/12/06 ឆ្នាំ ២០១២ ទំព័រទី១០ ។

[18] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិលេខ ១៧/១៩ ស្តីពី "សិទ្ធិមនុស្ស និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ" (A/HRC/RES/17/19) (ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០១១)

[19] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "ការកើតមកមានសេរីភាព និងសមភាព ៖ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនៅក្នុងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស" (A/HRC/19/41) ឆ្នាំ២០១២ ទំព័រទី ១០។

[20] សេចក្តីសម្រេចរបស់ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ២៧/៣២ "សិទ្ធិមនុស្ស និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ" (A/HRC/RES/២៧/៣២) ០២ ខែតុលា ឆ្នាំ២០១៤ ។

សហប្រជាជាតិសម្របសម្រួលកម្មវិធីអេដស៍ និងអង្គការពលកម្មអន្តរជាតិបានចេញសេចក្តីថ្លែងការណ៍រួមមួយ ដែលអំពាវនាវឱ្យមានវិធានការជាច្រើន ដើម្បីគាំទ្រសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា រួមមានទាំងការបង្កើតច្បាប់ក្នុងការទទួលស្គាល់ដោយស្របច្បាប់នៃអត្តសញ្ញាណយេនឌ័រនៃអ្នកប្តូរភេទ និងច្បាប់ដើម្បីហាមឃាត់ការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នា។[21] ចុងក្រោយបំផុត និងប្រហែលជាសំខាន់បំផុតនោះ នៅក្នុងខែមិថុនា ឆ្នាំ ២០១៦ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចមួយជាប្រវត្តិសាស្ត្រក្នុងការបង្កើតអ្នកជំនាញការឯករាជ្យស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រស្របតាមនីតិវិធីពិសេសរបស់ខ្លួន។[22]

គោលការណ៍យ៉កយ៉ាកាតានៃការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិស្តីពីនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រឆ្នាំ២០០៦ ខិតខំក្នុងការសម្រេចគោលបំណងឆ្ពោះទៅបញ្ចូលកិច្ចការពារអ្នកស្រឡាញ់ភេទដូចគ្នាឱ្យបានពិតប្រាកដនៅក្នុងច្បាប់ តាមរយៈការផ្តល់អនុសាសន៍ច្បាស់លាស់សម្រាប់ការអនុវត្តច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិក្នុងការដោះស្រាយបញ្ហានានាទាក់ទិននឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ។[23] ទោះបីជាគោលការណ៍ទាំងអស់នេះមិនចងជាកាតព្វកិច្ចតាមផ្លូវច្បាប់ក្តី ក៏គណៈកម្មាធិការរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ បានយោងដល់គោលការណ៍យ៉កយ៉ាកាតាជាប្រភពណែនាំ ជាពិសេសទាក់ទិននឹងការគោរពតាមនិយមន័យនៃវាក្យសព្ទដូចជា 'និន្នាការភេទ' និង 'អត្តសញ្ញាណយេនឌ័រ' ដែលត្រូវបានពិពណ៌នាថាជា "ផ្នែកមួយនៃទិដ្ឋភាពសំខាន់បំផុតក្នុងការកំណត់អត្តសញ្ញាណខ្លួនឯង សេចក្តីថ្លៃថ្នូរ និងសេរីភាព"។[24] គោលការណ៍ទី១ និងទី២ សំដៅដល់សិទ្ធិទទួលបានសិទ្ធិមនុស្សជាសាកល និងសិទ្ធិស្មើគ្នា និងគ្មានការរើសអើងចំពោះអ្នកស្រឡាញ់ភេទដូចគ្នា ដោយកំណត់ថា *"ជនគ្រប់រូបអាចប្រើប្រាស់សិទ្ធិទាំងអស់បានដោយមិនរើសអើងពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ"* និងតម្រូវឱ្យរដ្ឋ *"ចាត់វិធានការសមស្របទាំងអស់រាប់ទាំងកម្មវិធីសិក្សា និងវគ្គបណ្តុះបណ្តាល បំណងសម្រេចឱ្យបាននូវការលុបបំបាត់អាកប្បកិរិយា ឬឥរិយាបទរើសអើង ឬអន្តរាយទាំងឡាយដែលទាក់ទងនឹងគំនិតបែងចែកទាបខ្ពស់ ដល់និន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រឬការបង្ហាញនូវទំនោរយេនឌ័រ ឯណានីមួយនោះ។"*[25]

ចំពោះគណនេយ្យភាព គោលការណ៍ទី២៩ ចែងថា គ្មានការលើកលែងទោសដល់ជនល្មើសនៃការរំលោភបំពានលើក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ដែលជាប់ទាក់ទងនឹងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័ររបស់

---

[21] សេចក្តីថ្លែងការណ៍រួមរបស់អង្គការសហប្រជាជាតិ "បញ្ឈប់អំពើហិង្សានិងការរើសអើងប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរភេទ និងអន្តរភេទ ខែកញ្ញា ឆ្នាំ២០១៥ ។

[22] សូមមើល អង្គការសហប្រជាជាតិបានបង្កើតប្រវត្តិសាស្ត្រ "និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ" អង្គការឃ្លាំមើលសិទ្ធិមនុស្ស ៣០ ខែមិថុនា ឆ្នាំ ២០១៦ ។

[23] សន្និសីទរបស់ក្រុមអ្នកច្បាប់អន្តរជាតិ យ៉កយ៉ាកាតា ប្រទេសឥណ្ឌូនេស៊ី ពីថ្ងៃទី៦ ដល់ទី៩ ខែវិច្ឆិកា ឆ្នាំ២០០៦។ គោលការណ៍យ៉កយ៉ាកាតានៃការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ (ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៧)។

[24] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "ច្បាប់និងការអនុវត្តរើសអើង និងអំពើហិង្សាលើបុគ្គលដោយមូលហេតុនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ" (A/HRC/19/41) ឆ្នាំ២០១១ ទំព័រទី ៥ ។

[25] សន្និសីទរបស់ក្រុមអ្នកច្បាប់អន្តរជាតិ យ៉កយ៉ាកាតា ប្រទេសឥណ្ឌូនេស៊ី ពីថ្ងៃទី៦ ដល់ទី៩ ខែវិច្ឆិកា ឆ្នាំ២០០៦។ គោលការណ៍យ៉កយ៉ាកាតានៃការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ (ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៧) ។

ជនរងគ្រោះនោះទេ។ សិទ្ធិទទួលបានការទទួលស្គាល់យេនឌ័រស្របច្បាប់ក៏ត្រូវបានរួមបញ្ចូលផងដែរ ដោយគោលការណ៍ទី១៦ ដែលចែងថា រដ្ឋត្រូវ "*ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀតដើម្បីគោរពនិងទទួលស្គាល់ឱ្យបានពេញលេញនូវសិទ្ធិស្របច្បាប់ក្នុងការទទួលបានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ដោយផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ*"។[26]

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទរបស់អង្គការសហប្រជាជាតិ ("ស៊ី.ដ") មិនបញ្ជាក់ពីបញ្ហា អ្នកប្តូរភេទជាស្ត្រីឱ្យបានច្បាស់នោះទេ (ហើយគណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទក៏មិនបានបញ្ជាក់នៅក្នុងអនុសាសន៍ ឬការអធិប្បាយរបស់ខ្លួនដែរ) តែទោះជាយ៉ាងនេះក្តី អនុសាសន៍ជាទូទៅទី២៨ របស់គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទចែងថាទោះបីជាអត្ថបទរបស់ ស៊ី.ដ សំដៅតែទៅលើការរើសអើងផ្អែកលើភេទយ៉ាងណាក្តី ក៏អនុសញ្ញានេះបានគ្របដណ្តប់លើការរើសអើងផ្អែកលើយេនឌ័រក្នុងមូលដ្ឋាននៃ "*អត្តសញ្ញាណដែលបង្កើតតាមទស្សនៈសង្គមវិទ្យា*"។[27] ដូចនេះ យើងអាចនិយាយបានថា ស៊ី.ដ ក៏អនុវត្តលើអ្នកប្តូរភេទជាស្ត្រីផងដែរ។ ប្រទេសកម្ពុជាគឺជារដ្ឋភាគីនៃពិធីសារជម្រើសបន្ថែមនៃ ស៊ី.ដ មានន័យថាបុគ្គលអាចដាក់ពាក្យបណ្តឹងទៅគណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទបាន។

## ៣.២ ច្បាប់ជាតិ

ក្របខណ្ឌគតិយុត្តិជាតិ មិនយកចិត្តទុកដាក់ខ្លាំងទៅលើក្រុមអ្នកស្រឡាញ់ភេទដូចគ្នានោះទេ។ នេះបង្ហាញយ៉ាងច្បាស់ពីកង្វះខាត នៅក្នុងការការពារឱ្យច្បាស់លាស់ដល់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងច្បាប់ជាតិនិងគ្មានកំណត់ទោសទណ្ឌលើអ្នកដែលប្រព្រឹត្តបំពានលើក្រុមអ្នកទាំងនោះផងដែរ ព្រមទាំងគ្មានការទទួលស្គាល់តាមផ្លូវច្បាប់ពីការមានដៃគូភេទដូចគ្នាទៀតផង។ គ្មានការលើកឡើងអំពីក្រុមអ្នកប្តូរភេទនៅក្នុងច្បាប់ណាមួយនោះទេ រួមជាមួយនឹងបញ្ហាសំខាន់ៗ ដូចជាការវះកាត់កំណត់ពីយេនឌ័រ (ឬការកំណត់ភេទសារជាថ្មី) និងការប្តូរឈ្មោះដោយស្របច្បាប់ដោយឈរលើអត្តសញ្ញាណយេនឌ័រមិនត្រូវបានយកចិត្តទុកដាក់។ រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់កម្ពុជា ក៏មិនបានលើកឡើងដោយផ្ទាល់ពីពលរដ្ឋជាក្រុមអ្នកស្រឡាញ់ភេទដូចគ្នាដែរ។ មាត្រា ៣១ ធានាសិទ្ធិស្មើភាពដល់ប្រជាពលរដ្ឋខ្មែរទាំងអស់ ដោយមិនគិតពីចរិកលក្ខណៈបុគ្គលដោយបានចែងថា៖

"*ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ ដោយប្រើប្រាស់សិទ្ធិ និងសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ... ឬស្ថានភាពឯទៀតឡើយ។*"

---

[26] ដូចលេខយោងខាងលើ ។

[27] គណៈកម្មាធិការអង្គការសហប្រជាជាតិលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (CEDAW) "អនុសាសន៍ទូទៅលេខ ២៨ ស្តីពីកាតព្វកិច្ចស្នូលរបស់រដ្ឋភាគីស្របតាមមាត្រា ២ នៃ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (CEDAW/C/GC/28) (ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១០)។

នៅខណៈដែលយើងអាចលើកឡើងថា ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ស្ថិតនៅក្នុងចំណាត់ថ្នាក់ "*ស្ថានភាពឯទៀត*" ថ្វីបើក្រុមអ្នកស្រឡាញ់ភេទដូចគ្នាមិនត្រូវបានលើកឡើងនៅក្នុងក្របខណ្ឌគតិយុត្តិជាតិក្ដី ប្រទេសកម្ពុជាបានផ្ដល់សច្ចាប័នលើ ក.អ.ស.ព.ន និង ក.អ.ស.ស.វ ហើយហេតុដូច្នេះ តម្រូវឱ្យបញ្ចូលទៅក្នុងច្បាប់ជាតិនូវរាល់បទប្បញ្ញត្តិទាំងអស់ ដើម្បីធានាបាននូវសិទ្ធិដែលមានចែងនៅក្នុងសន្ធិសញ្ញា។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា ៖

"*ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ*"។[28]

មាត្រានេះត្រូវបានបកស្រាយដោយក្រុមប្រឹក្សាធម្មនុញ្ញដែលមានន័យថា សន្ធិសញ្ញាទាំងពីរនេះអនុវត្តបានដោយផ្ទាល់នៅក្នុងច្បាប់ជាតិ។[29] ដោយហេតុថា ក.អ.ស.ព.ន អាចអនុវត្តដោយផ្ទាល់បាន យើងសន្និដ្ឋានបានថា ការរើសអើងដោយឈរលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ និងការបង្ហាញលក្ខណៈយេនឌ័រ ត្រូវបានហាមឃាត់ស្របតាមច្បាប់ជាតិ ទោះបីជាការហាមឃាត់នេះខ្វះខាតច្បាប់គាំទ្រក្ដី។

[28] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។

[29] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្ដីសម្រេចលេខ 092/003/2007 ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៧ ។

# ៤. របកគំហើញពីការស្រាវជ្រាវ និងការពិភាក្សា

ផ្នែកនេះបង្ហាញពីបេកគំហើញ និងការវិភាគពីការសិក្សាស្រាវជ្រាវរបស់ ម.ស.ម.ក។ នៅក្នុងការស្ទង់មតិដែលធ្វើឡើងដោយ ម.ស.ម.ក ក្រុមធំបំផុតគឺក្រុមដែលមានអាយុចាប់ពី ២១ ដល់ ២៥ ឆ្នាំមានចំនួន ៣០,៦% ស្មើនឹង៤១ នាក់ ក្រុមដែលមានអាយុចាប់ពី ២៦ ដល់ ៣០ ឆ្នាំមានចំនួន ២៦,១២% ស្មើនឹង ៣៥ នាក់ ក្រុមដែលមានអាយុចាប់ពី ៣១ ដល់ ៣៥ ឆ្នាំមានចំនួន ១៩,៤% ស្មើនឹង ២៦ នាក់ ក្រុមដែលមានអាយុចាប់ពី ១៥ ដល់ ២០ ឆ្នាំ ចំនួន ១១,១៩% (១៥ នាក់) ក្រុមដែលមានអាយុចាប់ពី ៣៦ ដល់ ៤០ ឆ្នាំ ចំនួន ៨,២១% (១១ នាក់) និង ក្រុមដែលមានអាយុចាប់ពី ៤១ ឆ្នាំឡើងទៅមានចំនួន ៤,៤៨% (៦ នាក់)។ អ្នកផ្តល់សម្ភាសន៍សរុបចំនួន ៦៨ នាក់បានចូលរួមស្ទង់មតិនៅក្នុងរាជធានីភ្នំពេញ ចំនួន ២៥ នាក់នៅក្នុងក្រុងបាត់ដំបង ចំនួន ២៣ នាក់នៅក្នុងក្រុងសៀមរាប និងចំនួន ១៩ នាក់ នៅក្នុងក្រុងព្រះសីហនុ។

អ្នកផ្តល់សម្ភាសន៍ស្ទើរតែទាំងអស់គ្មានសញ្ញាប័ត្របរិញ្ញាប័ត្រ (មានតែ ២,២២% ប៉ុណ្ណោះដែលមាន) ហើយក៏គ្មាននរណាម្នាក់មានសញ្ញាប័ត្រអនុបណ្ឌិត ឬលើសពីនេះដែរ។ គួរឱ្យកត់សម្គាល់ មានតែ ១៤,០៧% ប៉ុណ្ណោះមានកម្រិតសិក្សាត្រឹមថ្នាក់ទី ១២ នៅវិទ្យាល័យដែលជាការទទួលបានកម្រិតអប់រំមូលដ្ឋានខ្ពស់បំផុត។ អ្នកផ្តល់សម្ភាសន៍ចំនួន ៥,៩៣% រៀនត្រឹមថ្នាក់ទី ១១ ចំនួន ១០,៣៧% រៀនត្រឹមថ្នាក់ទី ១០ ចំនួន ២២,៩៦% រៀនត្រឹមថ្នាក់ទី ៩ ចំនួន ៨,១៥% រៀនត្រឹមថ្នាក់ទី ៨ ចំនួន ៩,៦៣% រៀនត្រឹមថ្នាក់ទី ៧ ចំនួន ៣,៧% រៀនត្រឹមថ្នាក់ទី ៦ ចំនួន ១០,៣៧% រៀនត្រឹមថ្នាក់ទី ៥ និង ចំនួន ១១,១១% រៀនថ្នាក់ទី ៤ ឬទាបជាងនេះ។

អ្នកផ្តល់សម្ភាសន៍ចំនួន ៤៦ នាក់ (៣៥,១១%) បញ្ជាក់ថាការងាររកស៊ីផ្លូវភេទជាប្រភពចំណូលចម្បង ឬជាមុខរបរចម្បងរបស់ពួកគាត់។ នៅពេលសួរពីប្រភពចំណូលចម្បងក្នុងរយៈពេល ១២ ខែចុងក្រោយនេះ មានតែមុខរបរតែមួយមុខប៉ុណ្ណោះដែលបានលើកឡើងក្រៅពីការងាររកស៊ីផ្លូវភេទ (ជារឿយៗប្រកបមុខរបរទាំងពីរនេះ) គឺមុខរបរការកាត់សក់ និងថែសម្ផស្ស ដែលមានអ្នកផ្តល់សម្ភាសន៍ចំនួន ៣៩,៦៩% (៥២ នាក់) ធ្វើការនៅក្នុងឧស្សាហកម្មនេះ។ បន្ទាប់ពីតួលេខនេះ អ្នកផ្តល់សម្ភាសន៍ចំនួន ៦,១១% (៨ នាក់) ធ្វើការនៅក្នុងឧស្សាហកម្មកំសាន្ត និងចំនួន ៥,៣៤% (៧ នាក់) ធ្វើការនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការនៅតាមមូលដ្ឋាន។

## ៤.១ ការកំណត់អត្តសញ្ញាណផ្ទាល់ខ្លួន

ទោះបីជាមានអ្នកផ្តល់សម្ភាសន៍ភាគច្រើនកំណត់អត្តសញ្ញាណថាជា *ស្រីស្រស់* (ចំនួន ៤៣,៩៤%) អ្នកប្តូរភេទ (ចំនួន ២៦,៥២%) ឬមនុស្សភេទទី ៣ (ចំនួន ២៦,៥២%) ក្តី ពួកគាត់ត្រូវបានអ្នកដទៃយល់ថាជា *ខ្ទើយ* ក្នុងនោះមាន ៧១,៨៥% រាយការណ៍មកថាត្រូវបានគេហៅបែបនេះជាប្រចាំ។ ក្នុងចំណោមអ្នកផ្តល់

សម្ភាសន៍ទាំងអស់ មានអ្នកផ្តល់សម្ភាសន៍ចំនួន ៦៨,១៥% បាននិយាយថាពួកគាត់មិនសប្បាយចិត្តនឹងការហៅឈ្មោះពួកគាត់ផ្សេងនោះទេ ហើយ ៨០,៩២% ចង់ឱ្យហៅអ្វីផ្សេង ដែលភាគច្រើនបំផុតចង់ឱ្យហៅឈ្មោះរបស់ពួកគាត់តែម្តង។ ឈ្មោះដែលគេតែងតែហៅ ត្រូវបានអ្នកផ្តល់សម្ភាសន៍ចំនួន ៧១,៧៦% ចាត់ទុកថាជាការរើសអើង។




ការប្រើប្រាស់ទូលាយនៃវាក្យស័ព្ទបែបប្រមាថថាជា *ខ្ទើយ* និងការមិនទទួលយកវាក្យស័ព្ទនេះដោយអ្នកប្តូរភេទជាស្ត្រីដែលប្រើដោយមនុស្សទូទៅដើម្បីហៅពួកគាត់នោះ បង្កជាក្តីបារម្ភជាខ្លាំង និងភ្លាមៗ។ ក្តីបារម្ភនេះបង្ហាញពីកង្វះការយល់ដឹងរបស់មនុស្សទូទៅអំពីភាសា និងការដាក់ងារបែបរើសអើង ដែលនាំឱ្យមានការប្រើប្រាស់ពាក្យនេះយ៉ាងទូលំទូលាយ និងចាត់ទុកថាជាការបំពានមួយផងដែរ។ ដោយមានអ្នកប្តូរភេទជាស្ត្រីមួយចំនួនធំត្រូវបានគេហៅឈ្មោះដែលពួកគាត់ចាត់ទុកថាជាការមើលងាយ វាអាចសន្មត់បានថាការហៅបែបនេះទំនងជានាំឱ្យមានអារម្មណ៍ថាខ្លួនមិនត្រូវរាប់បញ្ចូលក្នុងសង្គម និងចាត់ទុកថា អ្នកប្តូរភេទជាស្ត្រកម្ពុជា *"អ្នកឯទៀត"*។ ហេតុដែលវាក្យស័ព្ទបែបប្រមាថគឺជាវាក្យស័ព្ទដែលប្រើទូទៅបំផុតដោយសាធារណជនទៅលើអ្នកប្តូរភេទជាស្ត្រីអាចប្រាប់យើងពីទិដ្ឋភាពពិតក្នុងនាមជាអ្នកប្តូរភេទជាស្ត្រីនៅក្នុងសង្គមខ្មែរ។

## ៤.២ ការបំពាននៅទីសាធារណៈ:

ផ្នែកនេះត្រូវបានបែងចែកជាផ្នែកតូចៗចំនួន ៣ ដើម្បីបកស្រាយពីការប្រមាថជា ៣ ប្រភេទផ្សេងគ្នាតាមពាក្យសម្តី លើរូបរាងកាយ និងផ្លូវភេទ។ របកគំហើញពីការស្រាវជ្រាវបង្ហាញថា អ្នកប្តូរភេទជាស្ត្រីទទួលរងនូវការប្រមាថទាំង ៣ ប្រភេទនេះក្នុងកម្រិតខ្ពស់ខ្លាំងពីសំណាក់ប្រជាជនទូទៅនៅតាមទីសាធារណៈ។







អ្នកចូលរួមធ្វើការស្ទង់មតិ ត្រូវបានសួរថាតើពួកគាត់ធ្លាប់ត្រូវបានគេប្រមាថដោយពាក្យសម្តី ដោយសារតែអត្តសញ្ញាណអ្នកប្តូរភេទរបស់ពួកគាត់នៅពេលដើរហើរនៅខាងក្រៅដែរឬទេ។ អ្នកផ្តល់សម្ភាសន៍ស្ទើរតែទាំងអស់ (ស្មើនឹង ៩១,៦%) បានឆ្លើយថាពួកគាត់ធ្លាប់ ហើយក្នុងចំណោមនោះមាន ២៧,៣៥% ឆ្លើយថាធ្លាប់ជួបច្រើនជាង ១០ ដងក្នុងឆ្នាំចុងក្រោយនេះ។ ការឆ្លើយតបនៅក្នុងចំណាត់ថ្នាក់ "ផ្សេង" ក៏ត្រូវបានកត់សម្គាល់ផង ដែរ ក្នុងនោះមានអ្នកផ្តល់សម្ភាសន៍ចំនួន ៣ នាក់ (២,៥៦%) ឆ្លើយថាត្រូវបានគេប្រមាថដោយពាក្យសម្តី

នៅតាមដងផ្លូវច្រើនជាង ១០០ ដងនៅអំឡុងពេល ១២ ខែចុងក្រោយនេះ។ របកគំហើញពីការស្រាវជ្រាវទាំងនេះចង្អុលបង្ហាញថាដងផ្លូវនៅកម្ពុជាមិនមែនជាកន្លែងមានសុវត្ថិភាពសម្រាប់អ្នកប្តូរភេទជាស្ត្រី និងអះអាងពីកម្រិតរើសអើងខ្ពស់ពីសំណាក់ប្រជាជនទូទៅ។






ករណីការប្រមាថដោយពាក្យសម្ដីមានកម្រិតច្រើនជាងបន្តិចលើអ្នកដែលធ្វើការរកស៊ីផ្លូវភេទដោយមានអ្នករកស៊ីផ្លូវភេទចំនួន ៩៥,៧៤% បានរាយការណ៍ពីការប្រមាថដោយពាក្យសម្ដី បើប្រៀបជាមួយនឹងអ្នកមិនរកស៊ីផ្លូវភេទដែលមានចំនួនតែ ៨៩,២៩%។[30] ក្នុងចំណោមអ្នកផ្ដល់សម្ភាសន៍ ចំនួន ៦ នាក់ (៥,១៣%) ដែលរាយការណ៍ថាបានជួបប្រទះបញ្ហានេះ ២០ ឬច្រើនដងជាងនេះ ក្នុងនោះមានចំនួន ២ នាក់ (១,៧%) ជាអ្នករកស៊ីផ្លូវភេទ។

ជាការគួរឱ្យកត់សម្គាល់ អ្នកផ្ដល់សម្ភាសន៍ចំនួន ៤២,៨៦% រាយការណ៍ថាត្រូវបានបំពានលើរាងកាយនៅតាមទីសាធារណៈ ដោយចំនួនច្រើនជាង ៩២% បានជួបហេតុការណ៍បែបនេះនៅក្នុងអំឡុងពេល ១២ ខែចុងក្រោយនេះ។ ការកើតឡើងជាទូទៅនៃការបំពានលើរាងកាយលើអ្នករកស៊ីផ្លូវភេទ (៥៩,១៨%) មានចំនួនច្រើនជាងការកើតឡើងលើអ្នកមិនរកស៊ីផ្លូវភេទ (៣៣,៣៣%) ហើយអ្នករកស៊ីផ្លូវភេទចំនួន ៧,១៤% រាយការណ៍ថាត្រូវបានបំពានលើរាងកាយច្រើនជាង ១០ ដងក្នុងអំឡុងពេល ១២ ខែចុងក្រោយនេះ។ ការកើតឡើងខ្ពស់នៃការវាយប្រហារបែបនេះបង្ហាញថារដ្ឋមិនបានបំពេញតួនាទីរបស់ខ្លួនគ្រប់គ្រាន់ក្នុងការធានាពីសន្តិសុខរបស់អ្នកប្ដូរភេទជាស្ត្រី និងរំលេចឱ្យឃើញពីតម្រូវការជាបន្ទាន់ក្នុងការបង្កើតច្បាប់ប្រឆាំងនឹងការរើសអើងដែលរួមបញ្ចូលទោសទណ្ឌដាក់លាក់លើបទស្អប់ខ្ពើម។




[30] ក្នុងគោលបំណងនៃរបាយការណ៍នេះ "អ្នករកស៊ីផ្លូវភេទ" សំដៅលើគ្រប់អ្នកផ្ដល់សម្ភាសន៍ទាំងអស់ដែលបានបញ្ជាក់ថាការងាររកស៊ីផ្លូវភេទជាប្រភពចំណូល ឬមុខរបរចម្បងរបស់ពួកគាត់។ ដូច្នេះ ស្ថិតិសម្រាប់ "អ្នកមិនរកស៊ីផ្លូវភេទ" រួមមានអ្នកផ្ដល់សម្ភាសន៍ទាំងអស់ដែលមិនពាក់ព័ន្ធនៅក្នុងការរកស៊ីផ្លូវភេទទាល់តែសោះ និងអ្នកដទៃទៀតដែលអាចធ្វើការរកស៊ីផ្លូវភេទ ប៉ុន្តែបដិសេធមិនបញ្ជាក់ថាការរកស៊ីផ្លូវភេទជាមុខរបរ ឬប្រភពចំណូលចម្បង។




ក្តីបារម្ភដូចគ្នានេះដែរ គឺហេតុដែលថាអ្នកផ្តល់សម្ភាសន៍ចំនួនមួយភាគបី (ស្មើនឹង ៣១,៣៤%) បានរាយការណ៍ថាត្រូវបានបំពានផ្លូវភេទនៅពេលដើរនៅតាមដងផ្លូវ និងដឹងថាការបំពាននេះបណ្តាលមកពីអត្តសញ្ញាណប្តូរភេទរបស់ពួកគាត់។ ក្នុងចំណោមនេះ អ្នកដែលបានជួបប្រទះហេតុការណ៍ទាំងនេះច្រើនជាង ៣ ដងមានចំនួនច្រើន ដោយមាន ១៩,៥១% រាយការណ៍ថាត្រូវបានបំពានផ្លូវភេទពី ៤ ទៅ ៦ ដង និង ១៧,០៧% ត្រូវបានបំពានច្រើនជាង ១០ ដង។ នៅក្នុងចំណាត់ថ្នាក់ "ផ្សេង" អ្នកផ្តល់សម្ភាសន៍ចំនួន ២នាក់ (ស្មើនឹង៤,៨៩%) រាយការណ៍ថាត្រូវបានបំពានផ្លូវភេទច្រើនជាង ៥០ ដង និងមាន ១ នាក់ (ស្មើនឹង ២,៤៤%) ជួបហេតុការណ៍នេះច្រើនជាង ២០ ដងក្នុងអំឡុងពេល ១២ ខែចុងក្រោយនេះ។

ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ចំនួន ៤២ នាក់ដែលរាយការណ៍ថាត្រូវបានបំពានផ្លូវភេទ មាន ៣៤ នាក់ (៨២,៩៣%) ត្រូវបានគេរំលោភសេពសន្ថវៈនៅទីសាធារណៈក្នុងរយៈពេល ១២ ខែចុងក្រោយនេះ។ ក្នុងចំណោមនោះ មានអ្នកផ្តល់សម្ភាសន៍ ១ នាក់បាននិយាយថាគាត់បានជួបហេតុការណ៍នេះចំនួន ៥០ ដង និងម្នាក់ទៀតប្រាប់ថាបានជួបហេតុការណ៍នេះដែរចំនួន ៦០ ដងក្នុងរយៈពេល ១២ ខែចុងក្រោយនេះ។[31]

[31] ដោយសារសំណួរមានភាពរសើបអំពីបញ្ហារំលោភសេពសន្ថវៈ អាចថាការរីកសាយភាពជាក់ស្តែងនៃអំពើហិង្សាផ្លូវភេទលើអ្នកប្តូរភេទជាស្ត្រីមានកម្រិតខ្ពស់ជាងអ្វីដែលបានចង្អុលបង្ហាញនៅក្នុងរបកគំហើញទាំងនេះ ដោយហេតុថាអ្នកផ្តល់សម្ភាសន៍អាចបដិសេធមិនឆ្លើយសំណួរ។

ប្រហែលជាគួរឱ្យភ្ញាក់ផ្អើលដែលចំនួនអ្នករកស៊ីផ្លូវភេទដែលធ្លាប់ជួបការបំពានផ្លូវភេទ (ស្មើនឹង២៨,៥៧%) មានតួលេខតិចជាងអ្នកមិនរកស៊ីផ្លូវភេទ (ស្មើនឹង ៣២,៩៤%)។ ប៉ុន្តែក្នុងចំណោមអ្នកទទួលរងការបំពានផ្លូវភេទនេះ ចំនួនអ្នករកស៊ីផ្លូវភេទ ៧៣,៦៨% ធ្លាប់ត្រូវបានគេរំលោភសេពសន្ថវៈមានចំនួនច្រើនជាងអ្នកមិនរកស៊ីផ្លូវភេទ ៦៧,៥៧% នៅក្នុងរយៈពេល ១២ ខែចុងក្រោយនេះ។ ទិន្នន័យនេះផ្ទុយពីការសន្មតដែលថាអ្នករកស៊ីផ្លូវភេទមានហានិភ័យជុំវិញអំពើហិង្សាផ្លូវភេទខ្ពស់ជាងអ្នកដទៃទៀតដោយសារតែប្រភេទការងាររបស់ពួកគាត់ និងបានរំលេចផងដែរពីការរីកដុះដាលគួរឱ្យបារម្ភនៃការវាយប្រហារទាំងនោះលើអ្នកប្តូរភេទជាស្ត្រីថាជាក្រុមមនុស្សទូទៅមួយ។

ទោះបីជាមិនបានរៀបរាប់ឱ្យគ្រប់ជ្រុងជ្រោយនៅក្នុងសំណួរស្ទង់មតិក៏ដោយ ក៏ក្រុមស្រាវជ្រាវរបស់ ម.ស.ម.ក បានទទួលរបាយការណ៍ជាច្រើនអំពីអ្នកប្តូរភេទជាស្ត្រីដែលត្រូវបានហាមឃាត់ក្នុងការដើរហើរនៅតាមទីសាធារណៈនិងបង្ខំឱ្យចាកចេញពីទីសាធារណៈ ជាពិសេសកើតមាននៅក្នុងក្រុងបាត់ដំបងនិងក្រុងសៀមរាប។ អ្នកប្តូរភេទជាស្ត្រីខ្លះបានរាយការណ៍មក ម.ស.ម.ក ថាអ្នកដែលមានយេនឌ័រពីកំណើតមិនទទួលបានការប្រព្រឹត្តដូចពួកគាត់នោះទេ ទោះបីជាមិនទាន់មានការអះអាងបញ្ជាក់ពីបញ្ហានេះក្តី។ កញ្ញា មូលី[32] ដែលជាអ្នកប្តូរភេទជាស្ត្រីម្នាក់មកពីក្រុងបាត់ដំបង បានប្រាប់ ម.ស.ម.ក ថា ៖

*"រាល់ពេលដែលស្រីស្រស់មកជួបជុំគ្នានៅក្នុងសួន កម្លាំងនគរបាលបង្ខំឱ្យពួកយើងត្រឡប់ទៅផ្ទះវិញ និងគំរាមចាប់ខ្លួនពួកយើង ប្រសិនបើពួកយើងមិនធ្វើតាម។ ពួកគាត់តែងតែចោទប្រកាន់ពួកយើងថាជាចោរ។ នេះជាការរើសអើង។ ហេតុអ្វីបានជាពួកយើងមិនអាចនៅទីនោះដើម្បីលំហែកំសាន្តដូចអ្នកដទៃ? ពួកយើងមិនបង្ករឿងឯណា។"*

## ៤.៣ លក្ខខណ្ឌរស់នៅ គ្រួសារ និងទំនាក់ទំនង

ការស្រាវជ្រាវអះអាងថា អ្នកប្តូរភេទជាស្ត្រីជារឿយៗត្រូវបានបណ្តេញចេញ ឬមិនរាប់រកពីសំណាក់គ្រួសារ និងសហគមន៍ដោយសារតែអត្តសញ្ញាណរបស់ពួកគាត់ ដែលធ្វើឱ្យពួកគាត់មានលទ្ធភាពតិចតួចក្នុងការស្វែងរកប្រព័ន្ធគាំទ្រ។[33] អ្នកប្តូរភេទជាស្ត្រីបានរាយការណ៍ខុសៗគ្នាជាច្រើនថាខ្លួនមិនឱ្យចូលរួមក្នុងសកម្មភាពគ្រួសារ ដូចជាការជួបជុំគ្នា និងត្រូវបានបណ្តេញចេញពីផ្ទះ កាត់កាល់ចោលពីគ្រួសារ និងអ្នកដទៃទៀត។[34]

ក្នុងចំណោម អ្នកប្តូរភេទជាស្ត្រីដែលបានស្ទង់មតិដោយ ម.ស.ម.ក មាន ២២,៣៩% បានរាយការណ៍ថាត្រូវបានបណ្តេញចេញពីផ្ទះ ហើយក្នុងចំណោមនោះមាន ៦៥,៥២% ធ្លាប់ត្រូវបានបណ្តេញចេញច្រើនជាង

---

[32] ហេស្សនាម

[33] ម.ស.ម.ក "ការចេញមុខជាចំហរនៅក្នុងព្រះរាជាណាចក្រកម្ពុជា៖ ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទនៅកម្ពុជា" របាយការណ៍ (ឆ្នាំ ២០១០)។

[34] ដេវីឌ ចារ៉េត (Davis, Jarrett) និងអ្នកនិពន្ធដទៃទៀត "លើសពីយេនឌ័រ ៖ ការសិក្សាមូលដ្ឋានពីអ្នកប្តូរភេទនៅក្នុងឧស្សាហកម្មរកស៊ីផ្លូវភេទនៅរាជធានីភ្នំពេញ" ឆ្នាំ២០១៤។

ម្តង និង ១០,៣៤% ធ្លាប់ត្រូវបានបណ្តេញចេញ "*ញឹកញាប់ណាស់*"។ ក្នុងចំណោមអ្នកធ្លាប់ត្រូវបានបណ្តេញចេញ មាន ៦៤% ជឿជាក់ថានេះដោយសារតែមកពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគាត់។ ចំនួនជិតមួយភាគបី (២៩,៩២%) នៃអ្នកផ្តល់សម្ភាសន៍ទាំងអស់ជាមនុស្សគ្មានផ្ទះនៅ ដែលចំនួនអ្នករកស៊ីផ្លូវភេទ (៤២,៨៦%) មានចំនួនច្រើនជាងអ្នកមិនរកស៊ីផ្លូវភេទ (២១,៧៩%) ចំនួន ២ ដង ដែលរាយការណ៍ថាគ្មានផ្ទះសម្បែងពីមុនមក។ ក្នុងចំណោមអ្នកដែលមិនមានគ្រួសារគាំទ្រ (៣៤,៥៩%) មានចំនួន ៤៥,៤៥% គ្មានផ្ទះនៅ និងអ្នកផ្តល់សម្ភាសន៍ចំនួន ៤៨,៨៥% មានអារម្មណ៍ថាពួកគាត់ចាំបាច់ត្រូវចាកចេញពីផ្ទះដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគាត់។ អ្នកផ្តល់សម្ភាសន៍ចំនួន ១៥,២៧% ដែលជាចំនួនតូចលើកឡើងថាត្រូវបានបណ្តេញចេញពីផ្ទះរបស់ពួកគាត់។[35] ទិន្នន័យនេះបង្ហាញពីទំនាក់ទំនងគ្នារវាងការងាររកស៊ីផ្លូវភេទ និងភាពគ្មានផ្ទះសម្បែង ទោះបីជាយ៉ាងនេះក្តីទាមទារឱ្យមានការស្រាវជ្រាវបែបគុណវិស័យបន្ថែមទៀតដើម្បីស្វែងរកមូលហេតុពិតប្រាកដដែលបណ្តាលឱ្យមានបញ្ហាទាំងពីរខាងលើនេះសម្រាប់អ្នកប្តូរភេទជាស្ត្រី។ ក៏ប៉ុន្តែយើងអាច សន្មត់ដោយសមហេតុសមផលថា អ្នកដែលចាកចេញពីផ្ទះ ដោយសារតែអត្តសញ្ញាណយេនឌ័ររបស់គាត់ទំនងជាបានជួបប្រទះភាពគ្មានផ្ទះសម្បែងច្រើនជាងអ្នកដែលទទួលបានការគាំទ្រយ៉ាងពេញទំហឹងនៅក្នុងផ្ទះ។




---

35 របកគំហើញពីការស្រាវជ្រាវទាំងនេះគាំទ្រយ៉ាងខ្លាំងដល់ការស្រាវជ្រាវដែលមានស្រាប់ពីមុនពាក់ព័ន្ធនឹងស្ថានភាពលំនៅរបស់ការងាររកស៊ីផ្លូវភេទរបស់អ្នកប្តូរភេទ នៅរាជធានីភ្នំពេញ។ ដោយ ដេវីឌ ចារ៉ែត (Davis, Jarrett) និងអ្នកនិពន្ធដទៃទៀត ឆ្នាំ២០១៤ ទំព័រ ២២-២៣។




អ្នកផ្តល់សម្ភាសន៍ចំនួនពីរភាគបី( ស្មើនឹង ៦៩,៤%) បាននិយាយថា គ្រួសាររបស់ពួកគាត់មិនគាំទ្រពួកគាត់នៅពេលពួកគាត់បង្ហាញឱ្យដឹងពីអត្តសញ្ញាណ ជាអ្នកប្តូរភេទនោះទេ ទោះបីជាចំនួន ៦៥,៤១% បាននិយាយថាគ្រួសាររបស់ពួកគាត់គាំទ្រពួកគាត់នាពេលសព្វថ្ងៃនេះក្តី។ ចំនួនច្រើនជាងមួយភាគបី (ស្មើនឹង ៣៤,៥៩%) មានគ្រួសារ ដែលនាពេលបច្ចុប្បន្នមិនគាំទ្រពួកគាត់នោះទេ។ ទិន្នន័យនេះឆ្លុះបញ្ចាំងពីការគាំទ្រដល់ការស្រាវជ្រាវដែលមានស្រាប់។[36]

ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ដែលប្រាប់ថាគ្រួសាររបស់ខ្លួនបច្ចុប្បន្នមិនគាំទ្រពួកគេចំនួន៤៤,៤៤% បានប្រាប់ថានេះដោយសារតែមកពីក្តីបារម្ភពីកេរ្តិ៍ឈ្មោះគ្រួសារ និងចំនួន ២៤,៤៤% ប្រាប់ថាមកពីកង្វះការ

---

[36] មនុស្សស្រឡាញ់ភេទផ្ទុយគ្នាភាគច្រើនដែលត្រូវបានស្ទង់មតិដោយសហគមន៍ឥន្ទធនូកម្ពុជានៅក្នុងការស្ទង់មតិទូលំទូលាយមួយដែលធ្វើនៅឆ្នាំ ២០១៥ បានប្រតិកម្មអវិជ្ជមានទៅនឹងលទ្ធភាពនៃការមានសមាជិកគ្រួសារជាអ្នកស្រឡាញ់ភេទដូចគ្នា (កូន កូនប្រសារ ឬប្រពន្ធ) ជាជាងមានគំនិតវិជ្ជមានពីបញ្ហានេះ។ ចំនួនច្រើនជាងពាក់កណ្តាលសម្តែងថាពួកគាត់នឹងមានអារម្មណ៍ខ្មាសគេ ខឹង ឬសោកស្តាយចំពោះក្រុមអ្នកស្រឡាញ់ភេទផ្ទុយគ្នា និងសង្ឃឹមថាពួកគេជាមនុស្សស្រឡាញ់ភេទផ្ទុយគ្នា។ អ្នកស្រឡាញ់ភេទផ្ទុយគ្នាចំនួន ៧៨% នៅក្នុងការស្ទង់មតិរបស់សហគមន៍ឥន្ទនូកម្ពុជាដែលអះអាងថានឹងក្លាយជាអ្នកគាំទ្រក្រុមអ្នកស្រឡាញ់ភេទដូចគ្នា បាននិយាយថាមានតែបន្ទាប់ពីព្យាយាមប្តូរកូនដែលជាក្រុមអ្នកស្រឡាញ់ភេទដូចគ្នារបស់ពួកគាត់ឱ្យក្លាយជាមនុស្សធម្មតាវិញសិន ទើបបានពួកគាត់ព្រមទទួលយកពួកគេ។

យល់ដឹងពីបញ្ហាក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។ ចំនួនជិត ៩% (៨,៨៩%) បានបង្ហាញថាកង្វះការគាំទ្របណ្ដាលមកពីក្ដីបារម្ភអំពីការបន្តវង្សត្រកូល និងអ្នកផ្សេងទៀតនិយាយថាមកពីបញ្ហាទាំងអស់ខាងលើ។ ជាចំណុចគួរឱ្យចាប់អារម្មណ៍ដែលថា ការបដិសេធទទួលយកពីគ្រួសារមិនមែនមកពីទស្សនៈផ្នែកសាសនា ឬមានៈនោះទេ ប៉ុន្តែគឺមកពីតម្លៃគ្រួសារតាមប្រពៃណី និងក្ដីបារម្ភពីកេរ្តិ៍ឈ្មោះ។

អ្នកផ្ដល់សម្ភាសន៍ច្រើនជាងពាក់កណ្ដាល (ស្មើនឹង ៥៣,៤៩%) បាននិយាយថា សមាជិកគ្រួសារបានព្យាយាមបង្ខំពួកគាត់ឱ្យរៀបអាពាហ៍ពិពាហ៍នាពេលកន្លងមក។ ក្នុងករណីចំនួន ៩៥,៥៩% ការរៀបអាពាហ៍ពិពាហ៍មិនបានធ្វើទៀចនោះទេ មានតែអ្នកផ្ដល់សម្ភាសន៍ចំនួន ៣ នាក់ (៤,៤១%) ប៉ុណ្ណោះដែលបានរៀបការ។ ការជំរុញ ឬការចាប់បង្ខំឱ្យរៀបការជាមួយភេទផ្ទុយគ្នាគឺជាបទពិសោធន៍ជូរចត់ ដែលអ្នកប្ដូរភេទជាស្ត្រី និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាជាច្រើនបានជួបប្រទះ។ វារួមមានអារម្មណ៍តប់ប្រមល់លាយឡំគ្នាក្នុងការបដិសេធទទួលយកដាច់ខាតពីអត្តសញ្ញាណពិតរបស់អ្នកប្ដូរភេទវ័យក្មេងពីសំណាក់គ្រួសារ រួមជាមួយនឹងជាតុផ្សំនៃការបង្ខិតបង្ខំ និងពេលខ្លះប្រើកម្លាំងកាយ និងឆ្លុះបញ្ចាំងពីតួនាទីដ៏សក្ដិសិទ្ធិ និងមិនអាចបត់បែនបាននៃការរៀបការជាមួយភេទផ្ទុយគ្នាតាមប្រពៃណីនៅក្នុងសង្គមខ្មែរ ដែលជាឧបសគ្គដ៏សំខាន់មួយសម្រាប់ស្វែងរកភាពស្មើគ្នារបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។

## ៤.៤ ការងារ

ជាលទ្ធផលនៃការរើសអើង អ្នកប្ដូរភេទប្រឈមនូវអត្រាគ្មានការងារធ្វើខ្ពស់ និងជារឿយៗត្រូវបានរុញច្រានពួកគាត់ឱ្យស្វែងរកការងារក្នុងលក្ខខណ្ឌចង្អៀត មិនសូវមានការយកចិត្តទុកដាក់ ឬមុខរបរបែបស្ត្រី។ បើយោងតាមកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ *"នៅក្នុងតំបន់ខ្លះ អ្នកប្ដូរភេទជាស្ត្រីភាគច្រើនបំផុតគឺជាអ្នករកស៊ីផ្លូវភេទ ដោយទទួលបានសិទ្ធិមានកម្រិត ឬគ្មានសិទ្ធិឬគ្មានការការពារតាមផ្លូវច្បាប់"*។[37] អ្នកប្ដូរភេទជាស្ត្រីជាច្រើនមិនត្រូវបានរាប់រកនៅកន្លែងធ្វើការដោយសារនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគាត់ និងមានរបាយការណ៍អំពីអ្នកប្ដូរភេទជាស្ត្រីមួយចំនួនដែលត្រូវបានបដិសេធទទួលឱ្យធ្វើការ នៅពេលដែលនិន្នាការភេទ និងអត្តសញ្ញាណ យេនឌ័ររបស់ពួកគាត់ត្រូវបានលាតត្រដាង ជាឧទាហរណ៍ បន្ទាប់ពីជាប់ការសម្ភាសន៍តាមការសរសេររួច និងនៅសល់តែជួបជាមួយនឹងនិយោជកដោយផ្ទាល់។ អ្នកប្ដូរភេទជាស្ត្រីមួយចំនួនធំធ្វើការជាអ្នករកស៊ីផ្លូវភេទ ដោយមានចំនួនតិចតួចដែលស្វែងរកការងារធ្វើនៅក្នុងរោងចក្រ និងការងារផ្សេងៗដូចជាកាតសក់ ផាត់មុខ និងបោកគក់ ដែលមានប្រាក់ឈ្នួលប្រចាំខែជាមធ្យមចំនួនប្រហែល ៣២០ដុល្លារ បើយោងតាមការស្រាវជ្រាវមួយ។[38]

---

[37] កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ "សុខភាព និងសិទ្ធិមនុស្សរបស់អ្នកប្ដូរភេទ" ឯកសារពិភាក្សា ឆ្នាំ២០១៣ ទំព័រទី ១៤ ។

[38] ដេវីឌ ចារ៉េត (Davis, Jarrett) និងអ្នកនិពន្ធដ៏ទៃទៀត "លើសពីយេនឌ័រ ៖ ការសិក្សាមូលដ្ឋានពីអ្នកប្ដូរភេទនៅក្នុងឧស្សាហកម្មរកស៊ីផ្លូវភេទនៅរាជធានីភ្នំពេញ" ឆ្នាំ២០១៤ ទំព័រទី២០ ។

គួរឱ្យកត់សម្គាល់ អ្នកផ្តល់សម្ភាសន៍ចំនួន ៤៦ នាក់ (ស្មើនឹង ៣៥,១១%) នៅក្នុងការស្ទង់មតិរបស់ ម.ស.ម.ក បញ្ជាក់ថាការងាររកស៊ីផ្លូវភេទគឺជាមុខរបរចម្បងរបស់ពួកគាត់។ នៅពេលសួរពីប្រភពចំណូលចម្បងក្នុងរយៈពេល ១២ ខែចុងក្រោយនេះ មានតែមុខរបរតែមួយមុខប៉ុណ្ណោះដែលបានលើកឡើងក្រៅពីការងាររកស៊ីផ្លូវភេទ គឺមុខរបរកាត់សក់ និងថែសម្ផស្ស ដែលមានអ្នកផ្តល់សម្ភាសន៍ចំនួន ៣៩,៦៩% (ស្មើនឹង ៥២ នាក់) ធ្វើការនៅក្នុងឧស្សាហកម្មនេះ តែជាញឹកញាប់គឺប្រកបរបរទាំងពីរនេះជាមួយគ្នា។ បន្ទាប់ពីតួលេខនៃអ្នករកស៊ីផ្លូវភេទនេះ អ្នកផ្តល់សម្ភាសន៍ចំនួន ៦,១១% (ស្មើនឹង ៨ នាក់) បញ្ជាក់ថាធ្វើការនៅក្នុងឧស្សាហកម្មកំសាន្តនិង ៥,៣៤% (ស្មើនឹង ៧ នាក់) ធ្វើការនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលឬអង្គការនៅតាមមូលដ្ឋាន។ អ្នកផ្តល់សម្ភាសន៍ ៥១,៥៩% រកចំណូលបានចន្លោះពី ១០០ ទៅ ២៩៩ ដុល្លាអាមេរិកក្នុងមួយខែ ក្នុងរយៈពេល ៣ ខែចុងក្រោយនេះអ្នកផ្តល់សម្ភាសន៍ចំនួន ១៥,៨៧% រកចំណូលបានចាប់ពី ៥១ ដល់ ១០០ ដុល្លារក្នុងមួយខែ។ អ្នកផ្តល់សម្ភាសន៍ចំនួន ១៤,២៩% រកចំណូលបានពី ៣០០ ដល់ ៤៩៩ ដុល្លាអាមេរិក ខណៈដែលចំនួន ៧,៩៤% រកចំណូលបានតិចជាង ៥០ ដុល្លាអាមេរិក និងចំនួន ១០,៣១% រកបានចំណូល ៥០០ ដុល្លាអាមេរិក ឬច្រើនជាងនេះ។

ទោះបីជាពាក្យពេចន៍នៅក្នុងសំណួរទាមទារឱ្យបានចម្លើយអំពីមុខរបរតែមួយគត់ក្តីក៏អ្នកផ្តល់សម្ភាសន៍ជាច្រើនបានឆ្លើយតបប្រាប់ពីមុខរបរច្រើនជាង ១ ថាជាប្រភពចំណូលចម្បងរបស់ពួកគាត់ ដែលនេះជាការបង្ហាញថានៅក្នុងករណីជាច្រើនចាំបាច់ត្រូវមានប្រភពចំណូលច្រើន។ ជាសរុប អ្នកផ្តល់សម្ភាសន៍ចំនួន ១៥,០៨% បានបញ្ជាក់ពីការងាររកស៊ីផ្លូវភេទជាមុខរបរដែលធ្វើអមជាមួយនឹងទម្រង់ការងារផ្សេងទៀត។

ការរីកដុះដាលនៃជម្រើសមុខរបរបែប"ស្ត្រី"ជាលក្ខណៈប្រពៃណី គឺជាករណីគួរឱ្យកត់សម្គាល់។ ការសិក្សាស្រាវជ្រាវបានបង្ហាញថា អ្នកប្តូរភេទជាស្ត្រីមានទំនោរយល់ថាឱកាសការងាររបស់ពួកគាត់មានកម្រិតត្រឹមតែប្រភេទការងារស្ត្រីបែបប្រពៃណីប៉ុណ្ណោះ។[39] ករណីនេះអាចជាផ្នែកមួយមកពីបុរេវិនិច្ឆ័យរបស់និយោជក ប៉ុន្តែក៏បញ្ជាក់បានផងដែរថាវាពាក់ព័ន្ធនឹងផ្នត់គំនិតវប្បធម៌ក្នុងស្រុកស្តីពីអត្តសញ្ញាណអ្នកប្តូរភេទផ្ទាល់ និងការរំពឹងទុកពីសង្គមលើអ្នកប្តូរភេទជាស្ត្រី។[40]

ការរើសអើងពីសង្គម និងការផាត់ចេញពីសង្គមទំនងជាដើរតួសំខាន់នៅក្នុងការបង្ខំឱ្យអ្នកប្តូរភេទជាស្ត្រីជាច្រើនចាប់យកការងាររកស៊ីផ្លូវភេទ ដែលមានស្ថានភាពសេដ្ឋកិច្ចទាប កង្វះការអប់រំ និងជំនាញ។ បន្ថែមពី

---

[39] ដេវីឌ ចារ៉េត (Davis, Jarrett) និងអ្នកនិពន្ធដ៏ទៃទៀត អះអាងថាលើសពីមូលហេតុជារចនាសម្ព័ន្ធសម្រាប់អ្នកប្តូរភេទជាស្ត្រីដែលស្វែងរកការងារដែលពួកគាត់សមនឹងទទួលបាន អត្តសញ្ញាណដែលកំណត់របស់អ្នកប្តូរភេទ ឬមនុស្សភេទទី ៣ នៅក្នុងសង្គមខ្មែរលើកទឹកចិត្តឱ្យមានជម្រើសមួយចំនួន រួមទាំងការងាររកស៊ីផ្លូវភេទ។ ការសិក្សាស្រាវជ្រាវនោះដកស្រង់ភាពច្របូកច្របល់ខាងផ្លូវភេទ និងចំណង់ចង់រួមភេទជាមួយបុរស "ពិត" (ភាពជាមនុស្សប្រុសពិតៗ) ថាជាផ្នែកសំខាន់មួយនៃអត្តសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកប្តូរភេទជាស្ត្រីដែលបានសម្ភាសន៍។ ការសិក្សាបានអះអាងថាការងាររកស៊ីផ្លូវភេទអាចផ្តល់មិនត្រឹមតែចំណូលប៉ុណ្ណោះទេ ថែមទាំងជាវិធីរស់នៅជាមួយនឹងអត្តសញ្ញាណដែលសន្មតរបស់ពួកគាត់ផងដែរ ដែលការណ៍នេះត្រូវបានបញ្ជាក់ដោយសារតែការទាក់ទាញតែប៉ុណ្ណោះ និងរួមភេទជាមួយនឹងបុរសពិត ឆ្នាំ ២០១៤ ទំព័រ ២៩ ។

[40] ដូចលេខយោងខាងលើ ទំព័រ ៣១ ។

លើនេះ អ្នកប្តូរភេទជាស្រ្តីជាច្រើនត្រូវបានបដិសេធទទួលឱ្យធ្វើការ និងចូលបម្រើនៅក្នុងការងាររកស៊ីផ្លូវភេទ ដោយសារគ្មានជម្រើសផ្សេងដែលជាក់លាក់ ឬចង់បាន។[41] ប៉ុន្តែ អ្នកប្តូរភេទជាស្រ្តីជាច្រើនបានប្រាប់អ្នកស្រាវជ្រាវរបស់ ម.ស.ម.ក ថាពួកគាត់ធ្វើការងាររកស៊ីផ្លូវភេទ មិនមែនដោយសារភាពចាំបាច់នោះទេ តែមកពីគ្មានជម្រើស ហើយអ្នកផ្តល់សម្ភាសន៍មួយចំនួនដែលរកប្រាក់ចំណូលបានគ្រប់គ្រាន់ពី"ការងារពេលថ្ងៃ" ក៏ធ្វើការងាររកស៊ីផ្លូវភេទនាពេលយប់ផងដែរ។ ដូច្នេះ ក្នុងបរិបទនៃសេវាគាំទ្រ និងការតស៊ូមតិ ការងាររកស៊ីផ្លូវភេទមិនគួរត្រូវបានចាត់ទុកថាជាការប្រកបទៅតាមកាលៈទេសៈនោះទេ និងយើងត្រូវតែទទួលស្គាល់ថាក្នុងករណីជាច្រើន វាគឺជាជម្រើស។ ទន្ទឹមនឹងការកាត់បន្ថយការរើសអើងពីសំណាក់និយោជក ការផ្តល់ជំនាញ និងការបណ្តុះបណ្តាលត្រូវតែធ្វើឡើងដើម្បីបង្កើនជម្រើសបន្ថែមដល់អ្នកប្តូរភេទជាស្រ្តី ហើយយើងត្រូវតែគោរពជម្រើសរបស់អ្នកដែលចាប់យកការងាររកស៊ីផ្លូវភេទ ព្រមទាំងត្រូវធានាអំពីសិទ្ធិ និងធានាសុវត្ថិភាពរបស់ពួកគាត់នៅក្នុងពេលធ្វើការ។




គួរឱ្យកត់សម្គាល់ អ្នកផ្តល់សម្ភាសន៍ច្រើនជាងមួយភាគបី (ស្មើនឹង ៣៤,៣៥%) ត្រូវបានបដិសេធទទួលឱ្យធ្វើការ និងអ្នកផ្តល់សម្ភាសន៍ចំនួន ២៤,៦២% បាននិយាយថាពួកគាត់ត្រូវបានគេបណ្តេញចេញពីការងារ ដោយសារតែពួកគាត់ជាអ្នកប្តូរភេទ។ ចំនួនរាយការណ៍ពីការប្រព្រឹត្តមិនត្រឹមត្រូវនៅកន្លែងការងារក៏មានចំនួនខ្ពស់ផងដែរ ដែលអ្នកផ្តល់សម្ភាសន៍ចំនួន ២៦,៧២% ធ្លាប់ត្រូវបានប្រមាថ ឬមាក់ងាយពីសំណាក់

---

[41] ដូចលេខយោងខាងលើ ទំព័រ ៣៦ ។

ចៅហ្វាយនាយ ឬមិត្តរួមការងារ ហើយអ្នកផ្តល់សម្ភាសន៍ចំនួន ១១,៥៤% ធ្លាប់ត្រូវបានបៀតបៀនកេរ្តិ៍ខ្មាស់ និងអ្នកផ្តល់សម្ភាសន៍ចំនួន ៨,៥៣% ទៀតត្រូវបានបំពានលើរាងកាយ។ ករណីបំពានពីសំណាក់អតិថិជនក៏មានចំនួនខ្ពស់ផងដែរ ដែលអ្នកផ្តល់សម្ភាសន៍ចំនួន ២២,១៤% ត្រូវបានបំពានលើរាងកាយ និង ១៧,៦៩% ត្រូវបានបៀតបៀនកេរ្តិ៍ខ្មាស់ពីសំណាក់អតិថិជនឬអ្នកប្រើប្រាស់សេវានៅក្នុងរយៈពេល ១២ ខែចុងក្រោយនេះ។

នេះជាភស្តុតាងដែលបង្ហាញថា អ្នកប្តូរភេទជាស្ត្រីជួបការលំបាកជាខ្លាំងក្នុងការទទួលបាន និងរក្សាការងារក្នុងប្រព័ន្ធ ក៏ដូចជាការប្រមាថខ្លាំងៗនៅក្នុងកន្លែងធ្វើការផងដែរ។ របាយការណ៍មួយបានកត់ចំណាំថា សូម្បីតែក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការលើបញ្ហាអ្នកប្តូរភេទជាស្ត្រី ក៏កើតមានការរើសអើងលើអ្នកប្តូរភេទដែរ នៅពេលនិយាយពីរឿងផ្តល់ការងារឱ្យធ្វើ ជាឧទាហរណ៍ចន្លោះពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១២ បណ្តាញបុរសស្រឡាញ់បុរស និងអ្នកប្តូរភេទជាស្ត្រីថ្នាក់ជាតិមិនមានសមាជិកណាម្នាក់ជាបុគ្គលិកពេញសិទ្ធិចេញពីក្រុមទាំងនោះទេ។[42]

កត្តាសំខាន់មួយនៃការរើសអើងការងារមិនត្រូវបានបកស្រាយឱ្យបានគ្រប់ជ្រុងជ្រោយនៅក្នុងសំណួរស្រាវជ្រាវនោះទេ ប៉ុន្តែវាត្រូវបានមើលឃើញយ៉ាងច្បាស់នៅពេលដែលអ្នកស្រាវជ្រាវបានសាកសួរអ្នកផ្តល់សម្ភាសន៍ថា អ្នកប្តូរភេទជាស្ត្រីជាច្រើនដែលបានផ្តល់កិច្ចសម្ភាសន៍មិនដែលធ្លាប់ដាក់ពាក្យធ្វើការងារ "ក្នុងប្រព័ន្ធ"ទេ ដោយហេតុថាពួកគាត់មានអារម្មណ៍ថានឹងមិនអាចទទួលបានការងារធ្វើនោះទេ។ នេះក៏អាចជាកត្តាពន្យល់ពីភាពចង្អៀតនៃមុខរបរ ដែលអាចមានសម្រាប់អ្នកប្តូរភេទជាស្ត្រីធ្វើ និងគាំទ្រដល់ទ្រឹស្តីនៃការដាក់កម្រិតខ្លួនឯងដែលបានលើកឡើងពីមុន និងនៅក្នុងការស្រាវជ្រាវផ្សេងផងដែរ។[43] នេះជាភស្តុតាងដែលអ្នកប្តូរភេទជាស្ត្រីនៅកម្ពុជាត្រូវបានកម្រិតមិនត្រឹមតែកត្តារូបរាងខាងក្រៅដើម្បីស្វែងរកការងារប៉ុណ្ណោះទេ ថែមទាំងកត្តាខាងក្នុងពាក់ព័ន្ធនឹងទស្សនៈយល់ឃើញនិងសក្តានុពលរបស់ខ្លួនឯងថែមទាំងផង។ វាអាចទៅរួចដែរដែលថាករណីនេះបង្កើតជាមធ្យោបាយនៃការរារាំងខ្លួនឯង ដែលអ្នកប្តូរភេទជាស្ត្រីមិនហ៊ានប្រថុយនឹងហានិភ័យនៅពេលពួកគាត់ដឹងពីឱកាសជោគជ័យរបស់ខ្លួនមានកម្រិត ដោយសារការរើសអើងជាក់ស្តែង និងវិករាលដាលពីសំណាក់និយោជក និងសាធារណជនទូទៅ។

## ៤.៥ នគរបាល និងអាជ្ញាធរ

ការស្រាវជ្រាវរបស់ ម.ស.ម.ក បង្ហាញថាអាជ្ញាធរអនុវត្តច្បាប់ដែលជាអ្នកទទួលបន្ទុកការពារសិទ្ធិសុវត្ថិភាព និងសន្តិសុខរបស់ប្រជាពលរដ្ឋ គឺស្ថិតក្នុងចំណោមអ្នករំលោភបំពានអាក្រក់បំផុតលើសិទ្ធិរបស់អ្នកប្តូរភេទជាស្ត្រីនៅកម្ពុជា។ របកគំហើញពីការស្រាវជ្រាវនេះបង្ហាញពីចំនួនអ្នកប្តូរភេទត្រូវបានឃាត់ខ្លួន និងឃុំខ្លួនជាច្រើនគួរ ឱ្យកត់សម្គាល់ដោយមូលហេតុអត្តសញ្ញាណប្តូរភេទជាស្ត្រីរបស់ពួកគាត់ រួមទាំងបទល្មើសដែលពួក

---

42 ដូចលេខយោងខាងលើ ទំព័រ ៤៣ ។

43 ដូចលេខយោងខាងលើ ទំព័រ ៣១ ។

គាត់មិនបានប្រព្រឹត្តដើម្បីយកសំណូក។ ករណីការប្រមាថដោយពាក្យសម្តី លើរាងកាយ និងផ្លូវភេទពីសំណាក់នគរបាលក៏មានច្រើនជាទូទៅផងដែរ។

នគរបាលនិងអាជ្ញាធរដែលរំលោភបំពានទៅលើសិទ្ធិរបស់អ្នកប្តូរភេទជាស្ត្រីធ្វើឡើងដោយនិទណ្ឌភាពយ៉ាងច្បាស់ និងចំនួនអ្នកប្តូរភេទជាស្ត្រីដែលមានអារម្មណ៍ថាគួររាយការណ៍ពីហេតុការណ៍បែបនេះនៅមានកម្រិតទាបនៅឡើយ។ អ្នកផ្តល់សម្ភាសន៍ភាគច្រើន (៧៤,៦៣%) បាននិយាយថាពួកគាត់ស្គាល់អ្នកប្តូរភេទដែលត្រូវនគរបាលឃាត់ខ្លួន ដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគាត់។ ក្នុងចំណោមអ្នកប្តូរភេទដែលធ្លាប់ត្រូវបានខ្លួនចំនួន ៣៨,៧% មានមាន ៩១,៦៧% ជឿជាក់ថាពួកគាត់ត្រូវបានចាប់ខ្លួនដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគាត់។ អ្នកផ្តល់សម្ភាសន៍ចំនួនជិតមួយភាគបួន (២៣,៣១%) ត្រូវបាននគរបាលឃុំខ្លួននាពេលកន្លងមក ហើយជាថ្មីម្តងទៀត ហើយដែលក្នុងចំណោមអ្នកទាំងនេះភាគច្រើនបំផុត (៩០,៦៣%) ជឿជាក់ថានេះមកពីមូលហេតុពួកគាត់ជាមនុស្សប្តូរភេទ។




ក្នុងចំណោមអ្នកដែលត្រូវបានឃុំខ្លួន មាន ២៩,៦៣% (ស្មើនឹង ៨ នាក់) ត្រូវបានឃុំខ្លួនចន្លោះពី ១ ទៅ ៣ ម៉ោង ឬពី ៤ ទៅ ១១ ម៉ោង និង ៣៧,០៤% (ស្មើនឹង ១០ នាក់) ត្រូវបានឃុំខ្លួនចន្លោះពី ១២ ទៅ ២៤ ម៉ោង។ មានអ្នកផ្តល់សម្ភាសន៍ចំនួន ២ នាក់ត្រូវបានឃុំខ្លួនទុករយៈពេលយូរជាង ២៤ ម៉ោង។

## តើអ្នកធ្លាប់ត្រូវបាននគរបាលរំខាន ឬសម្លុតដោយសារតែអ្នក ជាអ្នកប្តូរភេទដែរឬទេ?

ចម្លើយ: ១៣២ រំលង: ៣




## ប្រសិនបើធ្លាប់ តើមានប៉ុន្មានដង គិតត្រឹមរយៈពេល ១២ ខែនេះ?

ចម្លើយ: ៥៣ រំលង: ៨២



អ្នកផ្តល់សម្ភាសន៍ចំនួន ៤០,១៥% បាននិយាយថាពួកគាត់ត្រូវបាននគរបាលប្រមាថ ឬសម្លុតដោយសារតែពួកគាត់ជាមនុស្សប្តូរភេទ ដែលក្នុងនោះមាន ៨៥% រាយការណ៍ថាបានជួបបញ្ហានេះនៅក្នុងរយៈពេល ១២ ខែចុងក្រោយ។ អ្នកផ្តល់សម្ភាសន៍ចំនួន ៦ នាក់ជួបករណីបែបនេះច្រើនជាង ១០ ដងក្នុងរយៈពេល ១២ ខែចុងក្រោយនេះ។ ការបំពានលើរាងកាយដោយនគរបាលត្រូវបានរាយការណ៍ដោយអ្នកផ្តល់សម្ភាសន៍ចំនួន ១៧,១៦% ហើយក្នុងចំណោមនោះមាន ៣ នាក់ (ស្មើនឹង១២,៥%) បាននិយាយថាពួកគាត់ធ្លាប់ជួបបញ្ហានេះច្រើនជាង១០ ដងក្នុងរយៈពេល ១២ ខែចុងក្រោយនេះ។ ចំនួនប្រហាក់ប្រហែលនេះដែរ (១៤,៩៣% ស្មើនឹង ២០ នាក់) បានរាយការណ៍ថាត្រូវបាននគរបាលបៀតបៀនកេរ្តិ៍ខ្មាស់ និង ៩,០២% (ស្មើនឹង១២ នាក់) ត្រូវបាននគរបាលបំពានផ្លូវភេទ មានម្នាក់ធ្លាប់ជួបហេតុការណ៍នេះច្រើនជាង ១០ ដងក្នុងរយៈពេល ១២ ខែចុងក្រោយនេះ។ ការរីកដុះដាលខ្ពស់នៃការបំពានពីសំណាក់នគរបាលនេះគឺជាក្តីបារម្ភយ៉ាងខ្លាំង និងចង្អុលបង្ហាញពីការខកខានរបស់កម្ពុជាក្នុងការគោរព និងការពារសិទ្ធិរបស់អ្នកប្តូរភេទជាស្ត្រីឱ្យបានគ្រប់គ្រាន់។ មិនត្រឹមតែនគរបាលដែលមិនបានបំពេញកាតព្វកិច្ចការពារអ្នកប្តូរភេទជាស្ត្រីពីការបំពានសិទ្ធិមនុស្សប៉ុណ្ណោះទេ នៅក្នុងករណីជាច្រើន នគរបាលផ្ទាល់ជាអ្នកប្រព្រឹត្តបំពាន។

អ្នកប្តូរភេទជាស្ត្រីមួយចំនួនបាននិយាយប្រាប់ ម.ស.ម.ក ថាពួកគាត់ត្រូវបានចោទប្រកាន់ថាផ្ទុកឬចម្លងមេរោគអេដស៍ ដែលការចំអកឡកឡើយបែបនេះធ្វើឱ្យពួកគាត់ត្រូវបានឃាត់ខ្លួនពីសំណាក់ជនល្មើសពីអំពើបំពាននានា។ អ្នកប្តូរភេទជាស្ត្រីផ្សេងទៀតដែលបានស្នង់មតិបានឆ្លើយថាខ្លួនត្រូវបានបង្ខំឱ្យសូកសំណូក និងធ្វើការងារបោសជូត។ សំខាន់ជាងនេះទៀត អ្នកផ្តល់សម្ភាសន៍ច្រើនជាងមួយភាគបី (ស្មើនឹង ៣៣,៥៨%) បានរាយការណ៍ថាខ្លួនត្រូវបានចោទប្រកាន់ដោយទម្លាក់កំហុសថាបានប្រព្រឹត្តបទល្មើស ហើយក្នុងចំណោមនោះមាន ៦២,៥% បានសូកប៉ាន់ទៅឱ្យមន្ត្រីដែលឃាត់ខ្លួនពួកគាត់។ ការប្រព្រឹត្តកាន់តែច្រើនឡើងរបស់មន្ត្រីនគរបាលក្នុងការចោទប្រកាន់ជាការទម្លាក់កំហុស និងការឃុំខ្លួនគឺកំពុងតែជាក្តីកង្វល់យ៉ាងខ្លាំង។ ខណៈដែលគ្មានក្រុមការងារត្រួតពិនិត្យដើម្បីប្រៀបធៀបទិន្នន័យទាំងនេះជាមួយនឹងស្ថិតិរបស់ប្រជាជនទូទៅ វាទំនងដែលថាអ្នកប្តូរភេទគឺជាជនរងគ្រោះដែលជាគោលដៅរបស់នគរបាល ដោយសារតែពួកគាត់មានឋានៈតូចទាបនៅក្នុងសង្គមខ្មែរ រួមជាមួយអាត្រាអ្នករកស៊ីផ្លូវភេទមានច្រើននៅក្នុងចំណោមក្រុមអ្នកប្តូរភេទជាស្ត្រី។

## ៤.៦ ការងាររកស៊ីផ្លូវភេទ និងការរើសអើងពីសង្គម

ទន្ទឹមនឹងរបកគំហើញពីការស្រាវជ្រាវនេះបង្ហាញថា អ្នកប្តូរភេទជាស្ត្រីជាទូទៅជួបប្រទះការរើសអើងក្នុងកម្រិតខ្ពស់ ប៉ុន្តែនៅពេលទិន្នន័យបានពីអ្នកដែលរាយការណ៍ថាធ្វើការងាររកស៊ីផ្លូវភេទត្រូវបានវិភាគដាច់ដោយឡែក វាបង្ហាញឱ្យឃើញច្បាស់ថាមានភាពខុសគ្នាដាច់នៅក្នុងរបកគំហើញដែលបង្ហាញពីបញ្ហាពិសេសដោយឡែកចំពោះអ្នករកស៊ីផ្លូវភេទ។ អ្វីដែលសំខាន់ ក្នុងចំណោមអ្នកដែលបានរាយការណ៍ថាធ្វើការរកស៊ីផ្លូវភេទកាលពីអតីតកាល មាន ៩៥,៧៤% ត្រូវបានប្រមាថដោយពាក្យសម្តី ៩១,៣% ត្រូវបានបំពានលើរូបរាងកាយ និង ៨៥,១១% ត្រូវបានបំពានផ្លូវភេទនៅពេលប្រកបរបររកស៊ីផ្លូវភេទ។ ខណៈដែលដែលអាត្រានៃការ

ប្រមាថនៅតាមទីសាធារណៈមានកម្រិតខ្ពស់ចំពោះអ្នកប្តូរភេទជាស្ត្រីទាំងអស់ របកគំហើញខ្លះពាក់ព័ន្ធនឹងការរើសអើងនៅក្នុងការងារ គ្រួសារ និងការបំពាននៅក្នុងទំនាក់ទំនងស្និតរមួត បែរជាមានកម្រិតខ្ពស់ជាងចំពោះអ្នករកស៊ីផ្លូវភេទ។

នេះជាការសំខាន់ដែលត្រូវកត់ចំណាំថា ខណៈដែលរបកគំហើញពីការស្រាវជ្រាវនេះបង្ហាញថាអ្នករកស៊ីផ្លូវភេទជាទូទៅជួបប្រទះការរើសអើងច្រើនជាងអ្នកមិនរកស៊ីផ្លូវភេទ តែអ្នកប្តូរភេទជាស្ត្រីដែលមិនធ្លាប់ធ្វើការរកស៊ីផ្លូវភេទមានកម្រិតរើសអើងខ្ពស់ប្រហាក់ប្រហែលគ្នាដែរក្នុងចំណោមអ្នកប្តូរភេទជាស្ត្រីទាំងអស់។




អ្នករកស៊ីផ្លូវភេទច្រើនជាងពាក់កណ្តាល (៥៧,១៤%) បានរាយការណ៍ថា ខ្លួនត្រូវបានបដិសេធទទួលឱ្យធ្វើការដោយសារតែពួកគាត់ជាអ្នកប្តូរភេទ បើប្រៀបធៀបទៅនឹងអ្នកមិនរកស៊ីផ្លូវភេទដែលមានតែចំនួន ២០,៧៣% ។ គួរឱ្យកត់សម្គាល់ប្រហែលគ្នានេះដែរ អ្នករកស៊ីផ្លូវភេទចំនួន ៤០,៨២% រាយការណ៍ថាខ្លួនត្រូវបានបណ្តេញចេញពីការងារដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគាត់ បើប្រៀបធៀបទៅនឹងអ្នកមិនរកស៊ីផ្លូវភេទដែលមានកម្រិតទាបជាងឆ្ងាយក្នុងចំនួនត្រឹមតែ ១៤,៨១%។ ភាពខុសគ្នាខ្លាំងទាំងនេះបង្ហាញថា ការរើសអើងពីសំណាក់និយោជកទំនងជាកត្តាចម្បងដែលនាំឱ្យអ្នកប្តូរភេទជាស្ត្រីងាកទៅរកការងាររកស៊ីផ្លូវភេទ។ ពាក់ព័ន្ធនឹងបទពិសោធន៍នៃការរើសអើងនៅក្នុងប្រព័ន្ធកន្លែងធ្វើការ អ្នករកស៊ីផ្លូវភេទចំនួន ៤០,៨២% ធ្លាប់ត្រូវបានប្រមាថ ឬសម្លុតពីសំណាក់មិត្តរួមការងារ ឬចៅហ្វាយនាយ បើប្រៀបទៅនឹងអ្នកមិនរកស៊ីផ្លូវភេទដែលមានចំនួន ១៨,៣៧% ។

ចំនួនអ្នករកស៊ីផ្លូវភេទដែលរាយការណ៍ថា ខ្លួនមិនត្រូវអនុញ្ញាតឱ្យចូលរួមក្នុងកម្មវិធីសង្គមផ្សេងៗនៅក្នុងរយៈពេល ១២ ខែចុងក្រោយនេះពីសំណាក់គ្រួសាររបស់ពួកគាត់កើនឡើងពី ៩,៤១% សម្រាប់អ្នកមិនរកស៊ីផ្លូវភេទ ទៅដល់ ២០,៨៣% សម្រាប់អ្នករកស៊ីផ្លូវភេទ។ ក្នុងចំណោមអ្នករកស៊ីផ្លូវភេទ មាន ២២,៩២% បានរាយការណ៍ថាគ្រួសារពួកគាត់មិនហៅឱ្យចូលរួមក្នុងសកម្មភាពក្នុងគ្រួសារនានា (ដូចជាការធ្វើម្ហូប ការញ៉ាំអីជុំគ្នា ឬការគេងក្នុងបន្ទប់ជាមួយគ្នា) ដែលផ្ទុយពីអ្នកមិនរកស៊ីផ្លូវភេទដែលមានចំនួនតែ ៦,០២%។ ដូចគ្នានេះដែរ អ្នករកស៊ីផ្លូវភេទចំនួន ១៦,៣៣% បានរាយការណ៍ថា ធ្លាប់រងអំពើហិង្សាពីគ្រួសាររបស់ពួកគាត់ ដែលផ្ទុយពីអ្នកមិនរកស៊ីផ្លូវភេទដែលមានចំនួនតែ ៤,៩៤% និង អ្នករកស៊ីផ្លូវភេទចំនួន ២៣,៤% ធ្លាប់ត្រូវបានបណ្តេញចេញពីផ្ទះ ដែលចំនួននេះខុសពីអ្នកមិនរកស៊ីផ្លូវភេទដែលមានចំនួនតែ ១០,៧១%។

អ្នករកស៊ីផ្លូវភេទត្រូវបានមើលឃើញថាជនងាយរងគ្រោះ ជាពិសេសពីការបំពានដោយដៃគូស្នេហារបស់ ខ្លួន ។ ចំនួនអ្នករកស៊ីផ្លូវភេទជាច្រើនបានរាយការណ៍ថា ដៃគូស្នេហាបង្ខំឱ្យរួមភេទផ្ទុយពីបំណងរបស់ពួកគាត់ បើប្រៀបទៅនឹងអ្នកមិនរកស៊ីផ្លូវភេទ (ក្នុងចំនួន ៤៧,៩២% បើប្រៀបទៅនឹង ២៣,៥៣%)។ ការបំពានលើអ្នករកស៊ីផ្លូវភេទពីសំណាក់ដៃគូស្នេហា ឬដៃគូរួមភេទ ក៏មានកម្រិតខ្ពស់ដែរក្នុងចំនួន ៣៦,៧៣% ដែលបានរាយការណ៍ថា មានករណីនេះកើតឡើងក្នុងរយៈពេល ១២ ខែចុងក្រោយ ធៀបទៅនឹងអ្នកមិនរកស៊ីផ្លូវភេទដែលមានចំនួនតែ ១៤,៦៣%។

លទ្ធផលពីការស្រាវជ្រាវទាំងនេះនាំឱ្យយើងធ្វើការកត់សម្គាល់បានចំនួនពីរចំណុចពាក់ព័ន្ធនឹងអ្នកប្តូរភេទជាស្ត្រីដែលជាអ្នករកស៊ីផ្លូវភេទគឺ ទី១ មានទំនាក់ទំនងច្បាស់លាស់រវាងកង្វះការទទួលយកពីសំណាក់គ្រួសារ និងភាពសមទំនងដែលអ្នកប្តូរភេទជាស្ត្រីនឹងចាប់យកការងាររកស៊ីផ្លូវភេទ និងទី ២ មានទំនាក់ទំនងរឹងមាំស្មើគ្នារវាងបទពិសោធន៍ដែលជួបប្រទះការរើសអើងនៅក្នុងការងារក្នុងប្រព័ន្ធ ដូចជាការបដិសេធទទួលឱ្យធ្វើការ និងការបណ្តេញចេញពីការងារដោយសារតែអត្តសញ្ញាណប្តូរភេទ និងការងាររកស៊ីផ្លូវភេទរបស់ពួកគាត់។ ខណៈដែលបេកគំហើញពីការស្រាវជ្រាវទាំងនេះរំលេចពីការលំបាកកាន់តែកើនឡើងរបស់អ្នករកស៊ីផ្លូវភេទ ការស្រាវជ្រាវបែបគុណវិស័យគួរធ្វើបន្ថែមដើម្បីបញ្ជាក់ពីហេតុផលច្បាស់លាស់ និងរឹងមាំ។

អត្រាកម្រិតខ្ពស់នៃអ្នកប្តូរភេទជាស្ត្រីដែលធ្វើការជាអ្នករកស៊ីផ្លូវភេទ ក៏បង្ហាញអោយឃើញថាចំនួនអ្នកប្តូរភេទជាច្រើនមានជីវភាពនិងសន្តិសុខការងារត្រូវរងផលប៉ះពាល់ជាអវិជ្ជមានដោយសារការបង្ក្រាបពីសំណាក់នគរបាលកាន់តែច្រើនឡើងទៅលើបររកស៊ីផ្លូវភេទ។ ជាការគួរឱ្យកត់ចំណាំថា ទន្ទឹមនឹង "*បទហៅអ្នកដទៃនៅទីសាធារណៈ*" គឺជាអំពើខុសច្បាប់ បើយោងតាមមាត្រា ២៩៨ នៃក្រមព្រហ្មទណ្ឌ ការអនុវត្តច្បាប់មិនត្រូវធ្វើទៅក្នុងលក្ខណៈរើសអើង ហើយមន្ត្រីនគរបាលគ្មានសមត្ថកិច្ច ឬអ្វីដែលអាចបញ្ជាក់ពីភាពត្រឹមត្រូវក្នុងការប្រព្រឹត្តបំពានលើអ្នករកស៊ីផ្លូវភេទនោះទេ សូម្បីតែនៅពេលរកឃើញថាពួកគាត់ប្រព្រឹត្តអំពើបែបនោះក្តី។ បញ្ហាជាក់លាក់នៃការរើសអើងនិងការប្រមាថរបស់មន្ត្រីនគរបាលលើអ្នករកស៊ីផ្លូវភេទដែលជាអ្នកប្តូរភេទជាស្ត្រីត្រូវបានពិភាក្សាបន្ថែមនៅក្នុងផ្នែកតូចៗខាងក្រោម។

## ៤.៦.១ ការរើសអើងរបស់នគរបាលលើអ្នករកស៊ីផ្លូវភេទដែលជាមនុស្សប្តូរភេទ

ការស្រាវជ្រាវរបស់ ម.ស.ម.ក ចង្អុលបង្ហាញពីកំណើនប្រតិបត្តិការបង្ក្រាបរបស់អាជ្ញាធរលើអ្នករកស៊ីផ្លូវភេទ ដែលផ្តោតពិសេសទៅលើអ្នកប្តូរភេទជាស្ត្រី។[44] ការស្រាវជ្រាវដែលបានបញ្ចប់នៅឆ្នាំ ២០០៩ជុំវិញច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានបង្ហាញថាទន្ទឹមនឹងការឃាត់ខ្លួនស្ត្រីរកស៊ីផ្នែកកំសាន្តមានការថយចុះនៅចន្លោះឆ្នាំ ២០០៧ ដល់ឆ្នាំ ២០០៨ តែការឃាត់ខ្លួនបុរសស្រឡាញ់បុរស និងអ្នកប្តូរភេទរកស៊ីផ្នែកកំសាន្តកើនឡើងមួយជាបី ក្នុងអំឡុងពេលដូចគ្នានោះជារឿយៗត្រូវបានលើកឡើងថាដោយសារតែការសង្ស័យបែបរើសអើងថាពួកគាត់អាចជាចោរ។[45] ម.ស.ម.ក ក៏ទទួលបានរបាយការណ៍ជាច្រើនអំពីអ្នកប្តូរភេទជាស្ត្រីដែលធ្វើការងាររកស៊ីផ្លូវភេទត្រូវបានកេងចំណេញពីមន្ត្រីនគរបាលដើម្បីទទួលបានកម្រៃផ្នែកហិរញ្ញវត្ថុ និងត្រូវបានចាប់ខ្លួនក្នុងរូបភាពការចោទប្រកាន់ដោយទម្លាក់កំហុសថាប្រើប្រាស់គ្រឿងញៀន ជួញដូរ ឬពេស្យាកម្ម។




---

[44] ចិនឃិន ស៊ី (Jenkins, C) "អំពើហិង្សាលើ និងការងាយឆ្លងពីជម្ងឺអេដស៍របស់អ្នករកស៊ីផ្លូវភេទនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា" ឆ្នាំ ២០០៦ ។

[45] CACHA និងអាជ្ញាធរជាតិប្រឆាំងនឹងជម្ងឺអេដស៍ "បរិយាកាសគោលនយោបាយអំពីការទទួលបានជាសកលនិងសិទ្ធិធ្វើការរបស់អ្នករកស៊ីផ្នែកកំសាន្តនៅកម្ពុជា" របាយការណ៍ស្រាវជ្រាវ ទំព័រទី ៦៥-៦៧ ឆ្នាំ ២០០៩ ។

ក្នុងចំណោមអ្នករកស៊ីផ្លូវភេទដែលបានស្ទង់មតិចំនួន ៥៨,៣៣% រាយការណ៍ថាខ្លួនត្រូវបានមន្ត្រីនគរបាលប្រមាថ ឬសម្លុតដោយសារតែពួកគាត់ជាមនុស្សប្តូរភេទ ដោយក្នុងនោះមាន ៩៦% រាយការណ៍ថាបានជួបហេតុការណ៍នេះក្នុងរយៈពេល ១២ ខែចុងក្រោយ។ ការបំពានលើរូបរាងកាយ ត្រូវបានរាយការណ៍ថាមានចំនួន ៣០,៦១% និងការបំពានផ្លូវភេទមានចំនួន ១៨,២៧%។ អ្នករកស៊ីផ្លូវភេទចំនួន ៤៦,៩៤% ដែលជាចំនួនច្រើនបានរាយការណ៍ថាត្រូវបានមន្ត្រីនគរបាលចោទប្រកាន់ដោយទម្លាក់កំហុសពីបទល្មើសបើប្រៀបជាមួយនឹងអ្នកមិនរកស៊ីផ្លូវភេទដែលមានចំនួនតែ ២៥,៨៨% ។

## ៤.៧ ការប្រព្រឹត្តិដ៏ឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោករបស់នគរបាល

ករណីជាច្រើនពីអ្នកប្តូរភេទជាស្ត្រីដែលត្រូវបានចាប់ខ្លួនជាច្រើនដង ដែលទំនងជាធ្វើឱ្យផលប៉ះពាល់ដូចនឹងការប្រព្រឹត្តដ៏ឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោក ឬប្រហែលអាចជាការធ្វើទារុណកម្មដែលត្រូវបានហាមឃាត់ដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ។[46] ថ្វីបើ *"អំពើធ្វើទារុណកម្ម និងព្រៃផ្សៃ"* អាចប្រឈមនឹងផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពី ៧ ទៅ ២០ ឆ្នាំស្របតាមច្បាប់ជាតិ ឬច្រើនជាងនេះបើការធ្វើទារុណកម្មប្រព្រឹត្តដោយមន្ត្រីរាជការយ៉ាងណាក្តី ជារឿយៗដូចក្នុងករណីទាំងនេះអ្នកប្រព្រឹត្ត បំពានលើអ្នករកស៊ីផ្លូវភេទជាជាមនុស្ស ប្តូរភេទ (និងអ្នករកស៊ីផ្លូវភេទជាទូទៅ) តែងរួចផុតពីការដាក់ទោសទណ្ឌ ដោយសារតែបទល្មើសទាំងនោះមិនត្រូវបានរាយការណ៍ ឬអាជ្ញាធរមិនធ្វើការស៊ើបអង្កេតឱ្យបានគ្រប់ជ្រុងជ្រោយ។

### ៤.៧.១ ការបង្ខំឱ្យចុះងូតទឹកនៅក្រុងសៀមរាប

ម.ស.ម.ក បានទទួលរបាយការណ៍ជាច្រើនពីជនរងគ្រោះផ្ទាល់ និងពីបណ្តាញក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅតាមមូលដ្ឋានក្នុងអំឡុងពេលធ្វើការស្រាវជ្រាវនៅក្នុងក្រុងសៀមរាបពាក់ព័ន្ធនឹងអនុវត្តបែបថ្មីៗនេះដែលនគរបាលកំណត់គោលដៅលើអ្នករកស៊ីផ្លូវភេទដែលជាមនុស្សប្តូរភេទ និងបង្ខំឱ្យពួកគាត់ចុះងូតទឹកនៅក្នុងស្ទឹងដ៏កខ្វក់ នៅពេលរកឃើញថាអ្នកទាំងនោះកំពុងតែធ្វើការងាររកស៊ីផ្លូវភេទ ឬទម្លាក់កំហុសថាធ្វើការងាររកស៊ីផ្លូវភេទ។ មានពេលខ្លះ ពួកគាត់ត្រូវបានបង្ខំឱ្យងូតទឹកស្រាត។ អ្នកស្រាវជ្រាវរបស់ ម.ស.ម.ក ទទួលដំណឹងថា នៅក្នុងករណីខ្លះអ្នកប្តូរភេទជាស្ត្រីដែលជាគោលដៅរបស់នគរបាលអាចសូកប៉ាន់ប្រហែលជា ៣០ ដុល្លារ ដើម្បីរួចផុតពីការដាក់ទណ្ឌកម្មក្រៅប្រព័ន្ធតុលាការដ៏គួរឱ្យខ្មាសអៀនមួយនេះ ប៉ុន្តែមិនមែនគ្រប់ករណីទាំងអស់នោះទេ។ ខណៈដែលគ្មានមន្ទិលសង្ស័យពីការបំពានរបស់នគរបាល ការអនុវត្តបែបនេះគឺជាក្តីបារម្ភទ្វេឡើង ដោយសារតែជាប់ទាក់ទងនឹងការរើសអើង និងចិត្តសាស្ត្រ។

---

[46] ឧទាហរណ៍ សូមមើលឯកសារ "ការមើលលម្អិតបន្ថែមពី៖ ការឃុំខ្លួនតាមអំពើចិត្ត និងការបំពានផ្សេងទៀតលើអ្នករកស៊ីផ្លូវភេទនៅកម្ពុជា" របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ឆ្នាំ ២០១០ ។

មានសេចក្តីរាយការណ៍ថា ការបកស្រាយការអនុវត្តបែបនេះថាមានការបង្ខំឱ្យអ្នករកស៊ីផ្លូវភេទត្រឡប់ទៅផ្ទះវិញ ជាជាងឱ្យពួកគាត់ត្រឡប់មកនៅតាមផ្លូវទៀត។ ក៏ប៉ុន្តែ អ្នកផ្តល់សម្ភាសន៍បានប្រាប់អ្នកស្រាវជ្រាវរបស់ ម.ស.ម.ក ថាការដាក់ទណ្ឌកម្មនេះមិនបានអនុវត្តលើអ្នករកស៊ីផ្លូវភេទជាយេនឌ័រពីកំណើតទេ ដែលប្រការនេះបង្ហាញពីការរើសអើងលើអ្នកប្តូរភេទជាស្ត្រី។ ជាសក្តានុពល ដោយសារការអនុវត្តនេះពាក់ព័ន្ធនឹងការលាងសម្អាតខ្លួន ការលុបលាងម្សៅ និងពេលខ្លះត្រូវដោះសំលៀកបំពាក់ ធ្វើឱ្យការដាក់ទណ្ឌកម្មបែបនេះអាចជាការប៉ុនប៉ងលាតត្រដាងអត្តសញ្ញាណប្តូរភេទរបស់ជនរងគ្រោះ។

តាមច្បាប់ ក្រៅពីការបង្កើតឱ្យមានជាការរើសអើង វាទំនងដែលថាការប្រព្រឹត្តបែបនេះទៅលើអ្នកប្តូរភេទជាស្ត្រីពីសំណាក់នគរបាលយ៉ាងហោចណាស់យើងអាចចាត់ទុកថាជាការប្រព្រឹត្តដ៏ឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងអាចជាការធ្វើទារុណកម្មផង។ មាត្រា ១ នៃអនុសញ្ញាអន្តរជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលកម្ពុជាបានផ្តល់សច្ចាប័ន កំណត់ការធ្វើទារុណកម្មថាជា ៖

*"...អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្តក្តី ដែលត្រូវបានបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ ក្នុងគោលបំណងទាំងឡាយដូចជា ទាញយកព័ត៌មានពីជននោះ ឬ តតិយជនណាម្នាក់ ដាក់ទណ្ឌកម្មជននោះចំពោះអំពើណាមួយ ដែលជននោះ ឬតតិយជនណាម្នាក់បានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬបំភិតបំភ័យ ឬបង្ខិតបង្ខំជននោះ ឬតតិយជនណាម្នាក់* ***ឬដើម្បីមូលហេតុណាផ្សេងទៀតដែលផ្អែកលើការរើសអើងណាមួយ បើការឈឺចាប់ ឬការរងទុក្ខបង្កដោយមន្ត្រីសាធារណៈ ឬជនផ្សេងទៀត តាមការញុះញង់ ឬការព្រមព្រៀង ឬផ្តើមគំនិតរបស់មន្ត្រីសាធារណៈ ឬជនផ្សេងទៀតដែលបំពេញតួនាទី ជាផ្លូវការ។"*** [47]

ការបង្ខំឱ្យអ្នកប្តូរភេទជាស្ត្រីចុះងូតទឹក មានភាពស៊ីសង្វាក់ទៅនឹងនិយមន័យនៃការធ្វើទារុណកម្មដែលទទួលស្គាល់ជាទូទៅខាងលើនេះ។ វាពាក់ព័ន្ធនឹងការឈឺចាប់ និងរងទុក្ខយ៉ាងខ្លាំងខាងផ្លូវចិត្ត វាសំដៅដល់ការបំភិតបំភ័យ និងបង្ខិតបង្ខំ និងវាបង្ហាញឱ្យឃើញថាការធ្វើបែបនេះដោយផ្អែកលើការរើសអើង។ បន្ថែមពីលើនេះ ការដាក់ទណ្ឌកម្មកំពុងត្រូវបានអនុវត្តដោយអាជ្ញាធរសាធារណៈ ដូចនេះវាមានជាតុផ្សំគ្រប់គ្រាន់នៃអំពើធ្វើទារុណកម្មក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ជនរងគ្រោះបានរាយការណ៍ពីអារម្មណ៍អស់សង្ឃឹមនៅពេលសួរអំពីថាតើពួកគាត់គួររាយការណ៍ពីហេតុការណ៍នេះឬអត់ ដោយមានមន្ទិលថាករណីរបស់ពួកគាត់នឹងមិនត្រូវបាន យកចិត្តទុកដាក់ដោះស្រាយឱ្យនោះទេ។ ការរៀបរាប់ខាងក្រោមពីហេតុការណ៍គឺផ្អែកលើបទសម្ភាសន៍ដែលបានធ្វើជាមួយអ្នកប្តូរភេទជាស្ត្រីម្នាក់នៅក្នុងក្រុងសៀមរាប។ ឈ្មោះរបស់ជនរងគ្រោះត្រូវបានប្តូរ។

---

[47] អនុសញ្ញាអន្តរជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (សេចក្តីសម្រេចមហាសន្និបាតទូទៅលេខ ៣៩/៤៦ ឆ្នាំ១៩៨៤ ។

### *រឿងរបស់ស្រីលីម*

*"ប្រហែលជាមួយសប្ដាហ៍មុន ខ្ញុំត្រូវបាននគរបាលបង្ខំឱ្យចុះទៅក្នុងស្នឹង។ វាកើតឡើងប្រហែលជាពាក់កណ្ដាលអាធ្រាត្រ ពេលខ្ញុំទើបត្រឡប់មកពីពិធីបញ្ចុះសីមា។ នគរបាលទាំងនោះបានមកជិត និងប្រាប់ពួកយើងថាដល់ពេលត្រូវទៅដេកហើយ ហើយយើងមិនគួរនៅទីនេះពេលស្មើហ្នឹងបានទៀតទេ។ ខ្ញុំប្រាប់ពួកគាត់ថាខ្ញុំមិនដឹងថាខ្ញុំមិនអាចឈរនៅទីនេះនៅពេលយប់បានទេ និងបានសុំឱ្យពួកគាត់លើកលែងឱ្យខ្ញុំម្ដង។ ពួកគាត់និយាយថាមិនបានទេ និងប្រាប់ឱ្យពួកខ្ញុំចុះក្នុងស្នឹង ឬក៏ត្រូវបង់ប្រាក់ ៣០ ដុល្លារ។ ពួកគាត់ធ្វើបែបនេះតែទៅលើស្រីស្រស់ទេ ពួកគាត់មិនធ្វើបែបនេះជាមួយអ្នករកស៊ីផ្លូវភេទដែលជាស្រីធម្មតានៅម្ដុំនោះទេ។ នេះជាការរើសអើង ពួកគាត់តែងតែបង្ខំពួកយើងឱ្យចាកចេញពីទីកន្លែងនានា។*

*ខ្ញុំស្គាល់អ្នកដែលធ្លាប់ជួបរឿងបែបនេះដែរ គឺមិត្តភក្តិ ៣ នាក់របស់ខ្ញុំ កាលពីដើមខែមីនា [ឆ្នាំ ២០១៦]។ ពីមុន ពួកគាត់ធ្លាប់តែដេញឱ្យពួកយើងទៅផ្ទះ ប៉ុន្តែឥឡូវពួកគាត់ចាប់ផ្ដើមឱ្យពួកយើងចុះក្នុងស្នឹង។ នេះពិតជាមិនអាចទទួលយកបាននោះទេ វាធ្វើឱ្យខ្ញុំមិនសប្បាយចិត្ត។ ខ្ញុំចង់បានយុត្តិធម៌សម្រាប់ស្រីស្រស់។ យើងមិនដែលធ្វើអ្វីខុស ឬអ្វីអាក្រក់ទៅលើនគរបាលនោះទេ។ ពួកគាត់ត្រូវតែឈប់មាក់ងាយពួកយើង និងឈប់ព្យាយាមចង់បានលុយពីពួកយើងទៀត។ ឥឡូវនេះ ខ្ញុំគ្មានអារម្មណ៍ថាមានសុវត្ថិភាពនៅសៀមរាបទេ ហើយស្រីស្រស់ផ្សេងទៀតក៏មានអារម្មណ៍ចឹងដែរ។*

*ខ្ញុំធ្លាប់ជួបប្រទះអំពើហិង្សាពីនគរបាលកាលពីកន្លងមក ប៉ុន្តែវាជាការពិតដែលខ្ញុំមិនដែលទៅប៉ុស្តិ៍នគរបាលរាយការណ៍ពីហេតុការណ៍ហ្នឹងនោះទេ។ ខ្ញុំមិនគិតថាវាមានប្រយោជន៍ ហើយខ្ញុំក៏មិនគិតថាអាចនឹងឈ្នះនោះដែរ។ ពួកគាត់នឹងមិនយកចិត្តទុកដាក់ចំពោះរឿងខ្ញុំនោះទេ។ តែខ្ញុំចង់ឱ្យបញ្ឈប់រឿងទាំងអស់ហ្នឹង ហើយខ្ញុំចង់ឱ្យអាជ្ញាធរគោរពសិទ្ធិរបស់ស្រីស្រស់ និងបញ្ឈប់រាល់ការរំលោភបំពាន។"*

## ៤.៨ ការរាយការណ៍ពីការចំពាននានា

អ្នកផ្តល់សម្ភាសន៍ដែលធ្លាប់ត្រូវបានប្រមាថ ឬរើសអើង ត្រូវបានសួរសំណួរថាពួកគាត់ធ្លាប់រាយការណ៍ពីហេតុការណ៍ទាំងនោះទៅអាជ្ញាធរឬទេ ហើយអ្នកផ្តល់សម្ភាសន៍ចំនួន ៨៤,៧៣% បានឆ្លើយថាទេ។




នៅពេលសួរពីមូលហេតុ អ្នកផ្តល់សម្ភាសន៍ចំនួន ៥៥,២៦% បាននិយាយថាពួកគាត់ជឿថាគ្មានសង្ឃឹមនឹងទទួលបានជំនួយអ្វីពីការរាយការណ៍របស់ពួកគាត់នោះទេ។ បន្ថែមពីលើនេះ ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ទាំងអស់មាន ២៨,៩៥% បានជ្រើសយកចម្លើយ "ផ្សេងទៀត" ដោយសារពួកគាត់មានបំណងចង់សម្តែងការរួមបញ្ចូលជម្រើសដែលផ្តល់ឱ្យទាំងបួនចូលគ្នា មានដូចជាមិនចង់បន្តអូសបន្លាយបញ្ហា មានអារម្មណ៍ថាមិនសូវស្រួលក្នុងចិត្តពេលរាយការណ៍ និងមិនដឹងថានរណាដែលពួកគាត់ត្រូវរាយការណ៍ទៅ។ របកគំហើញពីការស្រាវជ្រាវទាំងនេះចង្អុលបង្ហាញថាអ្នកប្តូរភេទជាស្ត្រីមានជំនឿតិចតួច ឬគ្មានជំនឿទាល់តែសោះលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជា និងមានអារម្មណ៍ថាមានឱកាសតិចតួចក្នុងការទទួលបានសំណងពីការរំលោភបំពានដែលពួកគាត់បានជួបប្រទះ។ យើងអាចនិយាយបានថា ប្រការនេះមិនមែនជាអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ដោយសារតែការរីកដុះដាលនៃការរើសអើងកើតចេញពីអាជ្ញាធរខ្លួនឯងផ្ទាល់។

## ៤.៩ សុខភាពផ្លូវចិត្ត និងផលប៉ះពាល់ចិត្តសាស្ត្រពីការរើសអើង

ការរើសអើង ការមិនរាប់រកក្នុងសង្គម និងការមិនសូវមានការយកចិត្តទុកដាក់ អាចមានផលប៉ះពាល់អវិជ្ជមានយ៉ាងច្រើនដល់ការគោរពឱ្យតម្លៃខ្លួនឯង និងសុខមាលភាពចិត្តសាស្ត្ររបស់បុគ្គលម្នាក់ៗ ជាពិសេសដោយសារតែឥទ្ធិពលនៃការប្រមាថរើសអើង និងបុរេវិនិច្ឆ័យមិនសមហេតុផលដែលអាចចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គម។






ជាការលើកទឹកចិត្ត អ្នកផ្តល់សម្ភាសន៍ភាគច្រើន (ស្មើនឹង ៨៦,៥៧%) បាននិយាយថាពួកគាត់សប្បាយចិត្តនឹងជីវិតសព្វថ្ងៃដែលពួកគាត់មាន និងថាជីវិតរបស់ពួកគាត់ "ប្រសើរឡើង" (ស្មើនឹង ៦៧,៦៧%) ចាប់តាំងពីពួកគាត់បង្ហាញពីអត្តសញ្ញាណយេនឌ័រពិតមក។ ក៏ប៉ុន្តែ អ្នកផ្តល់សម្ភាសន៍ចំនួន ៣៦,៥៧% បាននិយាយថា ពួកគាត់មានអារម្មណ៍សោកស្តាយអំពីការបង្ហាញពីអត្តសញ្ញាណយេនឌ័រពិតជាសាធារណៈថាជាមនុស្សប្តូរភេទ។ ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ មានចំនួន ៤១,៣៥% (៥៣,០៦% ជាអ្នករកស៊ីផ្លូវភេទ និង ៣៤,៥២% ជាអ្នកមិនប្រកបរបរផ្លូវភេទ) បាននិយាយថា ពួកគេធ្លាប់គិតដល់ការធ្វើអត្តឃាត ដោយសារតែការយាយី ឬការរើស អើងដែលខ្លួនប្រឈម។ ក្នុងចំណោមអ្នកគិតថាចង់ធ្វើអត្តឃាត ៩៤,២៣% ប្រាប់ថាធ្លាប់ប៉ងធ្វើអត្តឃាតក្នុងរយៈពេល ១២ ខែចុងក្រោយនេះ។ ភាពរីករាយក្នុងកម្រិតខ្ពស់ដែលបានរាយការណ៍ ភ្ជាប់ជាមួយនឹងរបកគំហើញពីការស្រាវជ្រាវអំពីចំនួនអ្នកប្តូរភេទជាស្ត្រីដែលគិតចង់ធ្វើអត្តឃាតចង្អុលបង្ហាញថា ពួកគាត់ជាច្រើនជួបការលំបាក និងការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរនៅក្នុងជីវិតរបស់ខ្លួន ទោះបីជានៅទីបំផុតអ្នកផ្តល់សម្ភាសន៍ភាគច្រើនអាចរកឃើញភាពរីករាយរបស់ខ្លួន បន្ទាប់ពីប្រកាសពីអត្តសញ្ញាណយេនឌ័រពិតហើយក្តី។

ក្នុងចំណោមអ្នកប្តូរភេទជាស្ត្រីកម្ពុជាហាក់ដូចជាមានកិច្ចសហការគ្នារឹងមាំ និងមានអត្តសញ្ញាណរួមគ្នា។ អ្នកផ្តល់សម្ភាសន៍ស្ទើរតែទាំងអស់ (៩៤,៧៨%) បានប្រាប់ថាពួកគាត់មានមិត្តភក្តិជិតស្និទ្ធមួយចំនួន។ អ្នកផ្តល់សម្ភាសន៍ចំនួន ៦៧,៩១% ក៏បាននិយាយថាការប្រកាសពីអត្តសញ្ញាណយេនឌ័រពិតថាជាអ្នកប្តូរភេទបានផ្លាស់ប្តូរទំនាក់ទំនងរបស់ពួកគាត់ជាមួយមិត្តភក្តិក្នុងករណីខ្លះ ហើយក្នុងចំណោមនោះ មាន ៧៨% បាននិយាយថាទំនាក់ទំនងរបស់ពួកគាត់ជាមួយមិត្តភក្តិបានផ្លាស់ប្តូរទៅជាប្រសើរវិញ និងចំនួន ៨,៩៤% និយាយថា"ប្រសើរច្រើនមែនទែន"។ ក្នុងអំឡុងពេលស្រាវជ្រាវរបស់ ម.ស.ម.ក អ្នកស្រាវជ្រាវបានអង្កេតឃើញថាមានសហគមន៍ដែលចេះជួយទុក្ខធុរៈរបស់អ្នកប្តូរភេទនៅក្នុងទីប្រជុំជនជាច្រើននៅកម្ពុជា ដែលចេះគាំទ្រគ្នាទៅវិញទៅមក ហើយករណីបែបនេះ ជាការសំខាន់នៅក្នុងបរិបទសង្គមមួយដែលពោរពេញទៅដោយការរើសអើងយ៉ាងខ្លាំងទៅលើអ្នកប្តូរភេទជាស្ត្រី។ ករណីនេះត្រូវបានបង្ហាញឱ្យឃើញកាន់តែច្រើនឡើងតាមរយៈការផុសឡើងនៃក្រុម និងបណ្តាញគាំទ្រនានាដែលបង្កើតដោយ និងមានគោលដៅជួយដល់ក្រុមអ្នកប្តូរភេទ។

## ៤.១០ ការស្វែងរកជំនួយ និងក្រុមគាំទ្រ

ក្នុងចំណោមអ្នកប្តូរភេទជាស្ត្រីដែលបានស្ទង់មតិ មាន ៦៩,៤៧% បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា និង ៧៧,៣៤% បច្ចុប្បន្នជាសមាជិកនៃបណ្តាញក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។ ក៏ប៉ុន្តែ ទិន្នន័យនេះទំនងមិនអាចយកជាតំណាងបាននោះទេ មូលហេតុមកពីរបៀបទាក់ទងសុំជួបរបស់ក្រុមស្រាវជ្រាវជាមួយអ្នកផ្តល់សម្ភាសន៍ធ្វើឡើងជាចម្បងតាមរយៈបណ្តាញរបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅទូទាំងប្រទេសកម្ពុជា។ ជាការគួរឱ្យស្តាយ ដែនកំណត់នៃការស្រាវជ្រាវធ្វើឱ្យមានការលំបាកខ្លាំងក្នុងការជួបបុគ្គលដែលមិនទទួលបានសេវាគាំទ្រ ដែលភាគច្រើនគឺមិនអាចទាក់ទងធ្វើការស្ទង់មតិបាន។ ម្យ៉ាងទៀត ការស្រាវជ្រាវទៅលើឯកសារពាក់ព័ន្ធពីមុនមកផ្តល់នូវគំនិតមានប្រយោជន៍ជាច្រើនពីកំណើនជាទូទៅនៃបណ្តាញ

ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកប្តូរភេទនៅទូទាំងប្រទេសកម្ពុជា ហើយចលនាក៏ចេះតែកើនឡើងក្នុងចំណោមអ្នកប្តូរភេទជាស្ត្រីដើម្បីបង្កើតជាបណ្តាញ។ ជារបកគំហើញ នេះទំនងដែលថាមានចំនួនអ្នកប្តូរភេទជាស្ត្រីកាន់តែច្រើនកំពុងត្រូវបានសេវាគាំទ្រអាចទាក់ទងទៅដល់បាន។

ប៉ុន្តែ គួរឱ្យកត់ចំណាំថាបណ្តាញក្រុមអ្នកស្រឡាញ់ភេទដូចគ្នាភាគច្រើននៅខាងក្រៅរាជធានីភ្នំពេញផ្តោតយ៉ាងជាក់លាក់លើបញ្ហាជំងឺអេដស៍និងសុខភាព ហើយបណ្តាញទាំងនោះជាច្រើនខ្វះសមត្ថភាពឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការផ្នែកសិទ្ធិមនុស្សជាទូទៅរបស់អ្នកប្តូរភេទជាស្ត្រីនៅកម្ពុជា។ អង្គការដែលផ្តោតលើសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាមានដូចជា ម.ស.ម.ក ខេមអាស៊ាន និងសហគមន៍ឥន្ទធនូ កម្ពុជាដែលផ្តុំនៅតែក្នុងរាជធានីភ្នំពេញ មានន័យថាការគាំទ្រចាំបាច់មួយចំនួនសម្រាប់អ្នកប្តូរភេទជាស្ត្រីកំពុងតែខ្វះខាតនៅតាមទីប្រជុំជនផ្សេងទៀត។ អង្គការធ្វើការលើផ្នែកសុខភាពខ្លះមានកិច្ចប្រជុំជាប្រចាំជាមួយនឹងអាជ្ញាធរមូលដ្ឋាននិងស្ថាប័នជាតិ ដូចជាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក៏ប៉ុន្តែអ្នកស្រាវជ្រាវរបស់ ម.ស.ម.ក បានដឹងតាមរយៈសកម្មជនខ្លះថា អាជ្ញាធរជារឿយៗប្រកែកមិនចង់ពាក់ព័ន្ធនឹងបញ្ហាសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាជាទូទៅនៅក្នុងកិច្ចប្រជុំនោះទេ ដោយទទូចឱ្យកម្រិតការពិភាក្សាតែទៅលើការបង្ការការឆ្លងជំងឺអេដស៍ក្នុងន័យចង្អៀតប៉ុណ្ណោះ។

# ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការស្រាវជ្រាវរបស់ ម.ស.ម.ក បានបង្ហាញឱ្យឃើញពីកម្រិតរើសអើងលើស្ត្រីប្តូរភេទជាស្ត្រីគួរឱ្យព្រួយបារម្ភនៅតាមទីប្រជុំជននៅក្នុងប្រទេសកម្ពុជា។ ការរើសអើងនេះកើតមាននៅគ្រប់ផ្នែកទាំងអស់នៃជីវិតរស់នៅរបស់អ្នកប្តូរភេទជាស្ត្រី រាប់ចាប់តាំងពីគ្រួសារ និងសហគមន៍រហូតដល់ការងារ ទីកន្លែងសាធារណៈ និងការជាប់ពាក់ព័ន្ធជាមួយនឹងនគរបាល។ ជាការគួរឱ្យបារម្ភ ការឃាត់ខ្លួនមានលក្ខណៈរើសអើង ការជំរិតទារអ្វីមួយខុសច្បាប់ និងការបំពានលើអ្នកប្តូរភេទពីសំណាក់នគរបាលមានសភាពពុំរ៉ៃ និងភាគច្រើនកើតមានដោយគ្មានការដាក់ទោសទណ្ឌជាក់ស្តែង។ នៅក្នុងករណីខ្លះ ការប្រព្រឹត្តលើ អ្នកប្តូរភេទជាស្ត្រីពីសំណាក់កម្លាំងនគរបាលអាចជាការប្រព្រឹត្តដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោក ប្រសិនបើមិនមែនជាការធ្វើទារុណកម្ម ស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

របាយការណ៍លើកមុនបានបង្ហាញពីបញ្ហាធ្ងន់ធ្ងរជាខ្លាំង ដែលកម្រិតនៃការប្រមាថនិងការបំពានលើអ្នករកស៊ីផ្លូវភេទ (រួមទាំងបុរស និងស្ត្រីព្រមទាំងអ្នករកស៊ីផ្លូវភេទជាស្ត្រីប្តូរភេទ) និងការថែទាំត្រូវបានយកមកពិភាក្សានៅក្នុងរបាយការណ៍នេះ ដើម្បីវិភាគទិន្នន័យដែលប្រមូលបានមិនត្រឹមតែប្រើសម្រាប់ក្រុមអ្នកប្តូរភេទជាស្ត្រីទាំងមូលប៉ុណ្ណោះទេ ព្រមទាំងសម្រាប់យកមកវិភាគដាច់ដោយឡែកលើក្រុម ដែលបានរាយការណ៍មកថាធ្វើការងាររកស៊ីផ្លូវភេទដើម្បីធ្វើការវិភាគរកមើលចំណុចខុសប្លែកគ្នាសំខាន់ៗ។ របាយការណ៍នេះបានបង្ហាញថាអ្នកមិនរកស៊ីផ្លូវភេទក៏ជួបប្រទះការរើសអើងក្នុងកម្រិតខ្ពស់ដែរ ទោះបីជានៅក្នុងតំបន់ជាច្រើន អ្នករកស៊ីផ្លូវភេទជួបប្រទះការរើសអើងផ្ទួនៗគ្នានិងទទួលរងនូវការបំពានខ្ពស់ជាង ដោយសារតែមកពីការងាររបស់ពួកគាត់។ ដោយឡែក អ្នករកស៊ីផ្លូវភេទដែលជាអ្នកប្តូរភេទជាស្ត្រីជួបការបំពាននៅក្នុងទំនាក់ទំនងផ្លូវភេទនិងស្នេហាក្នុងកម្រិតខ្ពស់ជាង ជាពិសេសពីសំណាក់នគរបាលនិងអាជ្ញាធរ។ ការស្រាវជ្រាវក៏បានបង្ហាញថាការរើសអើងនៅក្នុងការងារក្នុងប្រព័ន្ធនិងការបដិសេធពីគ្រួសារ អាចធ្វើឱ្យអ្នកប្តូរភេទជាស្ត្រីក្លាយជាអ្នកស៊ីផ្លូវភេទ។

ថ្វីបើជួបប្រទះនឹងការរើសអើងក្នុងកម្រិតខ្ពស់ក្តី អ្នកប្តូរភេទជាស្ត្រីភាគច្រើនបានរាយការណ៍ថាខ្លួនរីករាយនឹងជីវិតនាពេលបច្ចុប្បន្នដែលអាចបញ្ជាក់បានច្រើនអំពីកម្រិតនៃភាពរឹងមាំផ្ទាល់របស់ពួកគេជាងគុណភាពជីវិត ដោយសារតែចំនួនអ្នកផ្តល់សម្ភាសន៍ដែលបានរាយការណ៍មានគំនិតចង់ធ្វើអត្តឃាតដោយសារការរើសអើងដែលពួកគាត់បានជួបប្រទះមានកម្រិតខ្ពស់គួរឱ្យបារម្ភ។ ដូចបានលើកឡើងរួចមកហើយ ក្នុងចំណោមអ្នកដែលបានធ្វើការស្ទង់មតិ ការទទួលបានការគាំទ្រពីក្រុមមានកម្រិតខ្ពស់ ហើយអ្នកប្តូរភេទជាស្ត្រីមួយចំនួនធំដែលបានសម្ភាសន៍រាយការណ៍ថាមានទំនាក់ទំនងល្អជាមួយនឹងមិត្តជិតស្និទ្ធ ដែលករណីនេះបង្ហាញថាអ្នកប្តូរភេទជាស្ត្រីនៅតាមទីប្រជុំជនទទួលបានគាំទ្រផ្នែកសង្គមច្រើន ថ្វីបើកម្រិតនៃបដិសេធទទួលស្គាល់ពីគ្រួសារនៅមានខ្ពស់យ៉ាងណាក្តី។

ទោះបីជាអ្នកប្តូរភេទជាស្ត្រីមានភាពរឹងមាំដែលបានសម្ភាសន៍នៅក្នុងការស្រាវជ្រាវនេះ និងសាមគ្គីភាពដែលមានក្នុងចំណោមសហគមន៍ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា វាមានភាពច្បាស់លាស់ច្រើនដែលថារដ្ឋាភិបាលកម្ពុជាខកខានក្នុងការបំពេញតួនាទីការពារ និងលើកកម្ពស់សិទ្ធិមនុស្សរបស់អ្នកប្តូរភេទជាស្ត្រីកម្ពុជា។ ចាំបាច់ត្រូវដាក់ចេញនូវសកម្មភាពបន្ទាន់ ដើម្បីបញ្ចប់ការបំពានក្នុងរូបភាពអាក្រក់បំផុតទាំងឡាយ ហើយដាក់ចេញនូវកំណែទម្រង់គោលនយោបាយពិតប្រាកដ និងរយៈពេលវែង ប្រសិនបើយើងចង់សម្រេចឱ្យបាននូវភាពស្មើគ្នាយ៉ាងពេញលេញដល់អ្នកប្តូរភេទជាស្ត្រីកម្ពុជា។

ដោយយោងតាមរបកគំហើញពីការស្រាវជ្រាវក្នុងរបាយការណ៍នេះ ម.ស.ម.ក មានបំណងចង់ផ្តល់អនុសាសន៍ដូចខាងក្រោមទៅដល់ស្ថាប័ននិងភាគីពាក់ព័ន្ធ ៖

### *១. អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា*

*១.១ បង្កើតច្បាប់ស្តីពីការហាមឃាត់ការរើសអើងគ្រប់ប្រភេទឱ្យច្បាស់លាស់ រួមទាំងការរើសអើងដោយឈរលើអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ និងនិន្នាការភេទដោយ ៖*

*១.១.១ ធានាឱកាស និងការប្រព្រឹត្តស្មើភាពគ្នាចំពោះអ្នកប្តូរភេទជាស្ត្រីនៅកន្លែងធ្វើការនិងដំណើរការជ្រើសរើសបុគ្គលិក។*

*១.១.២ ធានាការទទួលបានការអប់រំគ្រប់កម្រិត និងធានាការប្រព្រឹត្តស្មើគ្នាពីសិស្សានុសិស្ស និងលោកគ្រូ/អ្នកគ្រូ រួមទាំងគោលនយោបាយឯកសណ្ឋានរួមមួយ។*

*១.១.៣ ដាក់បញ្ចូលបទល្មើសជាក់លាក់នៃ"បទស្អប់ខ្ពើម"ទៅក្នុងក្រមព្រហ្មទណ្ឌ ស្របតាមការអនុវត្តល្អបំផុតរបស់អន្តរជាតិ រួមទាំងការផ្តន្ទាទោសសមស្របចំពោះជនល្មើសពីបទបទស្អប់ខ្ពើមលើអ្នកប្តូរភេទជាស្ត្រី និងក្រុមជនភាគតិចផ្សេងទៀត។*

*១.២ ធានាថាការរំលោភសិទ្ធិមនុស្សប្រឆាំងនឹងស្ត្រីអ្នកប្តូរភេទជាស្ត្រី ត្រូវបានដោះស្រាយយ៉ាងត្រឹមត្រូវដោយ*

*១.២.១ ធានាថាជនល្មើសទាំងអស់ដែលបានបំពានលើរូបរាងកាយ ផ្លូវភេទ និងពាក្យសម្តីលើអ្នកប្តូរភេទជាស្ត្រី ត្រូវបានផ្តន្ទាទោសស្របតាមច្បាប់និងមិនអនុញ្ញាតឱ្យទទួលបាននិទណ្ឌភាពនោះ។*

*១.២.២ ស៊ើបអង្កេតពីការអនុវត្តជាទូទៅនិងរើសអើងរបស់នគរបាលលើការឃាត់ខ្លួន ការឃុំខ្លួន ការជំរិតទារខុសច្បាប់ និងទម្លាក់កំហុសលើអ្នកប្តូរភេទជាស្ត្រីដែលគ្មានកំហុស ។*

*១.២.៣ ស៊ើបអង្កេតជាបន្ទាន់ពីករណីបង្ខំឱ្យចុះងូតទឹក ការធ្វើទារុណកម្ម និងការប្រព្រឹត្តិដ៏ឃោរឃៅអមនុស្សធម៌ និងបន្ទាបបន្ថោកដល់សេចក្តីថ្លៃថ្នូររបស់អ្នកប្តូរភេទជាស្ត្រី និងចាត់វិធានការសមស្របលើមន្ត្រីនគរបាលដែលរកឃើញថាមានជាប់ពាក់ព័ន្ធនៅក្នុងការដាក់ទោសខុសច្បាប់នេះ ។*

*១.២.៤ ស៊ើបអង្កេតពីករណីនគរបាលដែលបង្ខំអ្នកប្តូរភេទជាស្ត្រីមិនឱ្យដើរហើរនៅទីសាធារណៈនិងហាមពួកគេមិនឱ្យមកម្តងទៀត និងធានាថាមានភាពស្មើគ្នាក្នុងការដើរហើរនៅតាមទីសាធារណៈ។*

១.៣ ចាត់វិធានការបង្ការប្រឆាំងនឹងការរើសអើងលើអ្នកប្តូរភេទជាស្ត្រីតាមរយៈការបណ្តុះបណ្តាលមន្ត្រីនគរបាលពីគោលការណ៍មិនរើសអើង និងសិទ្ធិមនុស្ស ដូចមានកំណត់នៅក្នុងច្បាប់ជាតិ និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលកម្ពុជាបានផ្តល់សច្ចាប័ន។

១.៤ ធានាថាមានសេវាសុខភាពផ្លូវចិត្តទូលំទូលាយសម្រាប់សហគមន៍អ្នកប្តូរភេទ និងធានាថាបុគ្គលិកទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវក្នុងការដោះស្រាយបញ្ហាជាក់លាក់របស់អ្នកប្តូរភេទជាស្ត្រី។

១.៥ បង្កើតច្បាប់ដើម្បីធានាថាក្រុមអ្នកប្តូរភេទមានសិទ្ធិប្តូរភេទ និងឈ្មោះនៅលើឯកសារផ្លូវការនានាត្រឹមត្រូវតាមច្បាប់ ស្របជាមួយនឹងអត្តសញ្ញាណយេនឌ័រ នៅក្នុងដំណើរការមួយដែលអាចទទួលសេវាកម្មនេះបានដោយឥតកម្រៃ និងជាលក្ខណៈរដ្ឋបាល (ជាជាងតាមផ្លូវតុលាការ)។

១.៦ ប្រយុទ្ធប្រឆាំងនឹងការប្រមាថរើសអើង និងបុរេនិច្ឆ័យនៅក្នុងសង្គម តាមរយៈការបង្កើតកម្មវិធីបង្កើនការយល់ដឹងដល់ប្រជាជនទូទៅ និងនៅតាមសាលារៀនអំពីបញ្ហាអ្នកប្តូរភេទ និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា រួមទាំងការរៀបការដោយបង្ខំ។

១.៧ ដាក់ចេញកម្មវិធីអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដោយស្ម័គ្រចិត្ត និងមិនយកកម្រៃដល់អ្នករកស៊ីផ្លូវភេទដែលមានបំណងចង់ប្តូរមុខរបរ និងធ្វើវិសោធនកម្មលើគោលនយោបាយជាតិស្តីពីមុខរបរ ដើម្បីបញ្ចូលក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ថាជាក្រុមគោលដៅជាក់លាក់មួយ។

**២. អនុសាសន៍សម្រាប់អគ្គនាយកដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ**

២.១ ចាត់វិធានការដោះស្រាយការរំលោភបំពានដែលកំពុងរីកដាលលើសិទ្ធិរបស់អ្នកប្តូរភេទជាស្ត្រីពីសំណាក់នគរបាលដោយ៖

២.១.១ ស៊ើបអង្កេតរាល់ការលើកឡើងពីការរំលោភបំពានលើអ្នកប្តូរភេទជាស្ត្រីទាំងអស់ ដែលប្រព្រឹត្តដោយមន្ត្រីនគរបាល និងចាត់វិធានការដាក់ពិន័យសមស្រប រួមទាំងការព្យួរ ឬការបណ្តេញចេញពីកងកម្លាំងនគរបាល។

២.១.២ បញ្ចូលវគ្គបណ្តុះបណ្តាលពីសិទ្ធិមនុស្ស សិទ្ធិរបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា និងការមិនរើសអើងនៅក្នុងកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីនគរបាលដែលជាគ្រូបង្គោលទាំងអស់ និងផ្តល់ការបណ្តុះបណ្តាលបន្ថែមលើបញ្ហាទាំងនេះទៅដល់មន្ត្រីនគរបាលថ្មីៗ។

២.១.៣ អនុវត្តប្រព័ន្ធរាយការណ៍ក្នុងក្រុម និងពិធីសារការពារអ្នកឱ្យដំណឹងដល់មន្ត្រីនគរបាលដែលមានបំណងរាយការណ៍ពីអំពើរើសអើងពីសំណាក់មិត្តរួមការងាររបស់ពួកគេ។

**៣. អនុសាសន៍សម្រាប់គណបក្សនយោបាយទាំងអស់**

៣.១ ប្តេជ្ញាក្នុងការលើកកម្ពស់ការយល់ដឹងពីបញ្ហា និងសិទ្ធិរបស់អ្នកប្តូរភេទនៅកម្ពុជាដោយ៖

៣.១.១ ប្តេជ្ញាថាអនុម័តអនុសាសន៍ពីចំណុចទី១.១ ដល់ ១.៧ ប្រសិនបើបក្សខ្លួនឡើងកាន់អំណាច។

៣.១.២ ផ្សព្វផ្សាយសារវិជ្ជមានអំពីសហគមន៍អ្នកប្តូរភេទនៅពេលចុះធ្វើយុទ្ធនាការបោះឆ្នោត ឬពេលធ្វើការពិភាក្សាជាសាធារណៈ។

### ៤. អនុសាសន៍សម្រាប់និយោជក

៤.១ ដាក់ចេញនូវគោលនយោបាយមិនរើសអើងដើម្បីធានាពីសេចក្តីថ្លៃថ្នូរ និងការរាប់រកនៅកន្លែងធ្វើការ រួមទាំងការការពារសិទ្ធិរបស់និយោជិកជាក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។

៤.២ ធានាពីដំណើរការរើសបុគ្គលិក និងសេចក្តីសម្រេចរើសបុគ្គលិកដោយផ្តល់ឱកាសស្មើគ្នាដល់អ្នកប្តូរភេទជាស្ត្រី។

៤.៣ លើកទឹកចិត្តយ៉ាងសកម្មដល់អ្នកប្តូរភេទជាស្ត្រីឱ្យដាក់ពាក្យធ្វើការនៅពេលមានការផ្សព្វផ្សាយពីការរើសបុគ្គលិកសម្រាប់តំណែងដាក់លាក់ណាមួយ ឬការងារជាទូទៅ។

### ៥. អនុសាសន៍សម្រាប់សហជីពកម្មករ

៥.១ ធានាថាអ្នកប្តូរភេទជាស្ត្រីនៅកន្លែងការងារត្រូវបានតំណាងយ៉ាងគ្រប់គ្រាន់ ហើយសំឡេងរបស់ពួកគាត់ត្រូវបានគេស្តាប់។

៥.២ ធ្វើយុទ្ធនាការប្រឆាំងនឹងការរើសអើងពាក់ព័ន្ធនឹងអត្តសញ្ញាណយេនឌ័រធ្វើឡើងដោយនិយោជក និងអង្គការនានា។

៥.៣ អប់រំសមាជិកទាំងអស់អំពីសិទ្ធិរបស់អ្នកប្តូរភេទ និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។

### ៦. អនុសាសន៍សម្រាប់អង្គការសង្គមស៊ីវិលនៅកម្ពុជា

៦.១ បុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាល និងបណ្តាញដែលផ្តល់សេវាសុខភាព រួមទាំងអង្គការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ គួររៀបចំវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្ស និងវិធីសាស្ត្រដោយផ្អែកលើសិទ្ធិមនុស្ស ព្រមទាំងធានាថាយុទ្ធសាស្ត្របង្ការគិតគូរពីបញ្ហារើសអើង និងសុខភាពថាជាបញ្ហាពីរដែលមិនអាចកាត់ផ្តាច់ពីគ្នាបាន។ រាល់ការពាក់ព័ន្ធជាមួយនឹងអាជ្ញាធរទាំងអស់អំពីការបង្ការ និងយុទ្ធសាស្ត្រប្រឆាំងនឹងជម្ងឺអេដស៍ គួរតែអនុវត្តតាមវិធីសាស្ត្រនេះ និងផ្តល់សំឡេងដោយផ្ទាល់ទៅដល់អ្នកប្តូរភេទជាស្ត្រី តាមដែលអាចធ្វើទៅបាន។

៦.២ ធានាថាសិទ្ធិរបស់អ្នកប្តូរភេទក្លាយជាបញ្ហាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាដោយ ៖

៦.២.១ ស្នើគំនិតផ្តួចផ្តើមបង្កើតវគ្គអប់រំរួមស្តីពីសិទ្ធិអ្នកប្តូរភេទជាមួយនឹងរាជរដ្ឋាភិបាល ដែលផ្តោតលើមន្ត្រីរាជការ សាលារៀន និងសាធារណជនទូទៅ ។

៦.២.២ បញ្ជ្រាបការរួមបញ្ចូលអ្នកប្តូរភេទ ការមិនរើសអើង និងសិទ្ធិមនុស្សនៅក្នុងគោលនយោបាយផ្ទៃក្នុងនិងសកម្មភាពទាំងអស់ រួមទាំងការរើសបុគ្គលិក ។

### ៧. អនុសាសន៍សម្រាប់អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយ

៧.១ ធានាថាសិទ្ធិរបស់អ្នកប្តូរភេទក្លាយជាបញ្ហាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយ៖

៧.១.១ គាំទ្ររដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធឱ្យបង្កើត និងអនុវត្តគោលនយោបាយ និងច្បាប់ប្រឆាំងនឹងការរើសអើង ដើម្បីការពារសិទ្ធិរបស់អ្នកប្តូរភេទ ។

៧.១.២ ផ្តល់មូលនិធិ ចែករំលែក និងធ្វើការស្រាវជ្រាវបន្ថែមលើបញ្ហាអ្នកប្តូរភេទនៅកម្ពុជា រួមទាំងលើបទពិសោធន៍អ្នកប្តូរភេទជាបុរស ។

៧.២ បង្កើត និងអនុវត្តយុទ្ធសាស្ត្រដោះស្រាយក្តីបារម្ភ និងតម្រូវការរបស់អ្នកប្តូរភេទ ។

**៨. អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ថែម**

៨.១ ស៊ើបអង្កេតបន្ថែមពីការរីកដុះដាលនៃអំពើហិង្សាផ្លូវភេទលើអ្នកប្តូរភេទ រួមទាំងអ្នករកស៊ីផ្លូវភេទ ។

៨.២ ធ្វើការស្រាវជ្រាវបែបគុណវិស័យដើម្បីស្វែងរកមូលហេតុដែលធ្វើឱ្យអ្នកប្តូរភេទជាស្ត្រីចាប់យកការងាររកស៊ីផ្លូវភេទដោយយកចិត្តទុកដាក់ ជាពិសេសលើការមិនរាប់បញ្ចូលពីសំណាក់គ្រួសារ និងការរើសអើងក្នុងការងារក្នុងប្រព័ន្ធ ។

៨.៣ ធ្វើការស្រាវជ្រាវបែបគុណវិស័យ និងបរិមាណវិស័យស្តីពីប្រេវ៉ាឡង់និងទម្រង់នៃការរើសអើងដែលអ្នកប្តូរភេទជាបុរសជួបប្រទះនៅកម្ពុជា ។

# ឯកសារយោង

## ច្បាប់ជាតិ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ១៩៩៣)

## លិខិតុបករណ៍អន្តរជាតិ

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 2200 A (XXI) (ឆ្នាំ ១៩៦៦)

កតិកាសញ្ញាអន្តរជាតិស្តីពីសេដ្ឋកិច្ច សង្គម និងវប្បធម៌ ( 2200A មានដំណោះស្រាយ មហាសន្និបាតទី១១ (ឆ្នាំ១៩៦៦)

ការអធិប្បាយទូទៅលេខ ២០ "ការមិនរើសអើងចំពោះសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (កថាខណ្ឌ ២ មាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌)" របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ (E/C.12/GC/20) (ឆ្នាំ ២០០៩)

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ លេខ ១៧/១៩ ស្តីពី"សិទ្ធិមនុស្ស និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ" (A/HRC/RES/17/19) (ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០១១)

អនុសញ្ញាអន្តរជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ 39/46) (ឆ្នាំ ១៩៨៤)

ការអធិប្បាយទូទៅលេខ ២០ "ការមិនរើសអើងចំពោះសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (កថាខណ្ឌ ២ មាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌)" របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ (E/C.12/GC/20) (ឆ្នាំ ២០០៩)

"អនុសាសន៍ទូទៅលេខ ២៨ ស្តីពីកាតព្វកិច្ចស្នូលរបស់រដ្ឋភាគីស្របតាមមាត្រា ២ នៃ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (CEDAW/C/GC/28) របស់គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើអ្នកភេទនៃអង្គការសហប្រជាជាតិ (ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០១០)

## របាយការណ៍ និងឯកសារបោះពុម្ព

របាយការណ៍ស្តីពី "ការប្រកាសពីអត្តសញ្ញាណយេនឌ័រពិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា៖ ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទនៅកម្ពុជា" របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

(ឆ្នាំ ២០១០)
របាយការណ៍ស្តីពី "ការមាក់ងាយលើអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកប្តូរភេទនៅសាលារៀននៅក្នុងប្រទេសកម្ពុជា" របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ឆ្នាំ ២០១៥)
សន្និសីទរបស់អ្នកច្បាប់អន្តរជាតិ នៅទីក្រុងយ៉កយ៉ាកាតា ប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី ៦-៩ ខែវិច្ឆិកា ឆ្នាំ២០០៦។ "គោលការណ៍យ៉កយ៉ាកាតានៃការអនុវត្តច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិនៅក្នុងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ" (ថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០០៧)
ឯកសារ "លើសពីយេនឌ័រ៖ ការសិក្សាមូលដ្ឋានពីអ្នកប្តូរភេទនៅក្នុងឧស្សាហកម្មរកស៊ីផ្លូវភេទនៅរាជធានីភ្នំពេញ" សរសេរដោយ Davis, Jarrett និងអ្នកដទៃច្រើនទៀត (ឆ្នាំ ២០១៤)
ឯកសារ "ការធ្វើពិពិធកម្មយេនឌ័រ?៖ អត្តសញ្ញាណអ្នកប្តូរភេទពីបុរសមកជាស្រី និងកម្មវិធីជម្ងឺអេដស៍នៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា" សរសេរដោយ Earth, Barbara។ យេនឌ័រ និងការអភិវឌ្ឍ 14:2 ទំព័រពី ២៥៩ ដល់ ២៧១ (ឆ្នាំ ២០០៦)
ឯកសារ "ការមើលលម្អិតបន្ថែមពី៖ ការឃុំខ្លួនតាមអំពើចិត្ត និងការបំពានផ្សេងទៀតលើអ្នករកស៊ីផ្លូវភេទនៅកម្ពុជា" របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស (ឆ្នាំ ២០១០)
ឯកសារ "អំពើហិង្សា និងការងាយឆ្លងជម្ងឺអេដស៍របស់អ្នករកស៊ីផ្លូវភេទនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា" (ឆ្នាំ ២០០៦) សរសេរដោយ Jenkins, C.
ឯកសារ "ច្បាប់ និងការអនុវត្តរើសអើង និងអំពើហិង្សាលើបុគ្គលដោយសារតែមូលហេតុនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ" (A/HRC/19/41) (ឆ្នាំ២០១១) របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)
ឯកសារ "ការកើតមកមានសេរីភាព និងសមភាព៖ និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រនៅក្នុងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស" (HR/PUB/12/06) (ឆ្នាំ ២០១២) របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)
"របាយការណ៍ស្រាវជ្រាវស្តីពីមតិយោបល់ ឥរិយាបថ និងអត្តចរិកចំពោះអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា" របស់សហគមន៍ឥន្ទធនូកម្ពុជា (RoCK) (ឆ្នាំ ២០១៥)
ឯកសារ "ការស្វែងរកការមិនរាប់បញ្ចូលស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស និងអ្នកប្តូរភេទនៅក្នុងគ្រួសារ និងសហគមន៍នៅក្នុងតំបន់ខ្លះក្នុងប្រទេសកម្ពុជា និងវិធីរបស់ពួកគេក្នុងការដោះស្រាយបញ្ហាទាំងនេះ" សរសេរដោយ Salas, V. (ឆ្នាំ ២០១៣)
ឯកសារ "គម្រោងឃ្លាំមើលឃាតកម្មទៅលើអ្នកប្តូរភេទ - ការធ្វើបច្ចុប្បន្នភាពលើ IDAHOT ឆ្នាំ២០១៥" (ថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៥) របស់ Trans Respect Versus Transphobia Worldwide អាចរកមើលបានតាម រយៈ *http://bit.ly/1Iwy9Qy*
ឯកសារពិភាក្សាស្តីពី "សុខភាព និងសិទ្ធិមនុស្សរបស់អ្នកប្តូរភេទ" របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

(ឆ្នាំ ២០១៣)
ឯកសារ "ក្នុងនាមជាអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកប្តូរភេទនៅអាស៊ីៈ របាយការណ៍ប្រទេសកម្ពុជា - ការត្រួតពិនិត្យ និងការវិភាគដោយមានការចូលរួមលើបរិយាកាសច្បាប់ និងសង្គមសម្រាប់ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ និងសង្គមស៊ីវិល" (ឆ្នាំ ២០១៤) របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

## អត្ថបទសារព័ត៌មាន

អត្ថបទស្តីពី "សាលាក្រុងមានផែនការបង្កើតមជ្ឈមណ្ឌលវិជ្ជាជីវៈថ្មីមួយចំពេលប្រតិបត្តិការបោសសម្អាតអ្នកសុំទានតាមផ្លូវថ្នល់សរសេរដោយ Sokhean, Ben របស់សារព័ត៌មានខេមបូឌាដេលី នៅលើប្រព័ន្ធអ៊ិនធើណែត (ថ្ងៃទី ៩ ខែសីហា ឆ្នាំ ២០១៥)